សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ ក្នុងសង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ (ខេត្តកណ្ដាល)

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៥ មិថុនា ឆ្នាំ២០២១


ស្រាវជាវដោយ

និស្សិតឈ្មោះ **ក. អ៊ុង ផាណ្ណា**

**ក. វិត សុផានី**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ណារ៉េត**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៤ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំទាំងអស់គ្នាជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាន់ទី១៤ ឆមាសទី២ ផ្នែករដ្ឋបាលសាធារណៈ ឆ្នាំសិក្សា ២០១៧-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច **សូមលំឱនកាយសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោកអ្នកមានគុណរួមមានដូចខាងក្រោម៖**

**លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើតឲ្យកូនបានរស់រានមានជីវិត បើគ្មានលោកអ្នកមានគុណទាំងពីរទេរូបកូនក៏គ្មានថ្ងៃនេះដែរ គុណនេះពុំអាចកាត់ថ្លៃបានឡើយ។ យើងខ្ញុំសូមអរគុណនូវអ្វីគ្រប់យ៉ាងដែលលោកបានខិតខំប្រឹងប្រែងទាំងកម្លាំងកាយ កម្លាំងចិត្ត បូជាជូនកូនដោយមិនគិតពីការនឿយហត់ក្រលំបាកដើម្បីចិញ្ចឹមបីបាច់ថែរក្សាការពារ បណ្តុះបណ្តាលអប់រំទូន្មានឲ្យកូនប្រព្រឹត្តតែអំពើល្អ។ ទាំងនេះគឺជាឱសថដ៏សក្តិសិទ្ធិសម្រាប់កូនក្នុងការបន្តពុះពារគ្រប់ឧបសគ្គក្នុងជីវិតដើម្បីឆ្ពោះទៅរកភាពឧត្តុង្គឧត្តមនាពេលអនាគត។

**ឯកឧត្តមបណ្ឌិត លុយ ចន្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាធិការរង គណៈគ្រប់គ្រង មន្ត្រី បុគ្គលិកបម្រើការ និងសាស្ត្រាចារ្យគ្រប់រូប ដែលបានយកចិត្តទុកដាក់លើការសិក្សារបស់និស្សិតទាំងអស់ ព្រមទាំងខិតខំព្យាយាមបង្ហាត់បង្រៀនរាល់ចំណេះដឹងនិងជំនាញក៏ដូចជាផ្តល់ដំបូន្មានល្អៗ ជួយបំផុសស្មារតីនិស្សិតគ្រប់រូបឲ្យខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការសិក្សា និងពង្រឹងសមត្ថភាពខ្លួនដើម្បីធ្វើយ៉ាងណាឲ្យក្លាយជាបុគ្គលម្នាក់ដែលមានសមត្ថភាពពេញលេញដែលជាតម្រូវការរបស់សង្គម ។

លោកសាស្ត្រាចារ្យ **បណ្ឌិត ឈុន ណារ៉េត** គឺជាសាស្ត្រាចារ្យម្នាក់ប្រកបដោយគតិបណ្ឌិតដែលលោកបានបង្ហាត់បង្រៀន និងដឹកនាំក្នុងការសរសេរកិច្ចការស្រាវជ្រាវនេះ។ លើសពីនេះទៅទៀតលោកបានលះបង់កម្លាំងកាយកម្លាំងចិត្ត ព្រមទាំងពេលវេលាដ៏មានតម្លៃ ខិតខំប្រឹងប្រែងណែនាំកែសម្រួល និងផ្តល់នូវមតិល្អៗដែលធ្វើឲ្យកិច្ចការស្រាវជ្រាវនេះមានភាពល្អប្រសើរ និងសម្រេចបានជោគជ័យ។

**ឯកឧត្តមបណ្ឌិត ប៉ែន ស៊ីម៉ន** តំណាងរាស្ត្រមណ្ឌលខេត្តកំពត ប្រធានគណៈកម្មការទី១០នៃរដ្ឋសភា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកំពត ដែលបានផ្តល់អាហារូបករណ៍ជាប្រាក់សោហ៊ុយវិភាជន៍ដល់រូបនាងខ្ញុំរយៈពេល៤ឆ្នាំ រហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** បានដោយជោគជ័យ។

លោកចៅសង្កាត់ សមាជិកក្រុមប្រឹក្សាសង្កាត់ និងស្មៀនសង្កាត់ដែលបានជួយសម្របសម្រួលក្នុងការផ្តល់ឯកសារ និងណែនាំពន្យល់ពីស្ថានភាពទូទៅជាក់ស្តែងនៃការគ្រប់គ្រងរដ្ឋបាលរបស់សង្កាត់កោះអន្លង់ចិន។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ សូមប្រសិទ្ធពរជ័យជូនដល់លោកអ្នកមានគុណគ្រប់រូប សូមជួបតែពុទ្ធពរទាំង ៤ប្រការ គឺ **អាយុ វណ្ណៈ** *សុខៈ ពលៈ* កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាថ្នាក់បរិញ្ញាបត្រឯកទេសរដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេលជិត៤ឆ្នាំ យើងខ្ញុំទទួលនូវចំណេះដឹងជាច្រើនទាក់ទងនឹងវិស័យរដ្ឋបាលសាធារណៈ។ នៅពេលចាប់ផ្តើមសិក្សាឆ្នាំដំបូង យើងខ្ញុំមានក្តីស្រមៃចង់បន្សល់ទុកនូវស្នាដៃមួយនៅសាកលវិទ្យាល័យបន្ទាប់ពីការបញ្ចប់ការសិក្សារបស់យើងខ្ញុំ ដើម្បីទុកជាឯកសារសម្រាប់ជំនួយដល់សិស្សនិស្សិតក្នុងការស្វែងយល់ពីស្នាដៃនេះ។

នៅពេលដែលទទួលបានឱកាសក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ យើងខ្ញុំក៏បានសម្រេចចិត្តចាប់យកប្រធានបទមួយគឺ **ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការក្នុងសង្កាត់កោះអន្លង់ចិន** (**ករណីសិក្សា សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល**) ។ វត្ថុបំណងនៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺធ្វើឡើងដើម្បីសិក្សាស្វែងយល់ពីដំណើរការគ្រប់គ្រងនិងការប្រព្រឹត្តទៅនៃរដ្ឋបាលសង្កាត់កោះអន្លង់ចិនថាតើមានដំណើរការប្រព្រឹត្តទៅយ៉ាងដូចម្តេច។ ក្រោយពីទទួលបាននូវបទពិសោធន៍ថ្មីៗនៃការសិក្សាស្រាវជ្រាវលើប្រធានបទនេះរួចមក ធ្វើឲ្យយើងបានយល់ដឹងកាន់តែស៊ីជម្រៅច្បាស់លាស់ជាងមុន ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការនៅឃុំ សង្កាត់ ជាលក្ខណៈជាក់ស្តែងតែម្តងដែលកន្លងមកនោះយើងធ្លាប់បានសិក្សាតែទ្រឹស្តីប៉ុណ្ណោះ។ សមិទ្ធផលមួយនេះ អាចសម្រេចជោគជ័យទៅបានអាស្រ័យដោយមានការសម្របសម្រួលជួយជ្រោមជ្រែងយិតយោងពីសាស្ត្រាចារ្យដឹកនាំ និងលោកគ្រូ អ្នកគ្រូ នៅក្នុងការផ្តល់ជាអនុសាសន៍ណែនាំត្រួសត្រាយបង្ហាញផ្លូវកែសម្រួលពាក្យពេចន៍រចនាបទអត្ថន័យខ្លឹមសារអក្ខរាវិរុទ្ធ ធ្វើឲ្យអត្ថបទស្រាវជ្រាវមួយនេះសម្រេចចេញជាលទ្ធផលដែលអាចទទួលយកបាន។ ទោះបីជាយើងខ្ញុំ ខិតខំព្យាយាមប្រឹងប្រែងពិនិត្យពិច័យយ៉ាងហ្មត់ចត់សារចុះសារឡើងម្តងហើយម្តងទៀតយ៉ាងណាក៏ដោយ ក៏នៅតែគេចមិនផុតជៀសមិនរួចពីការខុសឆ្គាំឆ្គង ចន្លោះប្រហោងឆកល្វែងមិនទាន់គ្រប់ជ្រុងជ្រោយនៅក្នុងទំព័រណាមួយជាក់ជាមិនខានឡើយ។ អាស្រ័យហេតុនេះ យើងខ្ញុំរង់ចាំទទួលយកនូវរាល់ការរិះគន់ ការផ្តល់មតិយោបល់នៅក្នុងន័យស្ថាបនា និងការកែលម្អដោយក្តីសោមនស្សរីករាយពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិតមិត្តអ្នកអាន និងអ្នកស្រាវជ្រាវជាពិសេសពីសំណាក់គណៈកម្មការត្រួតពិនិត្យ វាយតម្លៃដើម្បីធ្វើការកែលម្អឲ្យមានភាពល្អប្រសើរឡើងថែមទៀត។

ជាទីបញ្ចប់ យើងខ្ញុំមានក្តីសង្ឃឹមយ៉ាងមុតមាំថា ស្នាដៃមួយនេះអាចជាទុនដល់ការសិក្សាស្រាវជ្រាវទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការនៅឃុំ សង្កាត់ សម្រាប់មិត្តនិស្សិតនានា។ ជាមួយគ្នានេះ យើងខ្ញុំក៏សូមខន្តីអភ័យទោស នូវរាល់កំហុសឆ្គងដែលកើតមានឡើង ដោយអចេតនាក្នុងការប្រើប្រាស់ពាក្យពេចន៍ទាំងឡាយនៅក្នុងខ្លឹមសារ និងសូមទទួលយកនូវមតិរិះគន់ក្នុងន័យស្ថាបនា ដើម្បីឲ្យស្នាដៃមួយនេះកាន់តែប្រសើរឡើង។

# មាតិកា

ទំព័រ

## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ....១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ....២
៣. គោលបំណងនៃការស្រាវជ្រាវ....២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ....៣
៥. សារៈសំខាន់នៃការស្រាវជ្រាវ....៣
៦. វិធីសាស្ត្រស្រាវជ្រាវ....៤
៧. រចនាសម្ព័ន្ធនៃសារណា....៥


## ជំពូកទី ១
## ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃរដ្ឋបាលឃុំ សង្កាត់


១.១ និយមន័យ....៦
១.១.១. និយមន័យគ្រប់គ្រង....៦
១.១.២. និយមន័យរដ្ឋបាល....៦
១.១.៣. និយមន័យវិមជ្ឈការ....៧
១.១.៤ ទិដ្ឋភាពសំខាន់ៗនៅក្នុងវិមជ្ឈការ....៨
១.១.៥. ការអនុវត្តវិមជ្ឈការ....៨
១.១.៦. ហេតុផលនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ....៩
១.២ ទិសដៅវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់....១០
១.២.១ ការផ្តល់ឱកាសដល់ប្រជាពលរដ្ឋឲ្យចូលរួមក្នុងការធ្វើសេចក្តីសម្រេចនានា....១០
១.២.២ ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាពរស់នៅ....១១
១.២.៣ ការធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការផ្តល់សេវាជាមូលដ្ឋាន....១១
១.៣ តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់....១២
១.៣.១ អំណាចរបស់រដ្ឋបាលឃុំ សង្កាត់....១២
១.៣.២ តួនាទី និងមុខងាររបស់រដ្ឋបាលឃុំ សង្កាត់....១២

១.៣.៣ ព្រំដែននៃអំណាច...........................................................................................................១៣
១.៤ ការរៀបចំរដ្ឋបាលឃុំ សង្កាត់.................................................................................................... ១៤
១.៤.១ រចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់ ...................................................................................... ១៤
១.៤.២ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ........................................................ ១៥
១.៥ កិច្ចការរដ្ឋបាលឃុំ សង្កាត់..........................................................................................................១៩
១.៥.១ ការគ្រប់គ្រងទ្រព្យសម្បត្តិ..................................................................................................... ១៩
១.៥.២ ការគ្រប់គ្រងឯកសារឃុំ សង្កាត់..............................................................................................២០
១.៦. ប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ....................................................................................២១
១.៦.១. អត្ថន័យនៃផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់.......................................២១
១.៦.២ គោលការណ៍សំខាន់ៗនៃការកសាងផែនការឃុំ សង្កាត់...........................................................២១
១.៦.៣. តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ .................................................................................... ២៣

## ជំពូកទី ២

## ដំណើរការគ្រប់គ្រងរដ្ឋបាលសង្កាត់កោះអន្លង់ចិន (ខេត្តកណ្តាល)

២.១. ស្ថានភាពទូទៅ........................................................................................................................ ២៧
២.១.១. ស្ថានភាពភូមិសាស្ត្រ .............................................................................................................. ២៧
២.១.២. ស្ថានភាពប្រជាសាស្ត្រ............................................................................................................. ២៧
២.២. ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលសង្កាត់កោះអន្លង់ចិន .........................................................២៨
២.២.១. សមាសភាពក្រុមប្រឹក្សាសង្កាត់ ................................................................................................២៨
២.២.២. គណៈកម្មាធិការនានារបស់សង្កាត់..........................................................................................២៨
២.២.៣. ហិរញ្ញវត្ថុរបស់សង្កាត់..............................................................................................................៣១
២.៣. ការអភិវឌ្ឍសង្កាត់កោះអន្លង់ចិន (កណ្តាល) ................................................................................ ៣៣
២.៣.១. ផែនការអភិវឌ្ឍន៍សង្កាត់.......................................................................................................... ៣៣
២.៣.២. កម្មវិធីវិនិយោគរបស់សង្កាត់.....................................................................................................៣៦
២.៣.៣. គម្រោង និងសកម្មភាពវិនិយោគរបស់សង្កាត់............................................................................៣៨
២.៣.៤. សមិទ្ធផលនានា......................................................................................................................... ៤០

# ជំពូកទី ៣
# បញ្ហាប្រឈម និងដំណោះស្រាយ

៣.១ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមក្នុងសង្កាត់ ........ ៤២
៣.១.១. ផ្នែកសេដ្ឋកិច្ច ........ ៤២
៣.១.២. ផ្នែកសង្គមកិច្ច ........ ៤២
៣.១.៣. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ........ ៤៣
៣.១.៤. ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ........ ៤៣
៣.២ ដំណោះស្រាយ ........ ៤៤
៣.២.១ ពង្រឹងផ្នែកសេដ្ឋកិច្ច ........ ៤៤
៣.២.២ ពង្រឹងផ្នែកសង្គមកិច្ច ........ ៤៥
៣.២.៣ ពង្រឹងការថែទាំធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ........ ៤៦
៣.២.៤ បង្កើនប្រសិទ្ធភាពការងាររដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ........ ៤៧
៣.៣. ទិសដៅទៅអនាគត ........ ៤៨
៣.៣.១. ការបណ្តុះបណ្តាលធនធានមនុស្ស ........ ៤៨
៣.៣.២. ការបង្កើនថវិកាសង្កាត់ ........ ៤៩
៣.៣.៣. ការបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាសង្កាត់ ........ ៤៩
**សេចក្តីសន្និដ្ឋាន** ........ ៥១
**អនុសាសន៍** ........ ៥៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

តាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់មានមាត្រា១ បានកំណត់ថា ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា គឺប្រព្រឹត្តតាមនយោបាយវិមជ្ឈការ។ ឃុំ សង្កាត់ ជានីតិបុគ្គល ដូច្នេះបើគ្មានច្បាប់ចែងថាជានីតិបុគ្គលទេ បុគ្គលនេះគ្រាន់ជាក្រុមបុគ្គលតែប៉ុណ្ណោះ។ ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់។ ឃុំ សង្កាត់គ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួនដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ យើងកត់សម្គាល់ឃើញថាព្រះរាជាណាចក្រកម្ពុជាប្រកាន់យកនូវរបបគ្រប់គ្រងតាមបែបវិមជ្ឈការ បានន័យថា រដ្ឋបាលកណ្តាលបែងចែកអំណាចទៅឲ្យរដ្ឋបាលមូលដ្ឋានក្នុងការសម្រេចកិច្ចការរបស់ខ្លួនឲ្យស្របទៅនឹងច្បាប់ដែលបានកំណត់ក្នុងគោលបំណងអភិវឌ្ឍ និងស្តារឡើងវិញនូវវិស័យសេដ្ឋកិច្ចសង្គម ដែលជាទិសដៅមួយដ៏មានសារៈសំខាន់ក្នុងការរៀបចំ និងកែលំអរហេដ្ឋារចនាសម្ព័ន្ធសង្គមជាតិទាំងមូល ដើម្បីឈានឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ និងដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ។

តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៩០ រដ្ឋាភិបាលជាតិ បានធ្វើប្រតិភូតកម្មអំណាចកណ្តាលរបស់ខ្លួនជាបណ្តើរៗមករដ្ឋបាលមូលដ្ឋាន។ ជាមួយនឹងការប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ នៅឆ្នាំ២០០១ លំដាប់ទាបបំផុតនៃរដ្ឋបាលដែនដីបានក្លាយជានីតិបុគ្គលឯករាជ្យពីរដ្ឋាភិបាលថ្នាក់ជាតិ។ នេះបានន័យថា ឃុំ សង្កាត់ មានធនធាន ថវិកា កម្មសិទ្ធិ និងរដ្ឋបាលគ្រប់គ្រងផ្ទាល់ខ្លួន។ រាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ន មានយុទ្ធសាស្ត្រថ្នាក់ក្រោមជាតិសម្រាប់កាត់បន្ថយភាពក្រីក្រ និងខិតខំស្វែងរកនូវគន្លឹះថ្មីៗ ក្នុងការជួយកសាង និងអភិវឌ្ឍប្រទេសជាតិទាំងមូល។ រដ្ឋបាលដែនដីលំដាប់ទាបបំផុត ដែលមានសមត្ថកិច្ចក្នុងការរក្សាសណ្តាប់ធ្នាប់ ការការពារដែនដី សន្តិសុខសាធារណៈ និងមានភារៈកិច្ចអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាលដូចជា ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗ និងជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ ការលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ការការពារសិទ្ធិមនុស្ស បេតិកភណ្ឌជាតិ ការការពារបរិស្ថានធម្មជាតិក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន។ តាមកម្មវិធីធ្វើកំណែទម្រង់គោលនយោបាយរបស់រាជរដ្ឋាភិបាល មានគោលបំណងផ្តល់សិទ្ធិជូនពលរដ្ឋក្នុងមូលដ្ឋានពង្រឹងលទ្ធិប្រជាធិបតេយ្យចាប់ពីថ្នាក់មូលដ្ឋាន និងដើម្បីអភិវឌ្ឍឃុំ សង្កាត់ ដោយខ្លួនឯងផ្ទាល់។ ជាពិសេសក៏ឆ្លុះបញ្ចាំងពីភាពទាក់ទងគ្នាយ៉ាងល្អរវាងប្រជាពលរដ្ឋ និងរដ្ឋបាលដែនដីលំដាប់ទាបបំផុតដែលឈានឆ្ពោះទៅរកភាពសហការគ្នាដោយមានការរាក់ទាក់ស្និទ្ធស្នាល ទាំងការងាររដ្ឋបាល ទាំងការទំនាក់ទំនងគ្នា និងសន្តិសុខសណ្តាប់ធ្នាប់ ព្រមទាំងការអភិវឌ្ឍដែលនាំឲ្យឃុំ សង្កាត់ មានការរីកចម្រើនពោរពេញដោយមោទនភាព និងប្រកបដោយនិរន្តរ៍ភាពផងដែរ។

យោងតាមមាត្រា៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨ បានកំណត់ថា ខេត្តចែកជាក្រុង ក្រុងចែកជាស្រុក ស្រុកចែកជាឃុំនិងជាសង្កាត់។ ក្នុងនោះខេត្តកណ្តាលបានបែងចែកជា ១ក្រុងនិង១០ស្រុក ដែលគ្របដណ្តប់លើ១១៧ឃុំ សង្កាត់ និងចែងចែកជា១០០៥ភូមិជាចំណុះ។ ក្នុងចំណោម១១ ក្រុង ស្រុក ពួកយើងបានជ្រើសរើសយកក្រុងតាខ្មៅដែលមាន១០ឃុំ សង្កាត់ ដែលក្នុង១០ឃុំ សង្កាត់នោះយើងក៏បានជ្រើសរើសយកសង្កាត់មួយ គឺសង្កាត់កោះអន្លង់ចិនដើម្បីចុះធ្វើកម្មសិក្សាទៅលើការគ្រប់គ្រងឃុំ សង្កាត់តាមបែបវិមជ្ឈការនៅទីនោះ។

លំនាំបញ្ហាគ្រាន់តែជាចំណុចចាប់ផ្តើមមុនសរសេរសារណាតែប៉ុណ្ណោះ អ្វីដែលសំខាន់បន្តទៀតដែលញ៉ាំងឲ្យមានការសិក្សាស្រាវជ្រាវ គឺបុព្វហេតុនៃការសិក្សាស្រាវជ្រាវ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

យើងសង្កេតឃើញថា ការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការនៅសង្កាត់កោះអន្លង់ចិនយើងនៅមិនទាន់បានឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅឡើយទេ ដោយនៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវធ្វើការកែលម្អ និងដោះស្រាយឲ្យបានទាន់ពេលវេលា ដើម្បីបម្រើប្រជាពលរដ្ឋឲ្យបានល្អប្រសើរ ហេតុនេះហើយទើបនៅក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទ ការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការក្នុងសង្កាត់កោះអន្លង់ចិន (ក្រុងតាខ្មៅ ខេត្តកណ្តាល) នេះបានចោទជាបញ្ហាមួយចំនួនដូចខាងក្រោម៖

១. តើការគ្រប់គ្រងរដ្ឋបាលសង្កាត់កោះអន្លង់ចិន (ខេត្តកណ្តាល) មានដំណើរការប្រព្រឹត្តទៅដូចម្តេច?

២. តើមានបញ្ហាប្រឈមអ្វីខ្លះ ដែលធ្វើឲ្យមានរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍សង្កាត់?

៣. តើត្រូវមានដំណោះស្រាយដូចម្តេច ដើម្បីធ្វើការកែលម្អ និងដោះស្រាយបញ្ហាប្រឈមទាំងនោះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺដើម្បីចូលរួមចំណែកធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការក្នុងសង្កាត់កោះអន្លង់ចិន (ខេត្តកណ្តាល) ជាពិសេសជំរុញឲ្យមានការអភិវឌ្ឍឃុំ សង្កាត់ឲ្យមានការរីកចម្រើន ដើម្បីបម្រើប្រជាពលរដ្ឋឲ្យបានល្អប្រសើរ ឆ្លើយតបទៅតាមតម្រូវការជាក់ស្តែងរបស់ពួកគាត់។ គោលបំណងចម្បងដែលជំរុញឲ្យមានការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះគឺ៖

១.ដើម្បីសិក្សាស្វែងយល់ឲ្យបានច្បាស់លាស់អំពីតថភាពជាក់ស្តែងនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

២. ដើម្បីសិក្សាស្វែងយល់អំពីដំណើរការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នៅថ្នាក់ក្រោមជាតិ

៣. ដើម្បីសិក្សាស្វែងយល់អំពីការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋនៅមូលដ្ឋានឃុំ សង្កាត់

៤. ដើម្បីសិក្សាស្វែងយល់អំពីដំណើរការអភិវឌ្ឍន៍របស់សង្កាត់កោះអន្លង់ចិន (ខេត្តកណ្តាល)។

នៅក្នុងរបកគំហើញខាងលើនេះ យើងនឹងលើកយកមកធ្វើការសិក្សា ដើម្បីកែលម្អនូវចំណុចខ្វះខាតមួយចំនួនដែលជាកត្តារាំងស្ទះដល់ដំណើរការនៃការគ្រប់គ្រង និងការអភិវឌ្ឍរបស់សង្កាត់កោះអន្លង់ចិន ដែលស្ថិតក្នុងក្រុងតាខ្មៅ ខេត្តកណ្តាល។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះដែនកំណត់ និងទំហំនៃការស្រាវជ្រាវទៅលើប្រធានបទ ការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការក្នុងសង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាលនេះ មានវិសាលភាពគ្របដណ្តប់តែទៅលើសកម្មភាពការងាររបស់រដ្ឋបាលសង្កាត់កោះអន្លង់ចិន ដែលស្ថិតនៅក្នុងក្រុងតាខ្មៅ ខេត្តកណ្តាល ដែលជាទីតាំងត្រូវចុះធ្វើការសិក្សាស្រាវជ្រាវ។ ក្នុងនោះផងដែរយើងខ្ញុំបានកំណត់យករយៈពេលនៃការអនុវត្តការងារ ក្នុងឆ្នាំ២០២០ និងត្រីមាសទី ១ ឆ្នាំ២០២១ តែប៉ុណ្ណោះ។ ការចុះស្រាវជ្រាវរកឯកសារបានប្រព្រឹត្តទៅអស់រយៈពេល៣ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១ ដល់ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២១។ ការកំណត់នូវទំហំនៃការស្រាវជ្រាវបែបនេះ គឺដើម្បីងាយស្រួលក្នុងការកំណត់វិធីសាស្ត្រនៃការស្រាវជ្រាវលើប្រធានបទ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការលើកយកនូវប្រធានបទនៃការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការក្នុងសង្កាត់កោះអន្លង់ចិន មកធ្វើការសិក្សាស្រាវជ្រាវនេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់អ្នកសិក្សាផ្នែករដ្ឋបាលសាធារណៈ ព្រោះថាការសិក្សាតែទៅលើទ្រឹស្តីវាមិនទាន់គ្រប់គ្រាន់នៅឡើយទេ គឺទាមទារឲ្យយើងមានការអនុវត្តជាក់ស្តែងទៀតទើបវាល្អប្រសើរ ហើយនេះគឺជាឱកាសដ៏ល្អក្នុងការចុះទៅសិក្សាស្រាវជ្រាវដោយផ្ទាល់ដល់ទីកន្លែង ដើម្បីទទួលបាននូវបទពិសោធន៍ថ្មីបន្ថែមទៀតពីការសិក្សាទ្រឹស្តីនៅក្នុងសាលា ឬសិក្សាតាមរយៈអនឡាញ ដែលស្របពេលក្នុងកំឡុងពេលកូវីត ១៩។ ម្យ៉ាងវិញទៀត ការសិក្សាស្រាវជ្រាវនេះបានផ្តល់ឲ្យយើងខ្ញុំទាំងពីរនាក់ ក្នុងការសហការគ្នាដើម្បីពិភាក្សាមូលមតិផ្លោះប្តូរគំនិតយោបល់ទស្សនៈការយល់ឃើញទៅវិញទៅមក ហើយសំខាន់ជាងនេះទៅទៀត គឺថាទទួលបាននូវចំណេះដឹង និងបទពិសោធន៍ថ្មីៗផ្សារភ្ជាប់ទៅនឹងការងាររដ្ឋបាលនៅមូលដ្ឋានដែលជាផ្នែកមួយដ៏សំខាន់ក្នុងការសិក្សាលើជំនាញរដ្ឋបាលសាធារណៈនេះ។ ជាងនេះទៅទៀត ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺជាការចូលរួមចំណែកវិភាគទានដ៏សំខាន់មួយសម្រាប់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការនៅមូលដ្ឋានស្របតាមការចង់បានរបស់រាជរដ្ឋាភិបាលខិតខំប្រឹងប្រែង និងជំរុញឲ្យមានការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ។ ហើយលទ្ធផលដែលទទួលបានពីការសិក្សាស្រាវជ្រាវនេះអាចជាចំណេះដឹង និងបទពិសោធន៍ដ៏ល្អប្រសើរសម្រាប់ខ្លួនឯងផ្ទាល់ និងសម្រាប់សង្គមជាតិទាំងមូល តាមរយៈការកែលម្អនូវចំណុចខ្វះខាតនានា ដើម្បីជំរុញឲ្យមានការអភិវឌ្ឍនៅតាមជនបទ ជាពិសេសទុកជាឯកសារសម្រាប់សិស្ស និស្សិត មិត្តអ្នកអានបានមើលផងដែរ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការក្នុងសង្កាត់កោះអន្លង់ចិន (ខេត្តកណ្តាល) នេះ គ្រាន់តែជាសារណាបញ្ចប់ការសិក្សាប៉ុណ្ណោះ ដូចនេះយើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវ ដកស្រង់លើកយក និងប្រមូលទិន្នន័យពាក់ព័ន្ធមួយចំនួនដែលមានស្រាប់យកមកចងក្រងជាសារណានេះឡើង ដើម្បីឲ្យមានជាលក្ខណៈបែបវិទ្យាសាស្ត្រអាចទទួលយកបាន ដែលក្នុងនោះមានដូចជា ទិន្នន័យចម្បង (Primary Data) ទិន្នន័យបន្ទាប់បន្សំ (Secondary Data) និងការវិភាគទិន្នន័យ។

**ក. ទិន្នន័យចម្បង** ( Primary Data )

- ការចុះសិក្សាស្រាវជ្រាវឯកសារនៅសាលាសង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល
- ការធ្វើការសម្ភាសន៍ជាមួយមេឃុំ ក្រុមប្រឹក្សា សមាជិក ស្មៀន និងបុគ្គលិកសង្កាត់កោះអន្លង់ចិន
- ការធ្វើការសាកសួរជាក់ស្តែងជាមួយប្រជាពលរដ្ឋមួយចំនួននៅក្នុងសង្កាត់កោះអន្លង់ចិន
- ការសុំការណែនាំពីសាស្ត្រាចារ្យដឹកនាំសារណា។

**ខ. ទិន្នន័យបន្ទាប់បន្សំ** ( Secondary Data )

- ឯកសារគតិយុត្តនានាដូចជា រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីណែនាំជាដើម
- ឯកសារដែលប្រមូលបានពីសាលាសង្កាត់កោះអន្លង់ចិន
- សៀវភៅផ្សេងៗដែលទាក់ទងទៅនឹងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ឯកសារពីបណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ឯកសារទទួលបានពីសាស្ត្រាចារ្យដឹកនាំ
- ឯកសារមេរៀនដែលបានសិក្សាកន្លងមក
- ឯកសារដែលទទួលបានតាមរយៈប្រព័ន្ធអ៊ីនធើណេត។

ការប្រមូលឯកសារ ទិន្នន័យ ព័ត៌មានជាច្រើនប្រភេទ គឺយកមកធ្វើការវិភាគពណ៌នាយ៉ាងល្អិតល្អន់ ដើម្បីធ្វើឲ្យខ្លឹមសារនៃសារណានេះមានទម្ងន់ និងទឡ្ហីករណ៍ច្បាស់លាស់ ជាពិសេស គឺដើម្បីធ្វើការសិក្សាប្រៀបធៀប និងឆ្លុះបញ្ចាំងរវាងទ្រឹស្តី ជាមួយនឹងការងារជាក់ស្តែងនៃការគ្រប់គ្រងរដ្ឋបាលនៅសង្កាត់។

**គ. ការវិភាគទិន្នន័យ**

បន្ទាប់ពីប្រមូលបានឯកសារពាក់ព័ន្ធ ទិន្នន័យ ព័ត៌មាននានាតាមរយៈការចុះសិក្សាស្រាវជ្រាវនៅក្នុងសង្កាត់កោះអន្លង់ចិន និងតាមរយៈការសម្ភាសន៍ជាមួយចៅសង្កាត់ ក្រុមប្រឹក្សា សមាជិក ស្មៀន និងបុគ្គលិកសង្កាត់ដែលបម្រើការងារនៅក្នុងសង្កាត់ និងប្រជាពលរដ្ឋដែលរស់នៅសង្កាត់ខាងលើរួចមក យើងខ្ញុំបានធ្វើការសិក្សាប្រៀបធៀបឆ្លុះបញ្ចាំងរវាងទ្រឹស្តីនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ជាមួយនឹងការអនុវត្តការងារជាក់ស្តែង

ដើម្បីវិភាគរកចំណុចខ្លាំង និងចំណុចខ្សោយ ឬរកឲ្យឃើញនូវបញ្ហាប្រឈម និងដំណោះស្រាយនៃការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការនៅក្នុងសង្កាត់កោះអន្លង់ចិន ដើម្បីឈានឆ្ពោះទៅរកការធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់ជាអនុសាសន៍កែលម្អចំណុចខ្វះខាតឲ្យមានភាពល្អប្រសើរឡើង។

## ៧. រចនាសម្ព័ន្ធនៃសារណា

ក្នុងរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការក្នុងសង្កាត់កោះអន្លង់ចិននេះ បានបែងចែកចេញជា ១កថាខណ្ឌ និង៣ជំពូក ដូចខាងក្រោម៖

**កថាខណ្ឌទី១៖** សេចក្តីផ្តើម ដែលមាន លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃសារណា។

**ជំពូកទី១៖** ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃរដ្ឋបាលឃុំ សង្កាត់ យើងខ្ញុំនឹងនិយាយអំពី ការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ ទិសដៅវិមជ្ឈការនិងការអនុវត្តវិមជ្ឈការ តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់ ការរៀបចំរដ្ឋបាលឃុំ សង្កាត់ កិច្ចការរដ្ឋបាលឃុំ សង្កាត់ និងប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

**ជំពូកទី២៖** ដំណើរការគ្រប់គ្រងរដ្ឋបាលសង្កាត់កោះអន្លង់ចិន (ខេត្តកណ្តាល) យើងនឹងបរិយាយពីស្ថានភាពទូទៅ (ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ) ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលសង្កាត់កោះអន្លង់ចិន និងការអភិវឌ្ឍសង្កាត់កោះអន្លង់ចិន។

**ជំពូកទី៣៖** បញ្ហាប្រឈម និងដំណោះស្រាយ យើងនឹងរៀបរាប់អំពី ស្ថានភាពបច្ចុប្បន្ន បញ្ហាប្រឈម និងដំណោះស្រាយនៅក្នុងសង្កាត់កោះអន្លង់ចិន ថាតើមានបញ្ហាប្រឈមអ្វីខ្លះបានកើតមានឡើងនៅក្នុងសង្កាត់ ហើយស្វែងរកដំណោះស្រាយដើម្បីយកមកដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ ចុងក្រោយ គឺនិយាយទាក់ទងទៅនឹងទិសដៅអនាគត។

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖** ជាការសរុបនូវខ្លឹមសារនៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការក្នុងសង្កាត់កោះអន្លង់ចិន និងការផ្តល់នូវអនុសាសន៍ទស្សនវិស័យ ដើម្បីឲ្យការគ្រប់គ្រងរដ្ឋបាលក្នុងសង្កាត់កោះអន្លង់ចិនកាន់តែមានការអភិវឌ្ឍរីកចម្រើនលូតលាស់ជឿនលឿនទៅមុខកាន់តែប្រសើរ។

# ជំពូកទី ១

# ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃរដ្ឋបាលឃុំ សង្កាត់

# ជំពូកទី ១
# ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃរដ្ឋបាលឃុំ សង្កាត់

## ១.១ និយមន័យ

### ១.១.១. និយមន័យគ្រប់គ្រង

គ្រប់គ្រង (កិរិយាសព្ទ) ពាក្យនេះបានមកពីពាក្យថា គ្របគ្រង

គ្រប (កិរិយាសព្ទ)=បិទខ្ទប់ពីលើ ឧទាហរណ៍ គ្របឆ្នាំងឲ្យជិតទៅ គ្របពាងឲ្យជិតទៅ

គ្រប (នាមសព្ទ)=ប្រដាប់សម្រាប់បិទខ្ទប់ពីលើ ឧទាហរណ៍ គ្របពាង, គ្របបាត្រ

គ្រង (កិរិយាសព្ទ)= ចាំថែរក្សា, រក្សាជាជំនួស ឧទាហរណ៍ គ្រងរាជ, គ្រងងារ

គ្រង (សង្ឃសព្ទ)= ស្លៀកដណ្ដប់ត្រៃចីវរ ឧទាហរណ៍ លោកសង្ឃគ្រងចីវរ

គ្រប់គ្រង ឬគ្របគ្រង មានន័យថា បីបាច់, ថែរក្សា, ថែទាំដោយទទួលរងបន្ទុក រងខុសត្រូវលើខ្លួន។[1]

ដូច្នេះ ពាក្យថាគ្រប់គ្រងនេះ យើងអាចឲ្យនិយមន័យជារួមថា គឺជាដំណើរការនៃការអនុវត្ត ចាត់ចែង និង គ្រប់គ្រងការងារ ដើម្បីសម្រេចនូវគោលដៅរបស់អង្គភាព ឬស្ថាប័នណាមួយ ដោយមានទំនួលខុសត្រូវខ្ពស់ដើម្បី ធ្វើឲ្យការងារនោះមានប្រសិទ្ធភាពល្អប្រសើរទៅតាមការរំពឹងទុក។

### ១.១.២. និយមន័យរដ្ឋបាល

ពាក្យថា «រដ្ឋបាល» ត្រូវបានគេឲ្យនិយមន័យផ្សេងៗគ្នាជាច្រើន ប៉ុន្តែនៅក្នុងទីនេះ យើងសូមយើងលើក យកអត្ថន័យសំខាន់ៗ បី មកបង្ហាញគឺៈ

- **អត្ថន័យអក្សរសាស្ត្រ**

រដ្ឋបាល មកពីពាក្យថា រដ្ឋ+បាល

រដ្ឋ (ជាពាក្យបាលី) មានន័យថា ដែន ប្រទេស អ្នកនៅដែន រាស្ត្រ ប្រជាជន។[2] ឧទាហណ៍ រដ្ឋធម្មនុញ្ញ រដ្ឋការ រដ្ឋកិច្ច រដ្ឋាភិបាល ជាដើម។ល។

បាល (ជាពាក្យបាលី) មានន័យថា ការថែរក្សា ការគ្រប់គ្រង។

សរុបសេចក្ដីមក រដ្ឋបាលមានន័យថាអ្នករក្សាដែន ឬប្រទេស។ ឧទាហរណ៍ ក្រសួង រាជការកាន់កាប់ កិច្ចការក្នុងប្រទេសជាគូគ្នានឹងតុលាការ មន្ត្រីខាងរដ្ឋបាល, ក្របខ័ណ្ឌខាងរដ្ឋបាល។

[1] សម្ដេចព្រះសង្ឃរាជជួន ណាត,*វចនានុក្រមខ្មែរ* (ភ្នំពេញៈពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧), ១៥០។

[2] សម្ដេចព្រះសង្ឃរាជជួន ណាត,*វចនានុក្រមខ្មែរ* (ភ្នំពេញៈពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧), ៩៧៥។

❖ **អត្ថន័យទូលាយតាមបែបបច្ចេកទេស**

រដ្ឋបាលមានន័យពីរ ដែលអាចប្រើបានទាំងវិស័យសាធារណៈ និងវិស័យឯកជន។

តាមអត្ថន័យទី១ «រដ្ឋបាល» សំដៅដល់ «សកម្មភាព» ឧទាហរណ៍ កិច្ចការរបស់ក្រុមហ៊ុនកាត់ដេរ (វិស័យឯកជន), កិច្ចការរបស់ក្រសួងទេសចរណ៍ (វិស័យសាធារណៈ)។

តាមអត្ថន័យទី២ «រដ្ឋបាល» សំដៅដល់ «អង្គការ» ឧទាហរណ៍ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនអាហារ័ណនីហារ័ណ (វិស័យឯកជន).ក្រសួងទេសចរណ៍ (វិស័យសាធារណៈ)។

❖ **អត្ថន័យចង្អៀតតាមបែបបច្ចេកទេស**

ពាក្យ «រដ្ឋបាល» សំដៅដល់ «រដ្ឋបាលសាធារណៈ»។ យើងអាចប្រើប្រាស់ពាក្យថា «រដ្ឋការ» ឬ «រាជការ» ដែលមិននាំឲ្យមានការភ័ន្តច្រឡំជាមួយនឹងពាក្យ «រដ្ឋបាល» ក្នុងវិស័យឯកជន។ រាជការ សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពនីមួយៗរបស់រដ្ឋដែលមានមន្ត្រីរាជការស្ថិតក្នុងក្របខ័ណ្ឌរដ្ឋ បម្រើការងាររដ្ឋ មានមុខតំណែង តួនាទី និងទទួលប្រាក់បៀវត្សពីរដ្ឋ។ សរុបសេក្តីមក រដ្ឋបាលមានន័យថា ការគ្រប់គ្រងរដ្ឋមួយដែលអាជ្ញាធរធ្វើការរៀបចំគ្រប់គ្រងចាត់ចែង ដើម្បីបម្រើរាស្ត្រប្រជាឲ្យបានកាន់តែល្អប្រសើរឡើង សំដៅលើកកម្ពស់កម្រិតជីវភាពរស់នៅ ឆ្ពោះទៅកាន់ការកាត់បន្ថយភាពក្រីក្រ។

### ១.១.៣. និយមន័យវិមជ្ឈការ

វិមជ្ឈការ មានន័យថា រាជរដ្ឋាភិបាលបានប្រគល់ឲ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ឲ្យទៅក្រុមប្រឹក្សាថ្នាក់ក្រោមជាតិដូចជាក្រុមប្រឹក្សា រាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខ័ណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មូលដ្ឋាន។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅមូលដ្ឋានលើបញ្ហាទាំងនេះ។[3] វិមជ្ឈការ គឺជាការផ្ទេរអំណាច មុខងារ ការទទួលខុសត្រូវ និងធនធានមួយចំនួនពីរដ្ឋបាលកណ្តាលទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ដែលកើតឡើងដោយការបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យ។[4] ដូច្នេះ រដ្ឋត្រូវប្រគល់អំណាចមួយចំនួនទៅឲ្យឃុំ សង្កាត់សម្រាប់សម្រេចកិច្ចការមូលដ្ឋានខ្លួនឯងផ្ទាល់ ដោយមិនចាំបាច់សុំការអនុញ្ញាតពីអាជ្ញាធររដ្ឋបាលថ្នាក់កណ្តាលឡើយ គ្រាន់តែមានការត្រួតពិនិត្យនីត្យានុកូលភាព ទៅលើសេចក្តីសម្រេចរបស់រដ្ឋតែប៉ុណ្ណោះ។ ឃុំ សង្កាត់ទទួលបាននូវអំណាច ការទទួលខុសត្រូវមួយចំនួនដែលប្រគល់ឲ្យដោយច្បាប់ និងមានមធ្យោបាយមួយចំនួន គឺថវិការបស់ឃុំ សង្កាត់ដោយផ្ទាល់ឬធនធានដើម្បីអនុវត្តកម្មវិធីរបស់ខ្លួនដែលហៅថា វិមជ្ឈការ។ អំណាចកណ្តាលមិនត្រូវបានប្រមូលផ្តុំនៅក្នុងដៃរដ្ឋតែម្នាក់ឯង

[3] ក្រសួងមហាផ្ទៃ, *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ* , ឆ្នាំ២០១៧។

[4] ការផ្សាយរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់, ខែមករា ២០០២។

ទេ ពោលគឺជាការប្រគល់អំណាចទៅឲ្យរដ្ឋបាលថ្នាក់ក្រោមតាមរយៈច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានបង្កើតឲ្យឃុំ សង្កាត់ ដឹកនាំដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលទទួលបាននូវសិទ្ធិ អំណាចនៅក្នុងការអនុវត្តការងារ និងសម្រេចកិច្ចការដោយភាពម្ចាស់ការ និងទទួលខុសត្រូវ ដោយអនុវត្តទៅតាមលទ្ធិប្រជាធិបតេយ្យដោយមានប្រជាពលរដ្ឋចូលរួម។

### ១.១.៤ ទិដ្ឋភាពសំខាន់ៗនៅក្នុងវិមជ្ឈការ

ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់នីមួយៗមានសិទ្ធិបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន និងត្រូវបានផ្តល់សិទ្ធិ ក៏ដូចជាការទទួលខុសត្រូវ ដើម្បីចូលរួមយ៉ាងសកម្មក្នុងដំណើរការនៃការអភិវឌ្ឍមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន។ លើសពីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់ របស់ខ្លួនតាមបែបប្រជាធិបតេយ្យ។ ដូច្នេះ ក្រុមប្រឹក្សាឃុំ សង្កាត់ ជាអង្គការតំណាងឲ្យប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់ មានអាណត្តិ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង។[5] ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្តល់ការទទួលខុសត្រូវ និងភារកិច្ចជាច្រើនដែលខុសប្លែកទាំងស្រុងពីការទទួលខុសត្រូវ និងភារកិច្ចរបស់ឃុំ សង្កាត់កាលពីមុនបោះឆ្នោតឆ្នាំ២០០២។ ភារកិច្ចសំខាន់បំផុតរបស់ក្រុមប្រឹក្សាឃុំសង្កាត់ គឺអភិវឌ្ឍឃុំ សង្កាត់ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ហើយត្រូវបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាឲ្យមានការចូលរួមយ៉ាងពេញលេញពីប្រជាពលរដ្ឋនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចរបស់ខ្លួន និងសេចក្តីសម្រេចនានា ដែលមានឥទ្ធិពលទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដើម្បីធានាថា បញ្ហា តម្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋគ្រប់រូបត្រូវបានប្រមូល និងវិភាគគ្រប់ជ្រុងជ្រោយមុននឹងធ្វើសេចក្តីសម្រេចចិត្ត។

### ១.១.៥. ការអនុវត្តវិមជ្ឈការ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់នូវនយោបាយលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។[6] ឃុំ សង្កាត់ជារដ្ឋបាលមួយដែលមានការប្រាស្រ័យទាក់ទងដោយផ្ទាល់ និងជាប្រចាំជាមួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានដែនដីរបស់ខ្លួន។ រដ្ឋបាលថ្នាក់ឃុំ សង្កាត់ កើតចេញដោយផ្ទាល់ពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ដែលបានបោះឆ្នោតជ្រើសតាំងជាតំណាងដូច្នេះ ប្រជាពលរដ្ឋជាម្ចាស់លើរដ្ឋបាលនោះ។ការធ្វើវិមជ្ឈការនៅឃុំសង្កាត់ធ្វើឲ្យលទ្ធិប្រជាធិបតេយ្យបានចាក់ឫសកាន់តែរឹងមាំថែមទៀតឃុំ សង្កាត់ មានសិទ្ធិនិងអំណាចក្នុងការ

[5] មាត្រា ១១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១។

[6] មាត្រា ៥១ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣។

គ្រប់គ្រង និងចាត់ចែងការងាររបស់ខ្លួន។ រាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីធានាឲ្យការបោះឆ្នោតបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព។ ទោះបីជាជួបប្រទះនូវការលំបាក ខាងផ្នែកហិរញ្ញវត្ថុ និងមធ្យោបាយសម្ភារៈយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលបានសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាអង្គការក្រៅរដ្ឋាភិបាលដើម្បីរៀបចំកសាងប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការ ជំរុញការស្តារ និងអភិវឌ្ឍសង្គមមួយប្រកបដោយ ស្ថេរភាព សន្តិភាព និងវឌ្ឍនភាពឆ្ពោះទៅការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ វិមជ្ឈការ ជាទម្រង់បែបបទមួយ ជំរុញលទ្ធិប្រជាធិបតេយ្យក្នុងការទទួលខុសត្រូវ និងកាត់បន្ថយនូវអំពើពុករលួយជាដើម។ ការជំរុញឲ្យមានការអភិវឌ្ឍដោយមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋនេះ គឺដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមទីជនបទ។ វិមជ្ឈការ អាចធ្វើទៅបាន គឺអាស្រ័យទៅលើកត្តាធនធានមនុស្ស កត្តាធនធានហិរញ្ញវត្ថុ និងបទពិសោធន៍។ ដូច្នេះ ដើម្បីធ្វើឲ្យការអនុវត្តនូវការគ្រប់គ្រង មូលដ្ឋានឃុំសង្កាត់មានការទទួលខុសត្រូវដោយផ្ទាល់ក្នុងការប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួន និងបង្កលក្ខណៈឲ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានតាមបែបប្រជាធិបតេយ្យ សំដៅបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋឲ្យមានភាពល្អប្រសើរឡើង។

### ១.១.៦. ហេតុផលនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ

ប្រទេសដែលអនុវត្តតាមគោលនយោបាយវិមជ្ឈការ នឹងនាំមកនូវការរីកចម្រើនខាងផ្នែកសេដ្ឋកិច្ចយ៉ាងឆាប់រហ័សដូចជា ការកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងដោះស្រាយក្នុងការគ្រប់គ្រងឲ្យកាន់តែមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ ការផ្តល់សេវាសាធារណៈកាន់តែប្រសើរឡើង ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការទទួលខុសត្រូវផ្ទាល់នៅមូលដ្ឋាន។ វិមជ្ឈការឃុំ សង្កាត់ត្រូវបានអ្នកនយោបាយផ្តួចផ្តើមឡើង និង អនុម័តយល់ស្របអំពីកំណែទម្រង់វិមជ្ឈការនេះ រាជរដ្ឋាភិបាលបានខិតខំធ្វើកំណែទម្រង់ការគ្រប់គ្រងវិមជ្ឈការនៅឃុំសង្កាត់ដើម្បីទទួលបាននូវសមិទ្ធផលជាច្រើនដូចជា កាត់បន្ថយនូវភាពមិនអើពើចំពោះការអភិវឌ្ឍនៅក្នុងមូលដ្ឋាន ជំរុញឲ្យមានការចូលរួម និងសកម្មភាពរួបរួមផ្សេងៗរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានឲ្យកាន់តែខ្លាំងឡើង។ ពង្រឹងការឆ្លើយតបឲ្យបានឆាប់រហ័ស និងយល់ច្បាស់អំពីតម្រូវការរបស់ប្រជាពលរដ្ឋ។ បង្កើននូវលំហូរព័ត៌មានពីរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ធ្វើឲ្យគម្រោងអភិវឌ្ឍមានចីរភាព ពង្រឹងបាននូវតម្លាភាព ជំរុញការទទួលខុសត្រូវកាន់តែខ្ពស់ និងធ្វើឲ្យសម្រេចបាននូវកិច្ចការប្រឹងប្រែងថ្មីៗ ជាពិសេស ធ្វើឲ្យកម្មវិធីអភិវឌ្ឍន៍មានភាពរលូនជាងមុន កាត់បន្ថយបាននូវសកម្មភាពពុករលួយ និងពង្រឹងលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន។

## ១.២ ទិសដៅវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

### ១.២.១ ការផ្តល់ឱកាសដល់ប្រជាពលរដ្ឋឲ្យចូលរួមកាន់តែទូលំទូលាយនៅក្នុងការធ្វើសេចក្តីសម្រេចនានា

តាមរយៈប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅថ្នាក់ឃុំ សង្កាត់ ប្រជាពលរដ្ឋគ្រប់រូប(ស្ត្រី បុរស ចាស់ ក្មេង ជនងាយរងគ្រោះ) មានសិទ្ធិចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពរបស់ឃុំ សង្កាត់ និងដំណើរការនៃការអភិវឌ្ឍមូលដ្ឋាន ដូចជា ការបញ្ចេញមតិ និងការរួមចំណែកតាមមធ្យោបាយផ្សេងៗ។ ប្រជាពលរដ្ឋមានសិទ្ធិលើកឡើងអំពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ខ្លួន តាមរយៈនីតិវិធី និងយន្តការដែលបានកំណត់ក្នុងលិខិតបទដ្ឋាន និង សេចក្តីណែនាំនានា។

ប្រជាពលរដ្ឋអាចចូលរួមតាមមធ្យោបាយជាច្រើន ដូចជា ៖

- បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលពួកគាត់គិតថាអាចតំណាងឲ្យផលប្រយោជន៍របស់ពួកគាត់បានប្រសើរបំផុត
- បង្កើតទំនាក់ទំនងជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះការងារដែលពាក់ព័ន្ធនឹងការអភិវឌ្ឍឃុំ សង្កាត់
- លើកឡើងអំពីបញ្ហា និងផលប្រយោជន៍របស់ពួកគាត់ជាមួយសមាជិកក្រុមប្រឹក្សា ដើម្បីឲ្យសមាជិកក្រុមប្រឹក្សាលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ឬតាមរយៈការចាត់ចែងកិច្ចការប្រចាំថ្ងៃរបស់រដ្ឋបាលឃុំ សង្កាត់ ដោយ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ស្មៀនឃុំ សង្កាត់
- ពិនិត្យតាមដានការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដូចជាការផ្តល់សេវា ការអនុវត្តគម្រោងអភិវឌ្ឍ និងការអនុវត្តសកម្មភាពនានានៅក្នុងមូលដ្ឋានរបស់ខ្លួន
- សិទ្ធិចូលរួមទទួលបាននូវព័ត៌មានពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬប្រជាពលរដ្ឋអាចទៅកាន់សាលាឃុំ សង្កាត់ដើម្បីទទួលព័ត៌មានផ្សេងៗដែលខ្លួនចង់ដឹង។

ការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាភារកិច្ចយ៉ាងសំខាន់របស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ការចូលរួមនេះជួយឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ស្វែងយល់ពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយបង្កើតកម្មវិធីដើម្បីដោះស្រាយសេចក្តីត្រូវការទាំងនោះ។ ប្រសិនបើប្រជាពលរដ្ឋបានចូលរួម ប្រជាពលរដ្ឋមានអារម្មណ៍ថានឹងមានការទទួលខុសត្រូវចំពោះការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ខ្លួន។

### ១.២.២ ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាពរស់នៅ

វិមជ្ឈការត្រូវបានចាត់ទុកថាជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការជំរុញអភិបាលកិច្ចល្អ។ អភិបាលកិច្ចល្អ គឺជាការអនុវត្តការងារឲ្យបានសមស្របទៅនឹងទិដ្ឋភាពសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញការងារដោយអនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋាននានា។
- ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនតាមបែបលទ្ធិប្រជាធិបតេយ្យ។ ដូច្នេះអ្វីដែលក្រុមប្រឹក្សាឃុំ សង្កាត់បានសម្រេច និងអនុវត្ត គឺត្រូវទទួលខុសត្រូវយ៉ាងពេញលេញចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ នេះមានន័យថាក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ ៖
  - ធ្វើផែនការឲ្យឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ
  - ផ្តល់ព័ត៌មានពីរបៀបប្រើប្រាស់ធនធានដែលខ្លួនមាន និង
  - ធានាថាធនធានទាំងនោះពិតជាត្រូវបានប្រើប្រាស់ ដើម្បីបម្រើឲ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋប្រកបដោយតម្លាភាព និងគណនេយ្យភាព។
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានតម្លាភាពនៅក្នុងការងារទាំងអស់ដែលខ្លួនបានបំពេញ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជម្រាបជូនសាធារណជនពីកិច្ចការនានាដែលខ្លួនបានពិភាក្សា ឬពីសេចក្ដីសម្រេចដែលខ្លួនបានធ្វើ ដូចជាការផ្សព្វផ្សាយដល់សាធារណជននិងការទទួលមតិយោបល់របស់សាធារណជនអំពីការកសាងផែនការអភិវឌ្ឍន៍ និងការរៀបចំថវិកាឃុំ សង្កាត់ ការផ្សព្វផ្សាយជាសាធារណៈអំពីសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តាមរយៈការបិទផ្សាយនៅលើក្ដារខៀនព័ត៌មានឃុំ សង្កាត់ ឬតាមមធ្យោបាយផ្សេងៗទៀតនៅមូលដ្ឋាន។
- ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាសមាសធាតុយ៉ាងសំខាន់មួយទៀតនៅក្នុងអភិបាលកិច្ចល្អ។

### ១.២.៣ ការធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការផ្តល់សេវាជាមូលដ្ឋាន

ក្រុមប្រឹក្សាឃុំ សង្កាត់ស្ថិតនៅកៀកជិតប្រជាពលរដ្ឋ ហើយអាចដឹងច្បាស់អំពីសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចរៀបចំផែនការ និងកម្មវិធី ដើម្បីលើកកម្ពស់ និងកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលស្ថិតនៅក្នុង ដែនសមត្ថកិច្ចរបស់ខ្លួន។ ដូច្នេះក្រុមប្រឹក្សាឃុំសង្កាត់អាចប្រើប្រាស់ធនធានរបស់ឃុំ សង្កាត់យ៉ាងមានប្រសិទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋរបស់ខ្លួន។

ប្រជាពលរដ្ឋអាចពិនិត្យមើលការប្រើប្រាស់ធនធានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ថាតើការប្រើប្រាស់ធនធានទាំងនោះពិតជាបម្រើឲ្យផលប្រយោជន៍របស់ខ្លួនដែរឬទេ។ ប្រសិនបើប្រជាពលរដ្ឋបានចូលរួមនៅក្នុង

ដំណើរការកសាងផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងការអនុវត្តគម្រោងនានានៅមូលដ្ឋានរបស់ខ្លួននោះ នឹងធ្វើឲ្យពួកគាត់កាន់តែទទួលខុសត្រូវច្រើនថែមទៀតនៅក្នុងការអនុវត្តផែនការទាំងនោះ។

## ១.៣ តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

ផ្អែកតាមបទប្បញ្ញត្តិក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្ទេរឲ្យនូវតួនាទី មុខងារ និងអំណាចមួយចំនួនសម្រាប់បម្រើប្រជាពលរដ្ឋ និងការអភិវឌ្ឍនៅមូលដ្ឋានរបស់ខ្លួន។ រដ្ឋបាលឃុំ សង្កាត់ មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធានដែលមានប្រកបដោយចីរភាព សម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋាននៅក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍ជាតិស្របតាមគោលនយោបាយទូទៅរបស់រដ្ឋ។[7]

### ១.៣.១ អំណាចរបស់រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំសង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។

- **អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់** ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់ តាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ សម្រាប់គ្រប់គ្រងកិច្ចការនានាដែលស្ថិតក្នុងក្របខណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឲ្យ។[8] ដីកាឃុំ សង្កាត់អាចមានប្រសិទ្ធភាពអនុវត្តតែនៅក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ។ ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធឡើយ។ ប្រសិនបើដីកាណាមួយដែលផ្ទុយនឹងលិខិតបទដ្ឋានគតិយុត្តខាងលើនេះ ដីកានោះនឹងត្រូវបានចាត់ទុកជាមោឃៈដាច់ខាត។
- **អំណាចប្រតិបត្តិរបស់ឃុំ សង្កាត់** មានន័យថារដ្ឋបាលឃុំ សង្កាត់មានសិទ្ធិអនុវត្តសេចក្តីសម្រេចរបស់ខ្លួននៅក្នុងក្របខណ្ឌតួនាទីមុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឲ្យ។ អំណាចប្រតិបត្តិនេះត្រូវបានធ្វើប្រតិភូកម្មឲ្យទៅមេឃុំ ចៅសង្កាត់ ជាអ្នកអនុវត្តក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

### ១.៣.២ តួនាទី និងមុខងាររបស់រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទ គឺៈ

១. តួនាទីបម្រើកិច្ចការមូលដ្ឋានសម្រាប់បម្រើផលប្រយោជន៍ឃុំ សង្កាត់និងប្រជាពលរដ្ឋក្នុងឃុំសង្កាត់របស់ខ្លួន

[7] មាត្រា៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១។
[8] មាត្រា៤៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១។

២. តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។[9]

**ក្នុងតួនាទីបម្រើកិច្ចការមូលដ្ឋាន** រដ្ឋបាលឃុំសង្កាត់មានភារកិច្ច ៖

- ធានារក្សាសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឲ្យកិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឲ្យមានការបង្កើនផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឲ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមកបំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

**ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ** ៖ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកាសម្រាប់អនុវត្ត។ ឧទាហរណ៍ដូចជាការចុះបញ្ជីអត្រានុកូលដ្ឋាន និងការចុះឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់ជាដើម។

### ១.៣.៣ ព្រំដែននៃអំណាច

រដ្ឋបាលឃុំ សង្កាត់អាចធ្វើសកម្មភាពបានតែនៅក្នុងក្របខណ្ឌអំណាច តួនាទី និងមុខងារដែលច្បាប់បានប្រគល់ឲ្យប៉ុណ្ណោះ។ នេះមានន័យថា រដ្ឋបាលឃុំ សង្កាត់មិនអាចធ្វើសកម្មភាពណាមួយដែលផ្ទុយនឹងគោលការណ៍ និងបទប្បញ្ញត្តិដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានាឡើយ។

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសម្រេចលើវិស័យ ៖

- ព្រៃឈើ
- ប្រៃសណីយ៍ និងទូរគមនាគមន៍
- ការពារជាតិ
- សន្តិសុខជាតិ
- រូបិយវត្ថុ

[9] មាត្រា៤២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១។

- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ និង
- វិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

## ១.៤ ការរៀបចំរដ្ឋបាលឃុំ សង្កាត់

### ១.៤.១ រចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់នីមួយៗ ត្រូវមានរចនាសម្ព័ន្ធជាក់លាក់របស់ខ្លួនដោយផ្អែកតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិក៥, ៧, ៩ ឬ១១ នាក់ផ្អែកតាមភូមិសាស្រ្ត និងចំនួនប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងឃុំ សង្កាត់នោះ។[10] ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ។ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានប្រធាន ០១ រូប ដែលហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាមេឃុំ ចៅសង្កាត់។[11] ឃុំ សង្កាត់នីមួយៗមានមេឃុំ ចៅសង្កាត់ម្នាក់។ ស្រ្តី និងបុរសអាចត្រូវបានជ្រើសរើសឲ្យធ្វើជាមេឃុំ ចៅសង្កាត់ ដោយផ្អែកតាមលទ្ធផលនៃការបោះឆ្នោត។ មេឃុំ ចៅសង្កាត់មានជំនួយការ០២រូប គឺជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២។ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឲ្យមានមេភូមិម្នាក់សម្រាប់ភូមិនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួន។ មេភូមិ គឺជាតំណាងឲ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិនិងជាខ្សែរយៈចម្បងសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់។ មេភូមិត្រូវមានជំនួយការរបស់ខ្លួន០២រូបម្នាក់ជាអនុប្រធានភូមិ និងម្នាក់ទៀតជាសមាជិកភូមិ។ មេឃុំ ចៅសង្កាត់អាចចាត់តាំងបង្កើតគណៈកម្មាធិការនានាបានតាមការចាំបាច់។[12] គណៈកម្មាធិការនីមួយៗមានសមាជិកយ៉ាងតិច០៣នាក់ ដើម្បីផ្តល់យោបល់ និងជួយការងារដល់ក្រុមប្រឹក្សាឃុំសង្កាត់ និងមេឃុំ ចៅសង្កាត់អំពីបញ្ហាជាក់លាក់ណាមួយ។ គណៈកម្មាធិការនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឲ្យធ្វើជាប្រធានក៏បានឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឲ្យធ្វើជាប្រធានក៏បាន។ ឃុំ សង្កាត់នីមួយៗមានស្មៀនមួយរូបដែលត្រូវបានតែងតាំង និងបម្រើការងារនៅក្នុងក្របខ័ណ្ឌរដ្ឋបាលក្រសួងមហាផ្ទៃ។[13] ស្មៀនឃុំ សង្កាត់ ទទួលខុសត្រូវចំពោះក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងការបំពេញមុខងាររបស់ខ្លួន ស្មៀនឃុំ សង្កាត់ ត្រូវតែអព្យាក្រឹត្យ មិនលម្អៀង ហើយត្រូវប្រកាន់ឥរិយាបទឲ្យបានស្មើៗគ្នាចំពោះប្រជាពលរដ្ឋ

---

[10] មាត្រា១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១។
[11] មាត្រា២៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១។
[12] មាត្រា២៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១។
[13] មាត្រា២៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១។

ទាំងអស់នៅក្នុងឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាគ្រប់រូបដោយ មិនប្រកាន់និន្នាការនយោបាយ និងចំពោះគណៈកម្មាធិការនានា។




### ១.៤.២ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់កើតឡើងពីការបោះឆ្នោត ដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ និងមានស្វ័យភាពក្នុងការដឹកនាំ និងគ្រប់គ្រងការងារអភិវឌ្ឍមូលដ្ឋាន តែក្រុមប្រឹក្សា ឃុំ សង្កាត់ជាផ្នែកមួយនៃអំណាចនីតិប្រតិបត្តិរបស់រដ្ឋ ដែលមានន័យថា ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ គោលនយោបាយរបស់រាជរដ្ឋាភិបាល និងលិខិតបទដ្ឋានជាធរមាន។

ក្រុមប្រឹក្សាឃុំ សង្កាត់ និងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់មាន តួនាទីៈ

**ក. ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់**

- ធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ធានាថា ក្រុមប្រឹក្សាឃុំ សង្កាត់បានប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ

- ធានាថា កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានធ្វើឡើងស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំក្រុមប្រឹក្សាឃុំសង្កាត់។[14]

**ខ. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់**

- ធានាថាក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់អំណាចតួនាទី និងមុខងារដូចមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ
- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសហប្រតិបត្តិការជាមួយនឹងប្រជាពលរដ្ឋ។

**គ. មេឃុំ ចៅសង្កាត់**

- ធានាថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្ត
- រាយការណ៍អំពីការបំពេញការងារប្រចាំខែជូនក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើការងារកសាងផែនការ ការងារថវិកា ហិរញ្ញវត្ថុ និងការអនុវត្តអំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- បំពេញភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឲ្យ
- ផ្ទេរសិទ្ធិដល់ជំទប់ ចៅសង្កាត់រងតាមឋានុក្រមពេលខ្លួនអវត្តមាន។

**ឃ. ជំទប់ទី១ ចៅសង្កាត់រងទី១**

- ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំចៅសង្កាត់អវត្តមាន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ ចៅសង្កាត់។

**ង. ជំទប់ទី២ ចៅសង្កាត់រងទី២**

- ជួយមេឃុំ ចៅសង្កាត់លើការងារផ្នែករដ្ឋបាលសេវាសង្គមកិច្ច សេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំចៅសង្កាត់ និងជំទប់ទី១ ចៅសង្កាត់រងទី១ អវត្តមាន។
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ ចៅសង្កាត់។

[14] មាត្រា១៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១។

**ច. គណៈកម្មាធិការនានា**

- ផ្តល់យោបល់ និងជួយការងារជាក់លាក់ណាមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដូចជាការកសាងផែនការ និងថវិកា
- រាយការណ៍អំពីការវិវឌ្ឍការងារប្រចាំខែរបស់ខ្លួន
- ផ្តល់យោបល់ពីវិធានការត្រូវអនុវត្តដែលពាក់ព័ន្ធទៅនឹងការងារជាសមត្ថកិច្ចរបស់ខ្លួន។

**ឆ. ស្មៀនឃុំ សង្កាត់**

ថ្វីត្បិតតែស្មៀនឃុំ សង្កាត់ជាបុគ្គលិកស្ថិតនៅក្នុងក្របខណ្ឌរដ្ឋបាលស៊ីវិលរបស់ក្រសួងមហាផ្ទៃក៏ពិតមែន ប៉ុន្តែក្នុងការអនុវត្តការងារស្មៀនឃុំ សង្កាត់ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់ជាអ្នក ៖

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងនិងគណៈកម្មាធិការនានាបំពេញតួនាទី និងមុខងារស្របទៅតាមតម្រូវការផ្នែកច្បាប់
- បំពេញការងាររដ្ឋបាល
- ធានាថាសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ស្របទៅនឹងលក្ខខណ្ឌច្បាប់
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និងការអនុវត្តកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ឃុំ សង្កាត់
- ចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬគណៈកម្មាធិការ លើកលែងតែបានទទួលការអនុញ្ញាតឲ្យអវត្តមានជាមុនពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់
- ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំឲ្យមានក្តារខៀនព័ត៌មានមួយឬច្រើនកន្លែង ដើម្បីបិទផ្សាយសេចក្តីជូនដំណឹង សេចក្តីសម្រេច និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រុមប្រឹក្សាឃុំសង្កាត់ និងមេឃុំ ចៅសង្កាត់សម្រាប់ឲ្យសាធារណជនទូទៅបានដឹងនូវព័ត៌មានទាំងនោះ។

**ជ. បុគ្គលិកឃុំ សង្កាត់**

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខណ្ឌរដ្ឋ ដើម្បីជួយកិច្ចការរបស់ខ្លួន តាមសេចក្តីត្រូវការ និងការចាំបាច់នៃការងារ និងតាមសេចក្តីសម្រេចរបស់ ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់។[15] បែបបទនៃការជ្រើសរើសបុគ្គលិកឃុំ សង្កាត់មានបរិយាយនៅក្នុងសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់។

[15] មាត្រា២៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១។

## ឈ. មេភូមិ និងជំនួយការមេភូមិ

### ឈ.១. មេភូមិ

- ទទួលខុសត្រូវរួមក្នុងភូមិរបស់ខ្លួន
- តំណាងឲ្យប្រជាពលរដ្ឋទាំងអស់ក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់ភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំសង្កាត់
- បង្កើនការពិគ្រោះយោបល់ ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ឃុំ សង្កាត់នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវ ដើម្បីផ្តល់យោបល់អំពីកិច្ចការដែលពាក់ព័ន្ធក្នុងភូមិរបស់ខ្លួនមានជាអាទិ៍៖
  - ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីតម្រូវការ និងផលប្រយោជន៍របស់ភូមិ
  - ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីរបៀបបង្កើន និងកសាងសមត្ថភាព និងធនធានរបស់ភូមិ
  - ផ្តល់យោបល់ដល់គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំសង្កាត់អំពី ៖
    - តម្រូវការ និងអាទិភាពរបស់ភូមិ ដើម្បីបញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
    - ការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន
    - ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំសង្កាត់ក្នុងភូមិរបស់ខ្លួន។
- ត្រូវធ្វើសេចក្តីរាយការណ៍រាល់បញ្ហាពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ត្រូវចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ សង្កាត់
- ត្រូវធានាផ្តល់ព័ត៌មានជាឯកសារជាសាធារណៈដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួនជូនដល់ប្រជាពលរដ្ឋរបស់ខ្លួន។ ឯកសារព័ត៌មានទាំងនោះអាចរួមមានព័ត៌មានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍ និងថវិកាឃុំ សង្កាត់
- ត្រូវទទួលខុសត្រូវអនុវត្តកិច្ចការដែលបានប្រគល់ឲ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

**បញ្ជាក់ ៖**

- មេភូមិមិនមានសិទ្ធិអំណាចចុះហត្ថលេខាលើកិច្ចសន្យា ឬការផ្ទេរអំណាច ឬការចាត់ចែងដទៃទៀតក្នុងនាមភូមិបានឡើយ។

- មេភូមិពុំមានសិទ្ធិអំណាចសម្រេចបញ្ហាណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយគ្មានការផ្ទេរអំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ស្របតាមប្រកាសរបស់ក្រសួងមហាផ្ទៃបានឡើយ។
- ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចផ្ទេរអំណាចដល់បុគ្គល ឬគណៈកម្មាធិការ ឬអង្គការណាមួយនៅក្នុងភូមិបានឡើយ លើកលែងតែមានការអនុញ្ញាតដែលបានចែងក្នុងប្រកាសរបស់ក្រសួងមហាផ្ទៃ។

**ឈ.២. ជំនួយការមេភូមិ**

• **អនុប្រធានភូមិ** ទទួលការងារជំនួសមេភូមិក្នុងពេលដែលមេភូមិអវត្តមាន ដោយមានមូលហេតុច្បាស់លាស់ ដូចជាមានជំងឺ ឬមានបេសកកម្មចេញក្រៅឃុំ សង្កាត់របស់ខ្លួនលើសពី១ថ្ងៃ។ ក្រៅពីនេះអនុប្រធានភូមិត្រូវទទួលជួយមេភូមិលើការអនុវត្តគម្រោងអភិវឌ្ឍន៍នានា ក្នុងភូមិតាមគម្រោងផែនការរបស់ឃុំ សង្កាត់។

• **សមាជិកភូមិ** ទទួលជួយធ្វើជាលេខាធិការឲ្យមេភូមិ និងទទួលជួយមេភូមិលើការងារស្ថិតិ ការចុះបញ្ជីប្រជាពលរដ្ឋ និងការរក្សាទុកឯកសារនានារបស់ភូមិ។

ក្រៅពីការងារខាងលើនេះមេភូមិអាចធ្វើការបែងចែក ឬប្រគល់ភារកិច្ចដល់អនុប្រធានភូមិ និងសមាជិកភូមិតាមការចាំបាច់ និងធ្វើសេចក្តីរាយការណ៍ជូនមេឃុំ ចៅសង្កាត់សាមី។

## ១.៥ កិច្ចការរដ្ឋបាលឃុំ សង្កាត់

### ១.៥.១ ការគ្រប់គ្រងទ្រព្យសម្បត្តិ

ទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់មាន៣ប្រភេទគឺ ទ្រព្យសម្បត្តិដែលរាជរដ្ឋាភិបាលផ្ទេរសិទ្ធិឲ្យកាន់កាប់ ទ្រព្យសម្បត្តិដែលឃុំ សង្កាត់ទិញដោយខ្លួនឯងផ្ទាល់ និងទ្រព្យសម្បត្តិដែលបានមកពីអំណោយនានា។

**ការកត់ត្រាចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ** ទ្រព្យសម្បត្តិ និងសម្ភារៈបរិក្ខារទាំងអស់របស់ឃុំ សង្កាត់ត្រូវចុះបញ្ជីឲ្យបានត្រឹមត្រូវ ។ បញ្ជីសារពើភ័ណ្ឌគ្រប់គ្រងទ្រព្យសម្បត្តិ និងសម្ភារៈបរិក្ខារនេះត្រូវរក្សាទុកឲ្យបានល្អប្រកបដោយសុវត្ថិភាព និងធ្វើបច្ចុប្បន្នភាពយ៉ាងតិចក្នុងរយៈពេលមួយឆ្នាំម្តង។ ការកត់ត្រាទ្រព្យសម្បត្តិត្រូវបញ្ចូលព័ត៌មានដូចជា លេខរៀង ឬលេខកូដ យថាប្រភេទ កាលបរិច្ឆេទផ្ទេរសិទ្ធិកាន់កាប់ បរិមាណ និងតម្លៃទីតាំងដែលទ្រព្យសម្បត្តិនោះទុកដាក់ ឬប្រើប្រាស់។[16]

**ការលក់ដូរ និងការផ្ទេរកម្មសិទ្ធិទ្រព្យសម្បត្តិ** ឃុំ សង្កាត់ពុំមានសិទ្ធិក្នុងការលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិ ដែលរាជរដ្ឋាភិបាលប្រគល់ឲ្យដោយគ្មានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឡើយ។ ប៉ុន្តែឃុំ សង្កាត់អាចធ្វើការលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិដែលបានមកពីអំណោយបាន ដោយគោរពទៅតាម

[16] មាត្រា៥០ នៃអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

លក្ខខណ្ឌដែលបានព្រមព្រៀងរវាងម្ចាស់អំណោយ និងឃុំ សង្កាត់។ សម្រាប់ទ្រព្យសម្បត្តិដែលឃុំ សង្កាត់ទិញដោយខ្លួនឯងផ្ទាល់ និងទ្រព្យសម្បត្តិផ្សេងទៀតដែលជាអំណោយគ្មានលក្ខខណ្ឌ ការលក់ដូរ ឬការផ្ទេរកម្មសិទ្ធិ ឬការផ្ទេរការប្រើប្រាស់ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- មេឃុំ ចៅសង្កាត់ ត្រូវតែបង្កើតគណៈកម្មការចំពោះកិច្ចមួយដើម្បីត្រួតពិនិត្យលើ ការលក់ដូរ ឬ ផ្ទេរទ្រព្យសម្បត្តិ។ គណៈកម្មការនេះត្រូវដឹកនាំដោយមេឃុំចៅសង្កាត់ និងមានសមាជិកក្រុមប្រឹក្សា០១រូប និង០១រូបទៀតជាគណនេយ្យករឃុំ សង្កាត់នៅរតនាគារខេត្តក្រុង ស្មៀនឃុំ សង្កាត់ត្រូវធ្វើជាលេខាធិការ។
- ដំណើរការលក់ដូរ ឬផ្ទេរ ត្រូវធានាឲ្យមានតម្លាភាព និងបើកទូលាយឲ្យមានការប្រគួតប្រជែងគ្នា។
- ក្នុងការលក់ដូរ ឬផ្ទេរ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវសម្រេចតាមអនុសាសន៍របស់គណៈកម្មការចំពោះកិច្ច។
- ទឹកប្រាក់បានមកពីការលក់ទ្រព្យសម្បត្តិត្រូវរក្សាទុកក្នុងគណនីឃុំ សង្កាត់នៅរតនាគារខេត្តក្រុង។[17]

### ១.៥.២ ការគ្រប់គ្រងឯកសារឃុំ សង្កាត់

ឃុំ សង្កាត់ គឺជាម្ចាស់លើរាល់លិខិត និងឯកសារដែលរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ឬក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ និងជាម្ចាស់កម្មសិទ្ធិលើតែមប្រ៊ី ត្រា ឃុំ សង្កាត់ព្រមទាំងឧបករណ៍ផ្សេងៗទៀតរបស់ឃុំសង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាថាទុកដាក់ឯកសារ លិខិតស្នាម តែមប្រ៊ី ត្រា ឲ្យបានត្រឹមត្រូវ និង គង់វង្ស ។ ការគ្រប់គ្រងឯកសារ គឺជាការរៀបចំទុកដាក់ និងថែរក្សាឯកសារទាំងឡាយតាមប្រព័ន្ធមួយ មានសណ្តាប់ធ្នាប់ និងសុវត្ថិភាព។

ផលប្រយោជន៍នៃការគ្រប់គ្រងឯកសារនឹងផ្តល់នូវប្រយោជន៍មួយចំនួនដូចជា ៖

- បង្កលក្ខណៈងាយស្រួលក្នុងការស្វែងរកព័ត៌មាន និងទិន្នន័យសម្រាប់ដឹកនាំនៅក្នុងការពិភាក្សា និងការធ្វើសេចក្តីសម្រេច
- ជួយបន្តនិរន្តរភាពព័ត៌មាន នៅពេលមានអ្នកមកកាន់ការងារថ្មី និងអ្នកផ្លាស់ចេញ
- ផ្តល់នូវភស្តុតាងជាក់លាក់ពីកិច្ចការ ឬព្រឹត្តិការណ៍ដែលកើតរួចមកហើយ
- បង្កើនប្រសិទ្ធភាព និងសន្សំពេលវេលាដល់ការងាររដ្ឋបាលឃុំសង្កាត់។

ជាទូទៅ ឯកសារឃុំ សង្កាត់ មាន២ប្រភេទ គឺឯកសារផ្ទៃក្នុង និងឯកសារសាធារណៈ ។ ឯកសារផ្ទៃក្នុងគឺជាឯកសារទាំងឡាយណាដែលត្រូវបានប្រើប្រាស់ និងផ្សព្វផ្សាយសម្រាប់តែផ្ទៃក្នុងរបស់រដ្ឋបាលឃុំ សង្កាត់ និងបុគ្គលពាក់ព័ន្ធផ្ទាល់ប៉ុណ្ណោះ។ ឧទាហរណ៍៖ របាយការណ៍ស៊ើបអង្កេត ឯកសារអគ្រានុកូលដ្ឋាន..។ល។

[17] មាត្រា៥៣ នៃអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

ឯកសារសាធារណៈ គឺជាឯកសារទាំងឡាយណាដែលត្រូវបានប្រើប្រាស់ និងផ្សព្វផ្សាយសម្រាប់សាធារណជនទូទៅ។ ឧទាហរណ៍ ៖ ផែនការអភិវឌ្ឍន៍ ,កម្មវិធីវិនិយោគបីឆ្នាំរំកិល ,របាយការណ៍ហិរញ្ញវត្ថុ..។ល។

## ១.៦. ប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំអនុម័ត និងអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្នុងគោលបំណងកំណត់នូវទស្សនវិស័យកម្មវិធី និងកិច្ចអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន។ ផែនការឃុំ សង្កាត់រួមមានផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។[18]

### ១.៦.១. អត្ថន័យនៃផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

#### ក. ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់មានរយៈពេលប្រាំឆ្នាំ ដូចអាណត្តិក្រុមប្រឹក្សាដែរ។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលឃុំ សង្កាត់ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហាតម្រូវការ និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយបញ្ហាទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋឲ្យមានប្រសិទ្ធភាព។

#### ខ. កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ គឺជាការធ្វើឲ្យខ្លឹមសារនៃផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ទៅជាគម្រោងសកម្មភាព ឬសេវាកម្មជាក់ស្តែង ដោយមានភ្ជាប់នូវចំណាយមូលនិធិ សំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍន៍សម្រាប់រយៈពេលបីឆ្នាំ។ កម្មវិធីវិនិយោគនេះត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

### ១.៦.២ គោលការណ៍សំខាន់ៗនៃការកសាងផែនការឃុំ សង្កាត់

ការកសាងផែនការឃុំ សង្កាត់ត្រូវផ្អែកតាមគោលការណ៍សំខាន់ៗដូចខាងក្រោម ៖

- ការចែករំលែកព័ត៌មាន ៖ ក្នុងដំណើរការកសាងផែនការត្រូវមានការចែករំលែកព័ត៌មានរវាងរដ្ឋបាលថ្នាក់ផ្សេងៗគ្នារវាងប្រជាពលរដ្ឋរវាងការិយាល័យ អង្គភាព អង្គការជាតិ អន្តរជាតិ និងដៃគូនានាព្រមទាំងវិស័យឯកជន ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។
- តម្លាភាព ៖ ការកសាងផែនការត្រូវធ្វើឡើងស្របតាមបែបបទនីតិវិធី គោលការណ៍ណែនាំ មិនមានការលាក់លៀម គ្រប់អ្នកពាក់ព័ន្ធបានចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនានា ហើយព័ត៌មានជុំវិញការធ្វើសេចក្តីសម្រេចចិត្តនេះ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ។
- សង្គតិភាព និងសុខដុមនីយកម្ម ៖ ផែនការត្រូវរៀបចំឡើងមានលំដាប់លំដោយត្រឹមត្រូវ ស៊ីសង្វាក់ និងមានលក្ខណៈសមស្របសម្រាប់គ្រប់អ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចក្រុមប្រឹក្សាឃុំសង្កាត់។ ផែនការ

[18] មាត្រា៦០ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ឃុំ សង្កាត់ត្រូវស្របទៅនឹងគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការអភិវឌ្ឍន៍រាជធានីខេត្ត និងផែនការអភិវឌ្ឍន៍ក្រុង ស្រុក។

- ការចូលរួមពិគ្រោះយោបល់ជាទូទៅ ៖ ក្នុងដំណើរការកសាងផែនការ ត្រូវមានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។
- ការឆ្លើយតបនឹងតម្រូវការ ៖ ផែនការឃុំ សង្កាត់ ពិសេសចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រអភិវឌ្ឍ ឬគម្រោងវិនិយោគត្រូវតែឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។
- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ៖ នៅក្នុងដំណើរការនៃការកសាងនិងអនុវត្តផែនការត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចក្រុមប្រឹក្សា ដោយក្រុមប្រឹក្សា និងគណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់ត្រូវធ្វើសេចក្ដីសម្រេចអំពីការអភិវឌ្ឍមូលដ្ឋានដោយឈរលើតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ និងត្រូវផ្ដល់ព័ត៌មានជូនប្រជាពលរដ្ឋអំពីហេតុផល នៃការធ្វើសេចក្ដីសម្រេចរបស់ខ្លួនចំពោះការអភិវឌ្ឍមូលដ្ឋានទាំងនោះ ព្រមទាំងទទួលខុសត្រូវចំពោះប្រជាពលរដ្ឋអំពីការសម្រេចរបស់ខ្លួន រួមទាំងផលវិបាកដែលកើតឡើងពីការសម្រេចទាំងនេះ។
- ប្រសិទ្ធភាព និងសុក្រឹតភាពសេដ្ឋកិច្ច និងសង្គម ៖ ក្នុងដំណើរការកសាង និងអនុវត្តផែនការត្រូវធានានូវប្រសិទ្ធភាព និងត្រូវចូលរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ ដើម្បីធានាឲ្យមានប្រសិទ្ធភាព ចាំបាច់ត្រូវកំណត់ឲ្យបាននូវតម្រូវការដែលមានអាទិភាពខ្ពស់បំផុត និងត្រូវសម្រេចប្រើប្រាស់ធនធានសម្រាប់ឆ្លើយតបចំពោះតម្រូវការជាអាទិភាពទាំងនេះ ប្រកបដោយការសន្សំសំចៃខ្ពស់ ដោយត្រូវធ្វើយ៉ាងណាឲ្យការចំណាយតិចបំផុត និងទទួលផលបានច្រើនបំផុតតាមដែលអាចធ្វើបាន។
- ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន ៖ ក្នុងដំណើរការកសាង និងអនុវត្តផែនការឃុំ សង្កាត់ត្រូវចូលរួមចំណែកក្នុងការការពារធនធានធម្មជាតិ និងបរិស្ថាន សំដៅធានាបាននូវនិរន្តរភាពធនធានធម្មជាតិ និងបរិស្ថាន ពោលគឺមិនបង្កឲ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ធនធានធម្មជាតិ និងបរិស្ថានក្នុងឃុំ សង្កាត់ឡើយ។
- ការធានាសមធម៌ ៖ ក្នុងដំណើរការកសាង និងអនុវត្តផែនការឃុំ សង្កាត់ត្រូវធានាឲ្យមានការចូលរួម និងផ្ដល់ផលប្រយោជន៍ដល់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ពិសេសស្ត្រី កុមារ ជនក្រីក្រ ជនពិការក្រុមជនភាគតិច និងជនងាយរងគ្រោះដែលមាននៅក្នុងឃុំ សង្កាត់។

### ១.៦.៣. តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ

យន្តការ ដែលទទួលខុសត្រូវក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ គឺ ៖

**ក. ក្រុមប្រឹក្សាឃុំ សង្កាត់**

- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដោយធានាឲ្យមានភាពគ្រប់ជ្រុងជ្រោយ និង ឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋពិសេស ស្ត្រី កុមារ ជនពិការ យុវជន និងជនងាយរងគ្រោះ ជាដើម។
- ពិនិត្យ និងអនុម័តរាល់ការធ្វើវិសោធនកម្មផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- តាមដាន និងវាយតម្លៃអំពីលទ្ធផលនៃការសម្រេចបាននូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**ខ. មេឃុំ ចៅសង្កាត់**

- ដឹកនាំការប្រមូលទិន្នន័យភូមិ ឃុំ សង្កាត់
- ដឹកនាំការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ដាក់សេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិនិត្យ និងអនុម័ត។

**គ. គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់**(គ.ផ.ថ)

- ជួយមេឃុំ ចៅសង្កាត់ ក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដោយអនុវត្តតាមបែបបទនីតិវិធីដូចមានកំណត់ក្នុងសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ឃុំសង្កាត់ និងសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ និងសង្កាត់។

យន្តការទាំងបីខាងលើ គឺជាយន្តការស្នូលក្នុងការចូលរួម និងទទួលខុសត្រូវផ្ទាល់លើការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។ ដើម្បីធានាឲ្យផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់មានគុណភាព ចាំបាច់ត្រូវមានយន្តការគាំទ្រ ដែលរួមមាន ៖

**ឃ. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់**(គ.ក.ន.ក)

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការប្រមូល វិភាគព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងបញ្ហា តម្រូវការរបស់នារី និងកុមារ ដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

- ទាក់ទាញ ការគាំទ្រ ដើម្បីឲ្យអ្នកពាក់ព័ន្ធនានា ពិសេសស្ត្រីជនពិការ យុវវ័យ និងជនងាយរងគ្រោះនានា បានចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការអភិវឌ្ឍមូលដ្ឋាន
- ចូលរួមផ្តល់ព័ត៌មាន និងជំរុញឲ្យមានការយកចិត្តទុកដាក់លើបញ្ហាស្ត្រី កុមារ និងជនងាយរងគ្រោះនានាដែលមានក្នុងដែនសមត្ថកិច្ចខ្លួននៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- សហការបំពេញការងារតាមសំណូមពរពីគ.ផ.ថ ដើម្បីកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**ខ. មន្ទីរផែនការរាជធានី ខេត្ត**

- គាំទ្របច្ចេកទេសកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដូចជា ការងារស្រង់ទិន្នន័យពីមូលដ្ឋានភូមិឃុំ សង្កាត់ ការងារចងក្រងកម្រងព័ត៌មានស្ថានភាពឃុំ សង្កាត់ប្រចាំឆ្នាំ ឯកសារពិន្ទុវិស័យ និងព័ត៌មានផ្សេងៗទៀត។
- សហការជាមួយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្តនិងទីចាត់ការផែនការនិងវិនិយោគរាជធានីខេត្តក្នុងការបណ្តុះបណ្តាលអំពីបច្ចេកទេសកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនយោគបីឆ្នាំរំកិលឃុំ សង្កាត់ ការប្រើប្រាស់ទិន្នន័យ និងបច្ចេកទេស តាមដាន និងវាយតម្លៃលទ្ធផលអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។
- សហការផ្តល់ការគាំទ្របច្ចេកទេសអំពីការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងការតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀននិងបុគ្គលិកសំខាន់ៗរបស់ឃុំ សង្កាត់ តាមសំណើរពីអ្នកពាក់ព័ន្ធ។

**ច. ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត**

- ផ្តល់ការបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គ.ផ.ថ និងអ្នកពាក់ព័ន្ធអំពីនីតិវិធីកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដោយមានកិច្ចសហការជាមួយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត មន្ទីរផែនការរាជធានី ខេត្ត ឬអង្គភាពជំនាញ ក្នុងករណីចាំបាច់
- ជំរុញ និងគាំទ្រការប្រមូល និងរក្សាសៀវភៅផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ទុកជាឯកសារ
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំនិងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ តាមដាន និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**ឆ. ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ឬការិយាល័យផែនការ និងអភិវឌ្ឍន៍**

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការវិភាគ វាយតម្លៃ និងរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ជួយទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត ដើម្បីពិនិត្យនិងលើកយោបល់ជូនអភិបាលរាជធានី ខេត្ត អំពីការធ្វើអនុលោមភាពផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- ជួយអភិបាលក្រុង (សង្កាត់ក្នុងក្រុង) អំពីការធ្វើអនុលោមភាពផែនការអភិវឌ្ឍន៍សង្កាត់សម្របសម្រួល និងប្រមូលឯកសារ ដើម្បីបញ្ជូនទៅអង្គភាពពាក់ព័ន្ធ
- សិក្សា វាយតម្លៃ និងលើកយោបល់អំពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងតម្រូវការគាំទ្រនានា
- ជួយក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ សង្កាត់
- គាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំការកសាង និងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**ជ. ការិយាល័យផែនការក្រុង ស្រុក ខណ្ឌ**

- ជួយសម្របសម្រួល និងជំរុញអាជ្ញាធរភូមិ ឃុំ សង្កាត់ ក្នុងការស្រង់ទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់
- ជួយ គ.ផ.ថ ក្នុងការវិភាគព័ត៌មានស្ថានភាព និងពិន្ទុវិស័យទិន្នន័យភូមិ ឃុំ សង្កាត់។

**ឈ. មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធនានាថ្នាក់រាជធានី ខេត្ត**

- ទទួលខុសត្រូវផ្តល់ជំនួយបច្ចេកទេសដែលពាក់ព័ន្ធនឹងជំនាញរបស់ខ្លួនដល់ការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ដូចជា យេនឌ័រ ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងអាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដែលសល់ពីសង្គ្រាម ពិការភាព។ល។

**ញ. អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា**

- ចូលរួមជាតំណាងឲ្យផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធណាមួយជាក់លាក់ ដូចជាតំណាងឲ្យស្ត្រី កុមារយុវជន ជនក្រីក្រ ជនជាតិដើមភាគតិច។ល។
- ចូលរួមផ្តល់ចំណេះដឹង និងគំនិតផ្សេងៗក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ចូលរួមក្នុងការពិភាក្សា និងពិគ្រោះយោបល់នានាដែលពាក់ព័ន្ធនឹងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

**ឌ. ប្រជាពលរដ្ឋ**

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ត្រូវចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីកំណត់បញ្ហា និងតម្រូវការអាទិភាពនានាក្នុងសហគមន៍ និងមូលដ្ឋានខ្លួនទៅតាមស្ថានភាពជាក់ស្តែងរបស់សាមីខ្លួននីមួយៗ។

# ជំពូកទី ២
# ដំណើរការគ្រប់គ្រងរដ្ឋបាល
# សង្កាត់កោះអន្លង់ចិន (ខេត្តកណ្ដាល)

# ជំពូកទី ២

# ដំណើរការគ្រប់គ្រងរដ្ឋបាលសង្កាត់កោះអន្លង់ចិន (ខេត្តកណ្ដាល)

## ២.១. ស្ថានភាពទូទៅ

### ២.១.១. ស្ថានភាពភូមិសាស្ត្រ

សង្កាត់កោះអន្លង់ចិន ជាសង្កាត់មួយក្នុងចំណោមសង្កាត់ទាំង១០ នៃក្រុងតាខ្មៅ ខេត្តកណ្ដាល មានភូមិសាស្ត្រជាកោះមួយដែលមានទន្លេបាសាក់ព័ទ្ធជុំវិញ។ សង្កាត់កោះអន្លង់ចិនមានផ្ទៃដីសង្កាត់មាន៨២៨០០ គីឡូម៉ែត្រការ៉េ (២០២០) ហើយលក្ខខណ្ឌភូមិសាស្ត្រនេះបានផ្ដល់នូវដីមានជីវជាតិសម្រាប់ប្រជាពលរដ្ឋធ្វើកសិកម្មគ្រប់ប្រភេទ ដែលជាប្រភពចំណូលចម្បងក្នុងការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ។[19] សង្កាត់កោះអន្លង់ចិនមានភូមិចំនួន៤ គឺ ភូមិក្បាលកោះ ភូមិកណ្ដាលកោះ ភូមិស្វាយពុំត្រង់ និងភូមិចុងកោះ។

**សង្កាត់កោះអន្លង់ចិនមានព្រំប្រទល់៖**

- ខាងកើតជាប់នឹងទន្លេបាសាក់ ឃុំកំពង់ស្វាយ (ស្រុកកៀនស្វាយ)
- ខាងលិចជាប់នឹងទន្លេបាសាក់ សង្កាត់សិត្បូ (ក្រុងតាខ្មៅ)
- ខាងត្បូងជាប់នឹងទន្លេបាសាក សង្កាត់ស្វាយរលំ (ឃុំសិត្បូ ក្រុងតាខ្មៅ)
- ខាងជើងជាប់នឹងទន្លេបាសាក់ ឃុំឈើទាល (ស្រុកកៀនស្វាយ)។

### ២.១.២. ស្ថានភាពប្រជាសាស្ត្រ

សង្កាត់កោះអន្លង់ចិន មានប្រជាជនសរុបចំនួន ៧,៣២៣នាក់ និងមានប្រជាពលរដ្ឋរស់នៅសរុបចំនួន ១,៥៥២គ្រួសារ ដែលក្នុងនោះចំនួនស្រីមានចំនួន ៣,៥៤៤នាក់ និងប្រុសមានចំនួន ៤,៦៣៣នាក់ ។ ប្រជាពលរដ្ឋដែលមានអាយុចាប់ពី ០ឆ្នាំ ដល់ ១៧ឆ្នាំ មានចំនួន ២៧,៦៦នាក់ ប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៦០ឆ្នាំ មានចំនួន ៤,៤២១នាក់ ប្រជាពលរដ្ឋដែលមានអាយុចាប់ពី ៦១ឆ្នាំឡើងទៅមានចំនួន ៩៩០ នាក់ មេគ្រួសារជាស្ត្រីមានចំនួន ១០.៣% កំណើនប្រជាពលរដ្ឋប្រចាំឆ្នាំ ១១.០% អត្រាភាពក្រីក្រ ១០.៦៨%។[20] ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតមានចំនួនសរុប ៤,០៥០នាក់។ ការប្រកបមុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់កោះអន្លង់ចិនភាគច្រើនគឺធ្វើកសិកម្មដាំដុះស្រូវនៅរដូវវស្សា បើគិតជាតួលេខ មុខរបរកសិកម្មជាចម្បងមានចំនួន ៨២.៥% មុខរបរផ្នែកសេវាកម្មជាចម្បងមានចំនួន ១៧.៤% និងមុខរបរចម្បងផ្នែកសិប្បកម្មមានចំនួន ០.១%។ ប្រជាពលរដ្ឋនៅក្នុងសង្កាត់នេះក៏មានអ្នកទៅរកការងារធ្វើនៅក្នុងប្រទេសមានចំនួន ៦៩% និងមានអ្នកទៅរកការងារធ្វើនៅក្រៅប្រទេសមានចំនួន ៣១%។

[19] របាយការណ៍សង្កាត់កោះអន្លង់ចិន ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១។

[20] កម្មវិធីវិនិយោគ៣ឆ្នាំរំកិលសង្កាត់កោះអន្លង់ចិន (២០២១-២០២៣)។

## ២.២. ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលសង្កាត់កោះអន្លង់ចិន

### ២.២.១. សមាសភាពក្រុមប្រឹក្សាសង្កាត់

យោងតាមប្រកាសរបស់ប្រសួងមហាផ្ទៃ ស្តីពិការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សា ចៅសង្កាត់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាសង្កាត់ នៃសង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល ក្រុមប្រឹក្សាសង្កាត់កោះអន្លង់ចិន នៅអាណត្តិទី៤ (២០១៧-២០២២) នេះមានសមាសភាព ៧រូប ដូចមានរាយនាមខាងក្រោម៖

១. លោក ជ្រឹង ជ្រឿង ជាប្រធានក្រុមប្រឹក្សា និងជាចៅសង្កាត់

២. លោក ជា គឹមហួន ជាសមាជិកក្រុមប្រឹក្សា និងជាចៅសង្កាត់រងទី១

៣. លោក ប៉ូ ឆាង ជាសមាជិកក្រុមប្រឹក្សា និងជាចៅសង្កាត់រងទី២

៤. លោកស្រី អាត សាម៉ីឌី ជាសមាជិកក្រុមប្រឹក្សាសង្កាត់

៥. លោក សួង ថន ជាសមាជិកក្រុមប្រឹក្សាសង្កាត់

៦. លោកស្រី ផៃ សុភារី ជាសមាជិកក្រុមប្រឹក្សាសង្កាត់

៧. លោក យឿន យ៉ុង ជាសមាជិកក្រុមប្រឹក្សាសង្កាត់។

យោងតាមប្រកាសដដែលទទួលស្គាល់សមាសភាពជាចៅសង្កាត់ ចៅសង្កាត់រងទី១ និងចៅសង្កាត់រងទី២ នៃសង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម៖

១. លោក ជ្រឹង ជ្រឿង ជាចៅសង្កាត់

២. លោក ជា គឹមហួន ជាចៅសង្កាត់រងទី១

៣. លោក ប៉ូ ឆាង ជាចៅសង្កាត់រងទី២។

### ២.២.២. គណៈកម្មាធិការនានារបស់សង្កាត់

#### ក. គណៈកម្មាធិការកសាងផែនការ និងថវិកា

គណៈកម្មាធិការកសាងផែនការ និងថវិកាសង្កាត់កោះអន្លង់ចិន មានសមាសភាពចំនួន ១៧រូប[21] ដឹកនាំដោយប្រធាន ១រូប ជាចៅសង្កាត់ និងមានសមាជិកចំនួន ១៦រូប ទៀត ដែលមានរាយនាមដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | លោក | **ជ្រឹង ជ្រឿង** | ប្រធានក្រុមប្រឹក្សាសង្កាត់ | ប្រធាន |
| ២. | លោក | **ជា គឹមហួន** | ចៅសង្កាត់រងទី១ | សមាជិកអចិន្ត្រៃយ៍ |
| ៣. | លោក | **ប៉ូ ឆាង** | ចៅសង្កាត់រងទី២ | សមាជិក |
| ៤. | លោកស្រី | **អាត សាម៉ីឌី** | សមាជិកក្រុមប្រឹក្សាសង្កាត់ | សមាជិក |
| ៥. | លោក | **ឯម សុខា** | មេភូមិក្បាលកោះ | សមាជិក |

[21] សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកាសង្កាត់កោះអន្លង់ចិន ថ្ងៃទី១២ ខែមករា ឆ្នាំ២០២១

| | | | | |
|---|---|---|---|---|
| ៦. | លោកស្រី | **ភេ ផាត** | អនុប្រធានភូមិក្បាលកោះ | សមាជិក |
| ៧. | លោក | **ជី សំអូន** | សមាជិកភូមិក្បាលកោះ | សមាជិក |
| ៨. | លោក | **សយ ណាន** | មេភូមិកណ្តាលកោះ | សមាជិក |
| ៩. | លោក | **លឹម គង់** | អនុប្រធានភូមិកណ្តាលកោះ | សមាជិក |
| ១០. | កញ្ញា | **ចាយ ផល្លា** | សមាជិកភូមិកណ្តាលកោះ | សមាជិក |
| ១១. | លោក | **ផេង គីម** | មេភូមិស្វាយពុំត្រង់ | សមាជិក |
| ១២. | លោកស្រី | **ប៉ោក គៀង** | អនុប្រធានភូមិស្វាយពុំត្រង់ | សមាជិក |
| ១៣. | លោក | **ទូច ព្រហ្ម** | តំណាងប្រជាពលរដ្ឋភូមិកណ្តាលកោះ | សមាជិក |
| ១៤. | លោក | **ម៉ម ភីនី** | មេភូមិចុងកោះ | សមាជិក |
| ១៥. | លោក | **អ៊ុំ អេម** | អនុភូមិចុងកោះ | សមាជិក |
| ១៦. | លោកស្រី | **សុខ ដាវី** | សមាជិកភូមិចុងកោះ | សមាជិក |
| ១៧. | លោក | **គាំ ចាន់កុសល** | ស្មៀនសង្កាត់ | លេខាធិការ |

គណៈកម្មាធិការនេះ ទទួលខុសត្រូវជួយចៅសង្កាត់ក្នុងការរៀបចំកសាងផែនការអភិវឌ្ឍន៍ផ្សេងៗ និង កម្មវិធីវិនិយោគសង្កាត់ និងរៀបចំថវិកាប្រចាំឆ្នាំរបស់សង្កាត់។ ទន្ទឹមនឹងនេះ គណៈកម្មាធិការនេះ ត្រូវរៀបចំអនុវត្តនីតិវិធីកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគសង្កាត់ និងរៀបចំថវិកាប្រចាំឆ្នាំរបស់សង្កាត់ តាមអភិក្រមដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

**ខ. គណៈកម្មការលទ្ធកម្ម**

គណៈកម្មការលទ្ធកម្មសង្កាត់កោះអន្លង់ចិន មានសមាសភាពចំនួន ៤រូប[22] ដឹកនាំដោយប្រធាន ១រូប ជាចៅសង្កាត់ និងមានសមាជិកចំនួន ៣រូប ទៀតដែលមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | លោក | **ជ្រឹង ជឿង** | ចៅសង្កាត់ | ប្រធាន |
| ២. | លោក | **ជា គឹមហួន** | ចៅសង្កាត់រងទី១ | អនុប្រធាន |
| ៣. | លោកស្រី | **អាត សាមុីឌី** | សមាជិកក្រុមប្រឹក្សា | សមាជិក |
| ៤. | លោក | **គាំ ចាន់កុសល** | ស្មៀនសង្កាត់ | លេខាធិការ |

គណៈកម្មការនេះ មានតួនាទីភារកិច្ចដូចជា ធានាឲ្យមានលទ្ធកម្មការងារសោងសង់ ការផ្គត់ផ្គង់សម្ភារៈ និងការផ្តល់សេវា ប្រព្រឹត្តទៅប្រកបដោយតម្លាភាព និងសន្សំសំចៃបំផុតតាមដែលអាចធ្វើទៅបានដោយធានាគុណភាព។ ធានាឲ្យអ្នកទទួលការ អ្នកផ្តល់សេវា និងអ្នកផ្គត់ផ្គង់ត្រូវបានផ្តល់ឱកាសស្មើៗគ្នា ដើម្បីចូលរួមនៅដំណើរ

[22] សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការលទ្ធកម្មសង្កាត់កោះអន្លង់ចិន ថ្ងៃទី១២ ខែមករា ឆ្នាំ២០២១។

ការដេញថ្លៃក្រោមលក្ខខណ្ឌយុត្តិធម៌ ស្មើភាព និងធានាឲ្យមានលទ្ធកម្មនៃការងារដេញថ្លៃត្រូវប្រកាសជាសាធារណៈ។ គណៈកម្មការនេះ មានភារកិច្ចទទួលបន្ទុកការងារទាំងឡាយមានដូចជា ការធ្វើការវាយតម្លៃលើការងារដេញថ្លៃ របស់អ្នកម៉ៅការ និងអ្នកផ្គត់ផ្គង់ និងផ្តល់អនុសាសន៍ លើការសម្រេចចុះកិច្ចសន្យា ហើយធ្វើសេចក្តីសម្រេចដោយសម្លេងគាំទ្រភាគច្រើន ក្នុងករណីសម្លេងស្មើគ្នា សម្លេងប្រធានចាត់ទុកថាមានឧត្តមានុភាព។

**គ. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ**

គណៈកម្មាធិការនេះ មានសមាសភាពចំនួន ១១រូប[23] ដឹកនាំដោយប្រធាន ០១រូប ជាចៅសង្កាត់ និងមានសមាជិកចំនួន ១០រូប ទៀតដែលជាសមាជិកដែលមានរាយនាមដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. លោក | **ជ្រឹង ជឿង** | ចៅសង្កាត់ | ប្រធាន |
| ២. លោក | **ប៉ូ ឆាង** | ចៅសង្កាត់រងទី២ | អនុប្រធាន |
| ៣. លោកស្រី | **អាត សាមុឺឌី** | សមាជិកក្រុមប្រឹក្សា | សមាជិកអចិន្ត្រៃយ៍ |
| ៤. លោក | **គាំ ចាន់កុសល** | ស្មៀនសង្កាត់ | សមាជិក |
| ៥. លោក | **ឌុល ចំណាន** | នាយរងប៉ុស្តិ៍រដ្ឋបាល | សមាជិក |
| ៦. លោកស្រី | **ម៉ក់ សុខន** | នាយកសាលាបឋមសិក្សា | សមាជិក |
| ៧. លោកស្រី | **អ៊ូច វណ្ណនី** | ប្រធានមណ្ឌលសុខភាព | សមាជិក |
| ៨. លោកស្រី | **ភេ ផាត** | អនុប្រធានភូមិក្បាលកោះ | សមាជិក |
| ៩. កញ្ញា | **ចាយ ផល្លា** | សមាជិកភូមិកណ្តាលកោះ | សមាជិក |
| ១០.លោកស្រី | **ប៉ោក គៀង** | អនុប្រធានភូមិស្វាយពុំត្រង់ | សមាជិក |
| ១១.លោកស្រី | **សុខ ស្រី** | សមាជិកភូមិចុងកោះ | សមាជិក |

**គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ មានភារកិច្ចដូចជា៖**

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គណៈកម្មការជូនក្រុមប្រឹក្សាសង្កាត់អនុម័ត
- ផ្តល់ប្រឹក្សាយោបល់ និងជួយក្រុមប្រឹក្សាសង្កាត់ ចំពោះការងារពាក់ព័ន្ធកិច្ចការនារី និងកុមារនៅសង្កាត់
- អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យយល់ដឹងអំពីច្បាប់ គោលនយោបាយនានារបស់រដ្ឋពាកព័ន្ធសិទ្ធិនារី និងកុមារ និងបំផុសចលនាសហគមន៍លើវិស័យសុខភាពអប់រំ កិច្ចការពារ និងការអភិវឌ្ឍកុមារ ព្រមទាំងការចុះបញ្ជីអត្រានុកូលដ្ឋានជូនទារក និងកុមារ
- ទាក់ទាញការគាំទ្រដើម្បីឲ្យនារីបានចូលរួមធ្វើសេចក្តីសម្រេច លើការអភិវឌ្ឍនៅមូលដ្ឋានសង្កាត់

[23] សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ថ្ងៃទី១២ ខែមករា ឆ្នាំ២០២១។

- បង្កើននិងពង្រឹងនូវការប្រាស្រ័យទាក់ទងកិច្ចសហការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាសង្កាត់ និងអ្នកផ្តល់សេវាកម្ម និងអ្នកភូមិ ដែលធ្វើសកម្មភាពជួយនារី និងកុមារនៅក្នុងសង្កាត់របស់ខ្លួន
- ជួយក្រុមប្រឹក្សាសង្កាត់ក្នុងការប្រមូល វិភាគព័ត៌មានទិន្នន័យ ពាក់ព័ន្ធបញ្ហា និងតម្រូវការរបស់នារីនិងកុមារ ដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍សង្កាត់ និងកម្មវិធីវិនិយោគសង្កាត់
- ចូលរួមអនុវត្តពិនិត្យតាមដាន និងវាយតម្លៃផែនការសកម្មភាពពាក់ព័ន្ធ ស្ថានភាពនារី និងកុមារ
- តាមដានស្ថានភាពនារី និងកុមារក្នុងសង្កាត់ និងធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សាសង្កាត់ ព្រមទាំងដាក់បញ្ចូលក្នុងរបាយការណ៍សង្កាត់
- ចៅសង្កាត់ ដែលជាប្រធានគណៈកម្មាធិការត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាសង្កាត់របស់ខ្លួន។
- គណៈកម្មាធិការត្រូវសម្របសម្រួល និងសហការជិតស្និតជាមួយអ្នកផ្តល់សេវាកម្មនានា ផ្នែកសង្គមកិច្ច និងអ្នកស្ម័គ្រចិត្តភូមិ និងសហគមន៍នៅក្នុងសង្កាត់ ដើម្បីបំពេញតួនាទី ភារកិច្ចខាងលើឲ្យមានប្រសិទ្ធិភាព។

**ឃ. កិច្ចប្រជុំរបស់គណៈកម្មាធិការ**

ជាគោលការណ៍ កិច្ចប្រជុំគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាសង្កាត់ ត្រូវអនុវត្តន៍ដូចកិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់ដែរ ប៉ុន្តែមានចំណុចពិសេសដូចជា របៀបវារៈសម្រាប់កិច្ចប្រជុំ គណៈកម្មាធិការផ្តល់យោបល់ ត្រូវរៀបចំដោយស្មៀនសង្កាត់ ដោយមានការពិគ្រោះយោបល់ជាមួយចៅសង្កាត់ និងប្រធានគណៈកម្មាធិការ។ ប្រសិនបើសមាជិកគណៈកម្មាធិការច្រើនជាងមួយភាគបី មានបំណងពិភាក្សាលើបញ្ហាដែលស្ថិតនៅក្នុងការងាររបស់គណៈកម្មាធិការ បញ្ហានោះត្រូវដាក់ចូលនៅក្នុងរបៀបវារៈ។ សេចក្តីសម្រេចរបស់គណៈកម្មាធិការ ត្រូវធ្វើសេចក្តីសម្រេចដោយការព្រមព្រៀងឯកភាពគ្នាតាមរយៈការលើកដៃចំពោះការធ្វើសេចក្តីសម្រេច។ ប្រសិនបើពុំមានការព្រមព្រៀងឯកភាពគ្នានោះទេ គណៈកម្មាធិការត្រូវធ្វើការបោះឆ្នោត ហើយគណៈកម្មាធិការត្រូវធ្វើការរាយការណ៍អំពីសេចក្តីសម្រេចរបស់ខ្លួនជូនក្រុមប្រឹក្សាសង្កាត់ ឬជូនចៅសង្កាត់។

## ២.២.៣. ហិរញ្ញវត្ថុរបស់សង្កាត់

### ក. ការរៀបចំ និងការអនុម័តថវិកា

គម្រោងថវិការបស់សង្កាត់កោះអន្លង់ចិន ត្រូវបានរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់ចៅសង្កាត់ និងដោយមានជំនួយពីគណៈកម្មាធិការកសាងផែនការ និងថវិកាសង្កាត់ ទើបបញ្ជូនទៅក្រុមប្រឹក្សាសង្កាត់ ដើម្បីធ្វើការពិនិត្យ និងអនុម័ត។ ជាទូទៅ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តគម្រោងថវិកានៃកិច្ចប្រជុំជាសាធារណៈឲ្យបានមុនថ្ងៃទី៣១ ខែតុលា។[24] ជាក់ស្តែង សង្កាត់កោះអន្លង់ចិន មុននឹងរៀបចំអនុម័តថវិកានេះផងដែរ តែងតែធ្វើការប្រឹក្សាយោបល់ពីប្រជាពលរដ្ឋអំពីតម្រូវការរបស់ពួកគាត់ ថាតើពួកគាត់ចង់បានអ្វីខ្លះ ដើម្បីងាយស្រួលរៀបចំ

[24] មាត្រា ១១ នៃអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ-សង្កាត់។

ថវិកាឲ្យបានត្រូវទៅតាមទិសដៅដែលប្រជាពលរដ្ឋនៅក្នុងសង្កាត់ចង់បាន។ ជារៀងរាល់ឆ្នាំ ដំណើរការរៀបចំថវិកាត្រូវបានកំណត់គោលដៅឲ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ដើម្បីជួយផ្ដល់មតិយោបល់ ព្រមទាំងផ្ដិតមេដៃបញ្ជាក់ការចូលរួមរបស់ខ្លួន។ ជារឿយៗ ក្រោយពេលដែលប្រកាសផ្សាយឲ្យមានការចូលរួមប្រជុំពីសំណាក់ប្រជាពលរដ្ឋ ប៉ុន្តែប្រជាពលរដ្ឋហាក់បីដូចជាមិនសូវចាប់អារម្មណ៍យកចិត្តទុកដាក់ ដោយហេតុថា ប្រជាពលរដ្ឋគាត់បានផ្ដល់ភាពចាំបាច់ទៅលើការប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃជាជាងការចូលរួមប្រជុំនេះ ចំណែកឯអ្នកខ្លះទៀតយល់ថា ការចូលរួមលុះត្រាតែបានអំណោយទើបពួកគាត់រីករាយក្នុងការចូលរួមនឹងការប្រជុំនេះ។ ចំពោះការរៀបចំគម្រោងថវិកានៅក្នុងឆ្នាំ២០២១ របស់សង្កាត់កោះអន្លង់ចិន សង្កាត់បានរៀបចំថវិកាចំនួន ៥២៤,២៩៤,២០០រៀល សម្រាប់ធ្វើការវិនិយោគនៅក្នុងឃុំ សង្កាត់ និងសម្រាប់បំពេញនូវតម្រូវការផ្សេងទៀតរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។[25] បន្ទាប់ពីការអនុម័តគម្រោងថវិកានៅថ្នាក់សង្កាត់រួចរាល់ហើយ ចៅសង្កាត់កោះអន្លង់ចិន បញ្ជូនគម្រោងថវិកានោះទៅកាន់អភិបាលខេត្តកណ្ដាល។ ក្រោយពេលអភិបាលខេត្ត ឯកភាពលើគម្រោងថវិកាហើយ ត្រូវបញ្ជូនសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរមកឲ្យលោកចៅសង្កាត់វិញ ដើម្បីបញ្ជាក់ពីការទទួលស្គាល់ទៅលើគម្រោងថវិកាដែលសេចក្ដីជូនដំណឹងនេះចម្លងជូនភ្ជាប់ជាមួយគម្រោងថវិកាទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគារខេត្តកណ្ដាលផងដែរ។[26]

**ខ. ចំណូល ចំណាយថវិកាសង្កាត់**

ដោយយោងតាមអនុស្សរណៈស្ដីពីការរៀបចំគម្រោងថវិកា ឆ្នាំ២០២១ របស់សង្កាត់កោះអន្លង់ចិនមានស្ថានភាព ចំណូល ចំណាយ ដូចតទៅ៖

**ចំណូល**

| | |
|---|---|
| ចំណូលចរន្ត | = ៥២៤,២៩៤,២០០ រៀល |
| ចំណូលមូលធន | = 0 រៀល |
| សរុប | = ៥២៤,២៩៤,២០០ រៀល |

**ចំណាយ**

| | |
|---|---|
| ចំណាយចរន្តសរុប | = ៥២៤,២៩៤,២០០ រៀល |
| ចំណាយមូលធន | = 0 រៀល |
| សរុប | = ៥២៤,២៩៤,២០០ រៀល |

[25] អនុស្សរណៈស្ដីពីការរៀបចំគម្រោងថវិកា ឆ្នាំ២០២១។
[26] មាត្រា ១៥ នៃអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្ដីពីប្រព័ន្ធហិរញ្ញឃុំ-សង្កាត់។

### គ. ប្រាក់ឧបត្ថម្ភប្រចាំខែរបស់សមាជិកក្រុមប្រឹក្សាសង្កាត់ និងមន្ត្រីភូមិ

យោងតាមអនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ ស្ដីពីការកែប្រែ និងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានកំណត់ដូចតទៅៈ

ប្រធានក្រុមប្រឹក្សា និងជាចៅសង្កាត់ = ១,១១០,000 រៀល ក្នុងមួយខែ
ចៅសង្កាត់ទី១ = ៨៥០,000 រៀល ក្នុងមួយខែ
ចៅសង្កាត់ទី២ = ៥៥០,000 រៀល ក្នុងមួយខែ
សមាជិកក្រុមប្រឹក្សាសង្កាត់ = ៧៤០,000 រៀល ក្នុងមួយខែ
មេភូមិ = ៤០០,000 រៀល ក្នុងមួយខែ
អនុប្រធានភូមិ = ២៨០,000 រៀល ក្នុងមួយខែ
សមាជិកភូមិ = ២៥០,000 រៀល ក្នុងមួយខែ

ដោយឡែក ចាប់ពីខែមករា ឆ្នាំ២០២១ របបប្រាក់ឧបត្ថម្ភប្រចាំខែរបស់សមាជិកក្រុមប្រឹក្សាសង្កាត់ និងមន្ត្រីភូមិត្រូវអនុវត្តតាមអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី១៦ខែមីនា ឆ្នាំ២០២១ដែលបានកំណត់ដូចតទៅៈ

ប្រធានក្រុមប្រឹក្សា និងជាចៅសង្កាត់ = ១,១១០,000 រៀល
ចៅសង្កាត់ទី១ = ៩៧០,000 រៀល
ចៅសង្កាត់ទី២ = ៩៧០,000 រៀល
សមាជិកក្រុមប្រឹក្សាសង្កាត់ = ៧៦០,000 រៀល
មេភូមិ = ៤៣០,000 រៀល
អនុប្រធានភូមិ = ៣១០,000 រៀល
សមាជិកភូមិ = ២៨០,000 រៀល

## ២.៣. ការអភិវឌ្ឍសង្កាត់កោះអន្លង់ចិន (កណ្ដាល)

### ២.៣.១. ផែនការអភិវឌ្ឍន៍សង្កាត់

ផែនការអភិវឌ្ឍន៍សង្កាត់ មានអាណត្តិ ៥ឆ្នាំ ដូចគ្នាទៅនឹងអាណត្តិរបស់ក្រុមប្រឹក្សាដែរ។ ផែនការអភិវឌ្ឍន៍សង្កាត់ ដែលត្រូវបានប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហាតម្រូវការ និងយុទ្ធសាស្ត្រនានាដើម្បីដោះស្រាយរាល់បញ្ហាទាំងនោះសំដៅឆ្លើយតបទៅនឹងបញ្ហាជាអាទិភាពរបស់ប្រជាពលរដ្ឋឲ្យមានប្រសិទ្ធភាព។

**ក. ការរៀបចំផែនការអភិវឌ្ឍន៍សង្កាត់**

ក្រុមប្រឹក្សាឃុំ សង្កាត់ជារដ្ឋបាលដែលនៅដាច់ឆ្ងាយពីរដ្ឋបាលកណ្តាល ប៉ុន្តែជារដ្ឋបាលរដ្ឋដែលនៅជិត និងប្រជាពលរដ្ឋជាងរដ្ឋបាលដទៃទៀត ហើយបានដឹងច្បាស់នូវតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ស្ថានភាពនៃមូលដ្ឋានរបស់ឃុំ សង្កាត់ផ្ទាល់ផងដែរ។ ដូច្នេះ ការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ឃុំ សង្កាត់នីមួយៗត្រូវតែពឹងផ្អែកទៅលើវិធានការ និងការរៀបចំគម្រោងនានារបស់ឃុំ សង្កាត់នីមួយៗស្របតាមលទ្ធផលផ្ទាល់ខ្លួនរបស់ឃុំ សង្កាត់នោះ។ នៅក្នុងការរៀបចំអនុម័ត និងអនុវត្តនូវផែនការអភិឌ្ឍន៍ សង្កាត់ គឺជាភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយគោលបំណងនៃការបង្កើតផែនការអភិវឌ្ឍនេះ គឺដើម្បីកំណត់នូវទស្សនវិស័យ កម្មវិធី និងកិច្ចអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន។[27] ថ្វីបើឃុំ សង្កាត់ត្រូវបានកំណត់ឲ្យរៀបចំនូវផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដោយខ្លួនឯង និងទៅតាមលទ្ធភាពនៃឃុំ សង្កាត់រៀងៗខ្លួនក៏ដោយ ប៉ុន្តែផែនការអភិវឌ្ឍន៍នេះត្រូវស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់ជាតិផងដែរ។ ផែនការអភិវឌ្ឍន៍ មានសារៈសំខាន់ណាស់ដែលក្រុមប្រឹក្សាឃុំ សង្កាត់ចាំបាច់ត្រូវតែរៀបចំ និងអនុម័តហើយធ្វើការកែសម្រួលនូវទិន្នន័យថ្មីៗដែលមានការប្រែប្រួលជារៀងរាល់ឆ្នាំ នៅពេលស្ថិតិក្នុងអាណត្តិ ឬក្នុងឆ្នាំទី១ នៃអាណត្តិក្រុមប្រឹក្សាដែលទើបនឹងជាប់ឆ្នោត។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិ និងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់មកជាមួយផង។ ផែនការអភិវឌ្ឍឃុំ សង្កាត់នេះត្រូវកំណត់នូវវិធីសាស្ត្រ និងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឲ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការនោះ។ករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់កែតម្រូវឲ្យបានសមស្របក្នុងអំឡុងពលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានច្បាប់ចម្លងនៃផែនការនោះ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសម្រួលផែនការអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួនឲ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[28]

**ខ. វដ្តនៃផែនការអភិវឌ្ឍន៍សង្កាត់**

វដ្តនៃផែនការអភិវឌ្ឍន៍សង្កាត់ មាន៥ ជំហាន គឺៈ

១. សេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍ និងថវិកា

២. កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍន៍សង្កាត់

៣. សេចក្តីព្រាងផែនការអភិវឌ្ឍន៍សង្កាត់

៤. ការអនុម័តផែនការអភិវឌ្ឍន៍សង្កាត់

៥. ការវាយតម្លៃអំពីផែនការអភិវឌ្ឍន៍សង្កាត់។

[27] មាត្រា៦០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់, ២០០១។

[28] មាត្រា៦៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់, ឆ្នាំ២០០១។

**ជំហានទី១៖** សេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍ និងថវិកា

គណៈកម្មាធិការកសាងផែនការ និងថវិកា ជួបប្រជុំនៅថ្នាក់សង្កាត់ដើម្បីការវិភាគទិន្នន័យភូមិ ទិន្នន័យសង្កាត់ ឯកសារព័ត៌មានស្ថានភាពសង្កាត់ និងប្រើឧបករណ៍វិភាគផ្សេងៗក្នុងការកំណត់អំពីបញ្ហា មូលហេតុបញ្ហា និងដំណោះស្រាយសម្រាប់ពិភាក្សាជាមួយប្រជាពលរដ្ឋ។ គណៈកម្មាធិការធ្វើការជួបប្រជុំនៅថ្នាក់សង្កាត់ម្តងទៀតដើម្បីបូកសរុបបញ្ហាមូលហេតុ និងដំណោះស្រាយបានមកពីភូមិនានា និងពីភាក្សាកំណត់សេចក្តីត្រូវការអភិវឌ្ឍគោលដៅយុទ្ធសាស្ត្រអភិវឌ្ឍសកម្មភាពជាអាទិភាព ទំហំគម្រោង ទីតាំងគម្រោង និងតម្លៃប៉ានស្មានគម្រោង។

**ជំហានទី២៖** កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍ

កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍសង្កាត់ ត្រូវបានរៀបចំឡើងដើម្បីប្រជុំជាមួយប្រជាពលរដ្ឋនៅក្នុងសង្កាត់ និងអ្នកពាក់ព័ន្ធនានាផ្តល់មតិយោបល់ទៅលើសេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍ និងថវិការបស់សង្កាត់។

**ជំហានទី៣៖** សេចក្តីព្រាងផែនការអភិវឌ្ឍន៍សង្កាត់

គណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍សង្កាត់ ហើយដាក់ជូនក្រុមប្រឹក្សាសង្កាត់ដើម្បីពិនិត្យ និងឯកភាព។ បន្ទាប់ពីទទួលការឯកភាព ចៅសង្កាត់ផ្ញើសេចក្តីព្រាងផែនការអភិវឌ្ឍន៍សង្កាត់ ជូនអភិបាលខេត្តកណ្តាល តាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខេត្តកណ្តាលដើម្បីពិនិត្យនិងផ្តល់យោបល់។

**ជំហានទី៤៖** ការអនុម័តផែនការអភិវឌ្ឍន៍

គណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវពិនិត្យពិចារណា និងកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍សង្កាត់ ទៅតាមមតិយោបល់របស់របស់អភិបាលខេត្តកណ្តាល។ ក្រោយមកទៀត ក្រុមប្រឹក្សាសង្កាត់ ធ្វើការពិនិត្យ និងអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍សង្កាត់នោះ។ ឯកសារផែនការអភិវឌ្ឍន៍សង្កាត់ដែលបានអនុម័តរួចរាល់ហើយត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងប្រើប្រាស់ជាមូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគប្រចាំឆ្នាំ។

**ជំហានទី៥៖** ការវាយតម្លៃអំពីផែនការអភិវឌ្ឍន៍សង្កាត់

គណៈកម្មាធិការកសាងផែនការ និងថវិកា ពិនិត្យ និងវាយតម្លៃទៅលើប្រសិទ្ធភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍សង្កាត់ និងដកស្រង់បទពិសោធន៍នានាសម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រង ការអនុវត្ត និងការរៀបចំផែនការនាពេលក្រោយ។

**គ. ការអនុវត្តផែនការអភិវឌ្ឍន៍**

នៅពេលអនុវត្តគម្រោង ក្រុមប្រឹក្សាសង្កាត់ត្រូវធានាថាអ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសអ្នកទទួលផលពីគម្រោងបានចូលរួមយ៉ាងពេញលេញនៅក្នុងការរៀបចំគម្រោង និងការត្រួតពិនិត្យការអនុវត្តគម្រោងដែលមាននៅ

ក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគសង្កាត់។ ចៅសង្កាត់ ត្រូវធ្វើលទ្ធកម្មការងារ សាងសង់ សម្ភារៈ ឬទំនិញ និងសេវាកម្មដើម្បីអនុវត្តគម្រោងទាំងអស់ និងសកម្មភាពនានាឲ្យស្របតាមនីតិវិធីដែលបានកំណត់។ មុននឹងធ្វើលទ្ធកម្មការងារសាងសង់ សម្ភារៈ ឬទំនិញ និងសេវាកម្មសម្រាប់អនុវត្តគម្រោងណាមួយ ចៅសង្កាត់ត្រូវស្វែងរកការបញ្ជាក់ផ្នែកបច្ចេកទេសពីមន្ទីរជំនាញ ឬអង្គភាពពាក់ព័ន្ធជុំវិញខេត្ត តាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត។ ការវាយតម្លៃគ្រប់ជ្រុងជ្រោយទៅលើលទ្ធផល និងផលប៉ះពាល់ពីការអនុវត្តផែនការអភិវឌ្ឍន៍សង្កាត់ ត្រូវធ្វើឡើងក្នុងរយៈពេល ០៦ខែ ចុងក្រោយនៃអាណត្តិរបស់ក្រុមប្រឹក្សា។

**ឃ. ការត្រួតពិនិត្យ និងការវាយតម្លៃ**

បន្ទាប់ពីរៀបចំផែនការអភិវឌ្ឍន៍ សង្កាត់រួច ក្រុមប្រឹក្សាសង្កាត់ត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតម្លៃទៅលើសកម្មភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍ កម្មវិធីគម្រោង និងការផ្តល់សេវាសាធារណៈនានារបស់សង្កាត់ប្រកបដោយតម្លាភាពជាមួយនឹងការទទួលខុសត្រូវរបស់អ្នកផ្តល់សេវា។ដោយស្របទៅតាមស្ថានភាពជាក់ស្តែង ក្រុមប្រឹក្សាសង្កាត់អាចជ្រើសរើសសមាសភាពផ្សេងទៀតមកអនុវត្តផែនការកម្មវិធី និងគម្រោងនានារបស់សង្កាត់ ប៉ុន្តែក្រុមប្រឹក្សាសង្កាត់នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដានការត្រួតពិនិត្យ និងការវាយតម្លៃចំពោះការអនុវត្តរបស់សមាសភាពនោះ។ ម្យ៉ាងវិញទៀត ដើម្បីបង្កើនវិធីសាស្ត្រក្នុងការអនុវត្តផែនការត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រុមប្រឹក្សាសង្កាត់ចំពោះការប្រើប្រាស់មូលនិធិសម្រាប់ផែនការអភិវឌ្ឍន៍សង្កាត់។

**២.៣.២. កម្មវិធីវិនិយោគរបស់សង្កាត់**

**ក. ក្របខណ្ឌវិនិយោគ**

ក្របខណ្ឌវិនិយោគ គឺជាផ្នែកមួយដ៏សំខាន់របស់កម្មវិធីវិនិយោគសង្កាត់កោះអន្លង់ចិន។ ក្រុមប្រឹក្សាសង្កាត់កោះអន្លង់ចិន ដែលមានគណៈកម្មាធិការកសាងផែនការ និងថវិកាសង្កាត់ជាជំនួយបានយកចិត្តទុកដាក់គិតគូរ និងរៀបចំអំពីគោលបំណងសំខាន់ៗដើម្បីធ្វើការអភិវឌ្ឍមូលដ្ឋាននាពេលអនាគត ដោយផ្អែកទៅលើផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ (២០១៩-២០២៣) ជាឯកសារគោល និងជាត្រីវិស័យសម្រាប់ឲ្យក្រុមប្រឹក្សាសង្កាត់អនុវត្តតាមរយៈការរៀបចំ និងការអនុវត្តកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់សង្កាត់។ នៅពេលពិនិត្យលើបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋឡើងវិញ ការរៀបចំគម្រោងវិនិយោគប្រចាំឆ្នាំរបស់សង្កាត់ ត្រូវឆ្លងកាត់ការពិភាក្សាគ្នាឲ្យបានល្អិតល្អន់ដើម្បីជ្រើសរើស និងចាត់អាទិភាពគម្រោងសម្រាប់យកទៅអនុវត្តឲ្យចំគោលដៅតាមការជាក់ស្តែងនៅក្នុងមូលដ្ឋានផ្ទាល់ ហើយថាតើអ្វីដែលជាបញ្ហាប្រឈម ហើយចាំបាច់ត្រូវធ្វើការដោះស្រាយជាមុន ដើម្បីឲ្យស្របទៅនឹងប្រភពធនធានដែលសង្កាត់មាន និងទុនពីខាងក្រៅដែលបានមកពីការជួយឧបត្ថម្ភគាំទ្រពីសំណាក់មន្ទីរជំនាញអង្គការក្រៅរដ្ឋាភិបាល សប្បុរជន និងដៃគូរអភិវឌ្ឍនានាជួយគាំទ្រដល់គម្រោងកម្មវិធីវិនិយោគនេះ នៅពេលដែលសមាហរណកម្មផែនការសង្កាត់ និងគម្រោងខ្លះទៀតជួយគាំទ្រក្រោយពេលសមាហរ

ណកម្មផែនការផងដែរ។ ជាមួយគ្នានេះដែរ សង្កាត់ត្រូវកោះប្រជុំពេញអង្គក្រុមប្រឹក្សា ដើម្បីសម្រេចជ្រើសរើសគម្រោងដែលនៅសេសសល់គ្មានការសន្យាគាំទ្រសម្រាប់ប្រើប្រាស់មូលនិធិសង្កាត់ ទុនចូលរួមពីប្រជាពលរដ្ឋ និងថវិកាផ្សេងៗទៀតរបស់សង្កាត់ដែលទទួលបានពីមជ្ឈដ្ឋានខាងក្រៅដាក់បញ្ចូលនៅក្នុងតារាងថវិកាវិនិយោគតាមប្រភព តារាងគម្រោងវិនិយោគដែលមានការសន្យាគាំទ្រ និងតារាងគម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្រ។

**ខ. វដ្តនៃកម្មវិធីវិនិយោគ**

វដ្តនៃកម្មវិធីវិនិយោគសង្កាត់មាន ៥ជំហានគឺ៖

**ជំហានទី១៖** ការពិនិត្យបញ្ហា ឬតម្រូវការជាមួយប្រជាពលរដ្ឋឡើងវិញ

គណៈកម្មាធិការកសាងផែនការ និងថវិកា ជួបប្រជុំនៅថ្នាក់សង្កាត់ ដើម្បីពិភាក្សាពិនិត្យបញ្ហា ឬតម្រូវការមូលហេតុនៃបញ្ហា និងដំណោះស្រាយឡើងវិញ ដោយធ្វើការឆ្លុះបញ្ចាំងជាមួយទិន្នន័យភូមិ ទិន្នន័យសង្កាត់ ឯកសារព័ត៌មានស្ថានភាពសង្កាត់ និងទិន្នន័យ ឬព័ត៌មានផ្សេងៗហើយកំណត់អំពីបញ្ហា មូលហេតុនៃបញ្ហា និងដំណោះស្រាយនានាសម្រាប់ពិភាក្សាជាមួយប្រជាពលរដ្ឋ។ គណៈកម្មាធិការនេះត្រូវធ្វើការរៀបចំប្រជុំនៅតាមភូមិ ដើម្បីពិភាក្សា និងធ្វើសុពលភាពទៅលើបញ្ហាមូលហេតុ និងដំណោះស្រាយទាំងឡាយដែលបានកំណត់នៅថ្នាក់សង្កាត់ដើម្បីពិភាក្សាកំណត់បញ្ហា ឬតម្រូវការ និងដំណោះស្រាយដែលបានមកពីបណ្តាភូមិនានា។

**ជំហានទី២៖** ការរៀបចំគម្រោងថវិកាវិនិយោគសង្កាត់

គណៈកម្មាធិការកសាងផែនការ និងថវិកា ធ្វើការឆ្លុះបញ្ចាំងលទ្ធផលនៃជំហានទី១ ជាមួយនឹងគម្រោងតាមបណ្តាឆ្នាំនីមួយៗនៃផែនការអភិវឌ្ឍន៍សង្កាត់ ដើម្បីកំណត់នូវគម្រោងកម្មវិធីវិនិយោគប្រចាំឆ្នាំដែលត្រូវយកទៅបង្ហាញ និងកៀរគរធនធាននៅសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង។

**ជំហានទី៣៖** សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ក្រុង

សិក្ខាសាលាសមាហរណកម្មផែនការនេះ ត្រូវរៀបចំឡើងដើម្បីផ្តល់ឱកាសឲ្យមានការភ្ជាប់ជាមួយកម្មវិធីវិនិយោគសង្កាត់ជាមួយនឹងផែនការរបស់មន្ទីរជំនាញ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍនានា ហើយធ្វើការកៀរគរ និងសម្របសម្រួលធនធានពីប្រភពផ្សេងៗ សម្រាប់គាំទ្រដល់គម្រោងវិនិយោគសង្កាត់ ជាពិសេសជួយតម្រង់ទិសសកម្មភាពរបស់មូលដ្ឋានសង្កាត់ ឲ្យស្របតាមគោលនយោបាយអភិវឌ្ឍជាតិ និងខេត្ត។

**ជំហានទី៤៖** ការអនុម័តកម្មវិធីវិនិយោគសង្កាត់

គណៈកម្មាធិការកសាងផែនការ និងថវិកា បានរៀបចំនូវតារាងថវិកាតាមប្រភព តារាងគម្រោងវិនិយោគដែលមានការសន្យាគាំទ្រ និងតារាងគម្រោងវិនិយោគដែលមិនទាន់មានការគាំទ្រ ជាពិសេសការជ្រើសរើសនូវគម្រោងដែលមិនទាន់មានការសន្យាគាំទ្រសម្រាប់ប្រើប្រាស់មូលនិធិសង្កាត់។ ក្រោយពីប្រមូលមតិយោបល់រួច

គណៈកម្មាធិការនេះត្រូវរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគសង្កាត់ ហើយដាក់ជូនក្រុមប្រឹក្សាសង្កាត់ ដើម្បីពិនិត្យ និងអនុម័ត។ ឯកសារកម្មវិធីវិនិយោគដែលអនុម័តរួច ត្រូវប្រកាសផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់ជាផ្លូវការ និងបង្កភាពងាយស្រួលដល់អ្នកពាក់ព័ន្ធដើម្បីធ្វើការសិក្សាស្វែងយល់។

**ជំហានទី៥៖** ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគសង្កាត់

គណៈកម្មាធិការកសាងផែនការ និងថវិកា ត្រូវតាមដានត្រួតពិនិត្យការរីកចម្រើន និងប្រសិទ្ធភាពនៃការអនុវត្តគម្រោង ឬសកម្មភាពនានាដែលមាននៅក្នុងកម្មវិធីវិនិយោគសង្កាត់ ដើម្បីធានាការអនុវត្តគម្រោង ឬសកម្មភាពទាំងនោះឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។ មិនត្រឹមតែប៉ុណ្ណោះ គណៈកម្មាធិការនេះក៏ត្រូវតែត្រួតពិនិត្យ និង វាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីវិនិយោគសង្កាត់ ហើយដកស្រង់បទពិសោធន៍សម្រាប់ជាមូលដ្ឋាននៅក្នុងការគ្រប់គ្រង ការអនុវត្ត និងការរៀបចំកម្មវិធីវិនិយោគឆ្នាំក្រោយ។

### ២.៣.៣. គម្រោង និងសកម្មភាពវិនិយោគរបស់សង្កាត់

នៅក្នុងសង្កាត់កោះអន្លង់ចិនមានប្រជាពលរដ្ឋចំនួន ៨២.៥% ប្រកបមុខរបរកសិកម្មជាចម្បងឃើញថាសក្តានុពលទាំងនេះមានអាទិភាពសម្រាប់ប្រជាពលរដ្ឋក្នុងសង្កាត់ទាំងមូល ថ្វីត្បិតតែសង្កាត់កោះអន្លង់ចិនមានលក្ខណៈអំណោយផលលើវិស័យកសិកម្ម តែប្រជាពលរដ្ឋដែលមានមុខរបរអាជីវកម្មមានចំនួនតិចតួច ភាគច្រើនជាកម្មកររោងចក្រ ហេដ្ឋារចនាសម្ព័ន្ធនៅមានភាពខ្វះខាតដូចជា ផ្លូវបេតុង ប្រព័ន្ធលូរំដោះទឹក ជាពិសេសពិបាកធ្វើដំណើរទៅកាន់ទីប្រជុំជន (ប្រើទូកដរចម្លង) គ្មានសេវាប្រមូលសម្រាម ការបម្រើសេវាសុខភាពទូទៅនៅមានកម្រិត។ លើសពីនេះទៅទៀត ក្រុមប្រឹក្សាសង្កាត់ គណៈកម្មាធិការនានាត្រូវជំរុញ និងផ្តល់ចំណេះដឹងគ្រប់បែបយ៉ាងទៅដល់ប្រជាពលរដ្ឋដូចជា ការលើកកម្ពស់សុខភាព និងអនាម័យនៅតាមគ្រួសារ ទីសាធារណៈ សាលារៀន (ផឹកស្អាត ហូបស្អាត រស់នៅស្អាត)។ ធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យពិគ្រោះយោបល់ និងពិនិត្យជំងឺនៅមណ្ឌលសុខភាព និងជំរុញឲ្យមាតាបិតានាំកូនទៅចុះឈ្មោះចូលរៀនឲ្យបានគ្រប់ៗគ្នា មានការផ្សព្វផ្សាយអំពីច្បាប់នានាដែលទាក់ទងទៅនឹងសន្តិសុខសណ្តាប់ធ្នាប់សង្គម មានគោលនយោបាយភូមិ សង្កាត់មានសុវត្ថិភាព និងចូលរួមវេទិការសាធារណៈ ចុះបង្ក្រាបបទល្មើសផ្សេងៗ។ ដើម្បីសម្រេចបានគោលដៅខាងលើ ក្រុមប្រឹក្សាសង្កាត់ ត្រូវខិតខំប្រឹងប្រែងកៀងគរកមូលនិធិពីរាជរដ្ឋាភិបាល មន្ទីរជំនាញ អង្គការនិងសប្បុរសជននានា ដើម្បីជួយកសាងភូមិ សង្កាត់ឲ្យមានការរីកចម្រើន ជាពិសេសធនធានផ្ទាល់របស់សង្កាត់នៅក្នុងការអនុវត្តគម្រោងឲ្យមានប្រសិទ្ធភាព និរន្តរភាព និងភាពជាម្ចាស់លើគម្រោងរបស់ខ្លួន។ ក្រុមប្រឹក្សាសង្កាត់កោះអន្លង់ចិន និងគណៈកម្មាធិការកសាងផែនការ និងថវិកាសង្កាត់បានរៀបចំឯកសារកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលសង្កាត់ ឆ្នាំ ២០២១-២០២៣ ដែលជាឆ្នាំទី១នៃផែនការអភិវឌ្ឍន៍សង្កាត់ដើម្បីអភិវឌ្ឍមូលដ្ឋានសង្កាត់ខាងលើ ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ផ្នែករដ្ឋបាល និងសន្តិ

សុខសណ្តាប់ធ្នាប់សាធារណៈ ដែលផ្អែកទៅលើមូលនិធិឃុំ សង្កាត់ ធនធានគាំទ្រពីមន្ទីរ អង្គភាព អង្គការ និង សប្បុរសជននានា។

**ក. គម្រោងសកម្មភាពដែលមានថវិកាគាំទ្រ**

នៅក្នុងអាណត្តិទី៤ នៃក្រុមប្រឹក្សាសង្កាត់កោះអន្លង់ចិន ប្រជាពលរដ្ឋមានជីវភាពកាន់តែប្រសើរឡើង ដោយធ្វើការកាត់បន្ថយអត្រាក្រីក្ររបស់ប្រជាជន តាមរយៈការកៀងគរ ដៃគូអភិវឌ្ឍ ការបង្កើនចំណេះដឹងវិជ្ជាជីវៈ បង្កើតមុខរបរជូនប្រជាពលរដ្ឋ អប់រំផ្សព្វផ្សាយ ពីសុខុមាលភាព និងការកែលម្អរហេដ្ឋារចនាសម្ព័ន្ធ មួយចំនួន ដែលនៅមានសេសសល់កន្លងមក ឲ្យស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល កម្ពុជា។[29] តាមរយៈកិច្ចប្រជុំកន្លងមក ក្រុមប្រឹក្សាសង្កាត់រៀបចំនូវគម្រោងវិនិយោគមួយចំនួនដែលមានថវិកាគាំទ្រ សង្កាត់លើផ្នែកសេដ្ឋកិច្ច សង្គមកិច្ច រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។[30] គម្រោងវិនិយោគទាំង អស់មានដូចជា កែលម្អផ្លូវចាក់បេតុងអាមេ ដែលមានប្រវែង ១០០០ម៉ែត្រ ស្ថិតនៅភូមិស្វាយពុំត្រង់ (ឆ្នាំ២០២២) ចំណាយប៉ាន់ស្មាន ៣០០,០០ លានរៀល និងស្ថិតក្នុងភូមិចុងកោះ ដែលមានប្រវែង ២០០០ ម៉ែត្រ (ឆ្នាំ២០២៣-២០២៤) ចំណាយប៉ាន់ស្មាន ៦០០,០០០ លានរៀល ផ្តល់ឧបត្ថម្ភដល់ជនងាយរងគ្រោះ (ជំងឺអេដស៍) ទូទាំង សង្កាត់ ៧២នាក់ អនុវត្តរយៈពេល ០៣ឆ្នាំ ចំណាយប៉ាន់ស្មាន ៨,៦៤ លានរៀល និងផ្តល់សម្ភារៈសម្រាប់សាង សង់បង្គន់អនាម័យទូទាំងសង្កាត់ ១០៨គ្រឿង អនុវត្តរយៈពេល ០៣ឆ្នាំ ចំណាយប៉ាន់ស្មាន ១០,៨០លានរៀល។ លើសពីនេះទៅទៀត សង្កាត់កោះអន្លង់ចិនមានគម្រោងសកម្មភាពមួយចំនួនទៀត ដែលទទួលបានការសន្យា គាំទ្រមូលនិធិពីអ្នកពាក់ព័ន្ធនៅក្នុងផ្នែកសង្គមកិច្ចមានដូចជា ផ្តល់អាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សា ដែល ស្ថិតនៅអនុវិទ្យាល័យកោះអន្លង់ចិន(អប់រំ) ផ្តល់អាហារូបករណ៍សិស្សក្រីក្ររៀនពូកែស្ថិតនៅបឋមសិក្សាកោះ អន្លង់ចិន (អប់រំ) ផ្តល់វ៉ាក់សាំងការពារជំងឺ ១២មុខ ដល់កុមារក្រោម ១ឆ្នាំ និងថ្នាំបង្ការជំងឺតេតាណុស ដល់ស្ត្រីមាន ផ្ទៃពោះ និងស្ត្រីសម្រាលកូន (សុខាភិបាល) ផ្តល់សេវាសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលបានបណ្តុះ បណ្តាលនៅមូលដ្ឋានសុខាភិបាល (RH,HC) (សុខាភិបាល) កម្មវិធីពន្យាកំណើត សេវាសុខភាពស្ត្រីមានផ្ទៃពោះ សកម្មភាពបង្ការ ថែទាំ និងព្យាបាលអេដស៍ សកម្មភាពស្រាវជ្រាវ និងទប់ស្កាត់ការឆ្លងជំងឺរបេង យុទ្ធនាការដាក់ថ្នាំ បាណកឃាដអាបេត/ប៊ីធីអាយ អប់រំផ្សព្វផ្សាយបន្ទុកជំងឺមិនឆ្លង ផ្តល់សេវាព្យាបាលមិនយកកម្រៃដល់ប្រជាពលរដ្ឋ ក្រីក្រតាមរយៈមូលនិធិសមធម៌ ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌ សេវាសុខាភិបាល កសាង បង្គន់អនាម័យ និងប្រព័ន្ធទឹកស្អាត បណ្តុះបន្តែអាជីវកម្មបន្លែសុវត្ថិភាព និង កម្មវិធីរដ្ឋបាលដីធ្លី ចំណាយថវិកា ប្រហែល ១៣៥,៦៧ លានរៀល ឬក៏អាចលើសពីនេះទៅទៀត។

---

[29] សៀវភៅកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល ២០២១-២០២៣ សង្កាត់កោះអន្លង់ចិន, ទំព័រ៧។

[30] សៀវភៅកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល ២០២១-២០២៣ សង្កាត់កោះអន្លង់ចិន, ទំព័រ៨។

### ខ. គម្រោង សកម្មភាពដែលមិនមានថវិកាគាំទ្រ

ចំពោះគម្រោងសកម្មភាពដែលមិនមានថវិកាគាំទ្រ ស្ថិតក្នុងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។[31] គម្រោងវិនិយោគទាំងអស់នោះមាន ធ្វើផ្លូវបេតុងអាមេមានចំនួន ៣ភូមិ ដែលមានប្រវែង ២០៥០ម៉ែត្រ ចំណាយថវិកា ៨២០ លានរៀល ដែលមានអ្នកទទួលផលផ្ទាល់សរុប ៤០០៨នាក់ ក្នុងនោះមានស្រីចំនួន ២៩៣៣នាក់ ផ្តល់ការបណ្តុះបណ្តាលពេទ្យធ្មប មាន២នាក់ ចំណាយប៉ាន់ស្មានចំនួន១,២ លានរៀល ជួសជុលដំបូលសាលាស្ថិតនៅបឋមសិក្សាកោះអន្លង់ចិន ចំនួន ៥បន្ទប់ ចំណាយប៉ាន់ស្មានចំនួន ៤,៦ លានរៀល ឧបត្ថម្ភជនងាយរងគ្រោះទូទាំងសង្កាត់ ៣៨៤គ្រួសារ ចំណាយប៉ាន់ស្មានចំនួន ៣៨,៤ លានរៀល ហើយអ្នកទទួលផលផ្ទាល់សរុប ៧៦៨នាក់ ក្នុងនោះមានស្រី ៣២១នាក់ បណ្តុះបណ្តាលបច្ចេកទេសដាំដុះ ទូទាំងសង្កាត់មាន ២វគ្គ អ្នកទទួលផលផ្ទាល់មានសរុប ១០០នាក់ ក្នុងនោះមានស្រី ៥០នាក់ ចំណាយប៉ាន់ស្មានចំនួន ៥,០៤០ លានរៀល បណ្តុះបណ្តាលធ្វើជីសរីរាង្គ ទូទាំងសង្កាត់មាន ២វគ្គ អ្នកទទួលផលផ្ទាល់មានសរុប ៥០នាក់ និងស្រី២៥នាក់ ចំណាយប៉ាន់ស្មានចំនួន ៨ លានរៀល បណ្តុះបណ្តាលវិជ្ជាជីវៈកាត់ដេរ ទូទាំងសង្កាត់មាន ១វគ្គ អ្នកទទួលផលផ្ទាល់សរុប ៥០នាក់ ស្រី២៥នាក់ ចំណាយប៉ាន់ស្មានចំនួន ២,៥២០ លានរៀល បណ្តុះបណ្តាលជំនាញអ៊ុតសក់ ទូទាំងសង្កាត់មាន ១វគ្គ អ្នកទទួលផលផ្ទាល់សរុប ៥០នាក់ ស្រី២៥នាក់ ចំណាយប៉ាន់ស្មានចំនួន ៤ លានរៀល ហើយមានការផ្សព្វផ្សាយបរិស្ថាន (មាន ០២លើក) ច្បាប់ជលផល (មាន ០១លើក) បំផុសចលនាដាំដើមឈើ (មាន ០១លើក) សេវាកម្មដឹកសម្រាម ទូទាំងសង្កាត់ ដោយចំណាយប៉ាន់ស្មានចំនួន ២,២៨២,០០០ រៀល ហើយថែមទាំងមានការអប់រំយល់ដឹងពីគ្រឿងញៀន (០២លើក) ផ្សព្វផ្សាយច្បាប់អំពើហឹង្សាក្នុងគ្រួសារ (០២លើក) ជំរុញសកម្មភាពទប់ស្កាត់ល្បែងស៊ីសង (០៤លើក) ផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោក (០១លើក) អប់រំកាត់បន្ថយការសេពគ្រឿងស្រវឹង (០១លើក) និងដាក់ស្លាកសញ្ញាចរាចរណ៍តាមផ្លូវជាតិ (២០ផ្លាក) ទូទាំងសង្កាត់ ចំណាយប៉ាន់ស្មានចំនួន ៥,២៦២,០០០ រៀល ដោយអនុវត្តរយៈពេល ០៥ឆ្នាំ។

### ២.៣.៤. សមិទ្ធផលនានា

នៅក្នុងសង្កាត់កោះអន្លង់ចិននៅអាណត្តិទី៤នេះ បានអភិវឌ្ឍនិងកសាងសមិទ្ធផលនានាជាច្រើន នៅក្នុងមូលដ្ឋានសង្កាត់របស់ខ្លួនសម្រាប់បំពេញតម្រូវការរបស់ប្រជាពលរដ្ឋ កាត់បន្ថយភាពក្រីក្រ និងដើម្បីលើកកម្ពស់ជីវភាពរស់នៅឲ្យកាន់តែល្អប្រសើរឡើងថែមទៀត។ នៅក្នុងសង្កាត់កោះអន្លង់ចិនទាំងមូល មានភូមិចំនួន ៤ភូមិ ហើយមានសមិទ្ធផលនានាជាច្រើនដូចជា ផ្លូវបេតុងអាមេទូទាំងសង្កាត់សម្រេចបានប្រម៉ាណ៧០% ដោយតំបន់ខ្លះមានទទឹងប្រវែង ៤ ម៉ែត្រ និងតំបន់ខ្លះទៀតទទឹងប្រវែង ៥ ម៉ែត្រ។ ក្រៅពីនេះសង្កាត់បាននឹងកំពុង

[31] សៀវភៅកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល ២០២១-២០២៣ សង្កាត់កោះអន្លង់ចិន។

រៀបចំនិងសម្របសម្រួលឲ្យមានការចុះបញ្ជីដីធ្លី ចេញបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋឲ្យក្លាយជាម្ចាស់កម្មសិទ្ធិដោយស្របច្បាប់។ នៅចុងឆ្នាំ២០២១ នឹងដាក់ដំណើរការជាផ្លូវការនូវ ស្ពានផ្លូវក្រវាត់ក្រុងទី៣ (ស្ពានឆ្លងទន្លេដែលជាគម្រោងរបស់ក្រុមហ៊ុនចិន និងរាជរដ្ឋាភិបាល) ស្ថិតនៅភូមិស្វាយពុំត្រង់ ដែលអាចបង្កឲ្យមានភាពងាយស្រួលដល់ប្រជាពលរដ្ឋដូចជា កាត់បន្ថយការចំណាយពីការឆ្លងទូកដរ និងហានិភ័យផ្សេងៗ។

# ជំពូកទី ៣

# បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី ៣
# បញ្ហាប្រឈម និងដំណោះស្រាយ

## ៣.១ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមក្នុងសង្កាត់

### ៣.១.១. ផ្នែកសេដ្ឋកិច្ច

តាមប្រភពព័ត៌មានស្ថានភាពសង្កាត់ និងផែនទីសង្កាត់ ក៏ដូចជាស្ថានភាពជាក់ស្តែងដែរ សង្កាត់កោះអន្លង់ចិនមានផ្ទៃដីបង្កបង្កើនផលចំការជាច្រើនហិចតា ក្រៅពីនេះប្រជាពលរដ្ឋក្នុងសង្កាត់ភាគច្រើនប្រកបមុខរបរលក់ដូរតូចតាច និងចិញ្ចឹមសត្វតាមលក្ខណៈគ្រួសារ។ ម្យ៉ាងទៀតប្រជាពលរដ្ឋមួយចំនួនគាត់ធ្វើជាមន្ត្រីរាជការ បុគ្គលិកក្រុមហ៊ុន អង្គការ ជាងផ្ទះ កម្មករសំណង់ និងកម្មកររោងចក្រជាដើម។ សង្កាត់កោះអន្លង់ចិនមានផ្លូវមួយខ្សែឆ្លងកាត់ និងផ្លូវលំជាច្រើនខ្សែ ដែលមានចម្ងាយជាច្រើនម៉ែត្រសម្រាប់តភ្ជាប់ពីភូមិមួយទៅភូមិមួយ ដែលជាផ្នែកមួយសម្រាប់សម្រួលដល់ការដឹកផលិតផលកសិកម្ម ពាណិជ្ជកម្ម និងការធ្វើដំណើរទូទៅ។ ទន្ទឹមនឹងលទ្ធផលដែលទទួលបាននេះ សង្កាត់ក៏នៅមានបញ្ហាមួយចំនួនផងដែរ ដោយសារប្រព័ន្ធគមនាគមន៍ខូចខាតដែលត្រូវធ្វើការជួសជុល និងកែលំអរបន្ថែមទៀត។ បញ្ហាទាំងនេះ ទោះបីក្រុមប្រឹក្សាសង្កាត់ អាណត្តិទី៤ បានខិតខំដោះស្រាយខ្លះៗរួចមកហើយក៏ដោយ ក៏បញ្ហាប្រឈម នឹងឧបសគ្គទាំងឡាយនៅតែជាសេចក្តីត្រូវការយ៉ាងខ្លាំងពីក្រុមប្រឹក្សាសង្កាត់អាណត្តិទី៥ នេះរួមគ្នារិះរកមធ្យោបាយគ្រប់បែបយ៉ាងដើម្បីដោះស្រាយជូនប្រជាពលរដ្ឋឲ្យបានសមស្របនៅក្នុងឆ្នាំខាងមុខ។

### ៣.១.២. ផ្នែកសង្គមកិច្ច

តាមការអភិវឌ្ឍជាក់ស្តែង នៅក្នុងសង្កាត់កោះអន្លង់ចិនផ្នែកនេះមានភាពរីកចម្រើនលូតលាស់គួរឲ្យកត់សំគាល់។ វិស័យសុខាភិបាល សង្កាត់មានមណ្ឌលសុខភាពមួយសំរាប់ទ្រទ្រង់សុខុមាលភាពប្រជាពលរដ្ឋទូទៅ ព្រមទាំងមានបុគ្គលិកជំនាញ និងភ្នាក់ងារពេទ្យភូមិទៀតផង ចាំបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ។ ប៉ុន្តែតាមការពិនិត្យស្ថានភាពទិន្នន័យសង្កាត់ ឃើញមានប្រជាពលរដ្ឋមួយចំនួនដូចជាស្ត្រីមានផ្ទៃពោះមិនបានមកពិនិត្យផ្ទៃពោះ និងសំរាលកូននៅមណ្ឌលសុខភាពទេ ឯកុមារដែលត្រូវផ្តល់វ៉ាក់សាំង ៩មុខ ក៏មិនទាន់បានចាក់គ្រប់គ្នា និងគ្រប់ចំនួនថ្នាំកំណត់ដែរ។ អត្រាមរណមាតា និងទារក ក្នុងពេលសំរាលកូន ក៏នៅមានខ្លះៗដែរ កត្តាទាំងនេះបណ្តាលមកពី ការផ្តល់សេវារបស់មណ្ឌលសុខភាពមិនទាន់បានល្អប្រសើរ ការទន់ខ្សោយផ្នែកជីវភាពរបស់ប្រជាពលរដ្ឋផង ពិសេសប្រជាពលរដ្ឋខ្លួនឯងខ្វះការយកចិត្តទុកដាក់ និងយល់ដឹងពីការការពារ និងថែទាំសុខភាពក្នុងគ្រួសារផង។ ដោយឡែកការប្រើប្រាស់ទឹកស្អាតវិញ ក៏នៅមានជួបការលំបាកមួយចំនួនផងដែរ ព្រោះបណ្តាញទឹកស្អាតមិនគ្រប់គ្រាន់ អណ្តូងស្នប់មួយចំនួនធំត្រូវមានជាតិអាសេទិច ដែលមិនអាចប្រើប្រាស់បានទៀតផង។ ចំពោះការប្រើប្រាស់បង្គន់អនាម័យ ប្រជាពលរដ្ឋប្រមាណ ៥%នៅមិនទាន់មានបង្គន់ប្រើ

ប្រាស់នៅឡើយ ដោយសារខ្វះការយល់ដឹង និងខ្វះលទ្ធភាពធ្វើ។ បញ្ហាយុវវ័យ និងសុខភាពបន្តពូជក្នុងសង្កាត់ ក៏មានគ្រួសារប្រជាពលរដ្ឋមួយចំនួនតូចបានផ្ទុកនូវមេរោគអេដស៍។

វិស័យអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏មានសារៈសំខាន់ណាស់ក្នុងការលើកកម្ពស់ធនធានមនុស្សឲ្យទទួលបានសេវាអប់រំស្មើៗគ្នា។ សង្កាត់កោះអន្លង់ចិនមានសាលាបឋមសិក្សាចំនួន ៣កន្លែង និងអនុវិទ្យាល័យចំនួន ១កន្លែង ប៉ុន្តែការខ្វះខាតនៅតែមានព្រោះសិស្សចេះតែកើនឡើងសាលាមួយចំនួនបានចាស់ទ្រុឌទ្រោម ខូចខាតដំបូល មិនមានសោភ័ណភាពល្អ និងមិនធានាដល់សុវត្ថិភាពដល់សិស្ស និងគ្រូដែលកំពុងរៀន។ កុមារគ្រប់អាយុមិនទាន់បានចូលរៀនសាលាមត្តេយ្យបានទាំងអស់គ្នា ព្រោះមានតែសាលាមត្តេយ្យសិក្សារដ្ឋតែពីរកន្លែងប៉ុណ្ណោះ។ កុមារបានបោះបង់ចោលការសិក្សាក្រោមកំរិតបឋមភូមិមានមួយចំនួនដែរ មូលហេតុជីវភាពខ្វះខាត ខ្លះទៅបួសជាសង្ឃ ខ្លះដើរប្រព្រឹត្តអំពើផ្តេសផ្តាសវាយតប់គ្នា ខ្លះចូលធ្វើការរោងចក្រ ខ្លះរៀបការ ឪពុកម្តាយមួយចំនួនតូចមិនបានផ្តល់ឱកាសឲ្យកូនបានរៀនសូត្រ និងមិនបានឲ្យតម្លៃលើការអប់រំ រាល់បញ្ហានិងឧបសគ្គទាំងអស់នេះ ក្រុមប្រឹក្សាសង្កាត់កំពុងគិតគូដើម្បីដោះស្រាយជាបណ្តើរៗ។

### ៣.១.៣. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

តាមការវិភាគផែនទីសង្កាត់កន្លងមក ធនធានធម្មជាតិនានានៅក្នុងសង្កាត់មានសម្បូរបែបគួរសមដែរ ដូចជា អូរ ព្រៃក សត្វបក្សាបក្សី និងមច្ឆាជាតិគ្រប់ប្រភេទ ប៉ុន្តែមកដល់បច្ចុប្បន្ននេះធនធានធម្មជាតិទាំងនោះត្រូវបានបាត់បង់ស្ទើរគ្មានសល់ ដោយសារតែគ្រួសារប្រជាពលរដ្ឋកើនឡើង តម្រូវការជីវភាពមានច្រើនដែរ ដែលតម្រូវឲ្យមានការប៉ះពាល់លើធនធានទាំងនេះ ដូចជាមច្ឆាជាតិត្រូវថយចុះ មូលហេតុ អូរ ទន្លេ រាក់ គោក មិនសូវមានទឹក ម្យ៉ាងការប្រើប្រាស់ថ្នាំ ជីគីមី មិនមានបទដ្ឋានបច្ចេកទេស ការចាប់មកធ្វើម្ហូបទាំងតូចទាំងធំ និង ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ដូចជាការឆក់ ឬអូសស្បៃមុងជាដើម។ល។ ចំពោះការប៉ះពាល់បរិស្ថានវិញ មានប្រជាពលរដ្ឋមួយចំនួនបានទុកដាក់សំរាមគ្មាន សណ្តាប់ធ្នាប់ ម្យ៉ាងដោយមានការបង្ហូរទឹក និងកាកសំណល់ពីផ្ទះចូលក្នុងទន្លេ បានធ្វើឲ្យមានការប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋជាច្រើន។

### ៣.១.៤. ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

ការផ្តល់សេវាជូនប្រជាពលរដ្ឋ រដ្ឋបាលសង្កាត់កោះអន្លង់ចិន បាននឹងកំពុងបម្រើជូនជាប្រចាំ ជាពិសេសនោះ សង្កាត់ មានសាលាសង្កាត់មួយ ដែលជាអំណោយរបស់រាជរដ្ឋាភិបាលកម្ពុជា ផ្តល់ជូនក្រុមប្រឹក្សាសង្កាត់ មិនតែប៉ុណ្ណោះ សប្បុរសជនបានជួយសាងសង់របងខាងមុខ ជូនក្រុមប្រឹក្សាសង្កាត់ថែមទៀត។ លើសពីនេះក្រុមប្រឹក្សាសង្កាត់ បានទទួលវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពយ៉ាងច្រើនថែមទៀត ពីស្ថាប័ននានា របស់រាជរដ្ឋាភិបាល ក៏ដូចជាដៃគូអភិវឌ្ឍ តាមរយៈទីប្រឹក្សាក្រុង មន្ត្រីបច្ចេកទេស និងមន្ត្រីគាំទ្រសង្កាត់ ក្នុងការគាំទ្រ និងជួយតម្រង់ទិសដៅ លើការអភិវឌ្ឍគ្រប់វិស័យជូនសហគមន៍មូលដ្ឋាន។

ទោះបីជាមានការគាំទ្រទាំងសម្ភារៈ និងស្មារតី ជាច្រើនយ៉ាងនេះក្តី សង្កាត់នៅជួបការលំបាកដូចជាៈ ការផ្សព្វផ្សាយលិខិតបទដ្ឋាននានា ការទទួលព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋ មិនទាន់បានល្អប្រសើរ ប្រជាការពារ មិនទាន់មានវគ្គបណ្តុះបណ្តាលស្តីពីតួនាទីភារកិច្ចនៅឡើយ។ ការងារគ្រប់គ្រងប្រជាពលរដ្ឋ មិនទាន់បានល្អ ដោយសារការផ្លាស់ចេញ ចូល របស់ប្រជាពលរដ្ឋ មិនមានការបញ្ជាក់របស់អាជ្ញាធរមូលដ្ឋានឲ្យបានគ្រប់ៗគ្នា ម្យ៉ាងដោយការយល់ដឹងរបស់មន្ត្រីនៅមានកម្រិតនៅឡើយ។ បញ្ហាពាក់ព័ន្ធនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន មក ដល់ពេលនេះប្រជាពលរដ្ឋមួយចំនួនតូច មិនទាន់បានចុះបញ្ជីបញ្ជាក់កំណើត និងអាពាហ៍ពិពាហ៍ ទារកទើប កើតមួយចំនួនតូចមិនបានចុះសំបុត្រកំណើត ទាន់ពេល រហូតដល់ពេលចូលរៀនទើបក្រុមគ្រួសារមកចុះដើម្បី បានចូលរៀន រីឯការទុកដាក់ ថែរក្សាឯកសារអត្រានុកូលដ្ឋានវិញ ពួកគាត់មិនបានទុកដាក់ឲ្យបានហ្មត់ចត់ល្អ នោះទេ ទាំងនេះ គឺបណ្តាលមកពីពួកគាត់មិនមានការយល់ដឹង ពីសារៈសំខាន់របស់ឯកសារនៅឡើយ រីឯ សង្កាត់ពុំមាន ឯកសារជាមូលដ្ឋានដែលអាចបញ្ជាក់ថាគាត់បានចុះហើយឬនៅទេ។

ដោយឡែកចំពោះបញ្ហាសន្តិសុខសណ្តាប់ធ្នាប់ អំពើហឹង្សាក្នុងគ្រួសារនៅមានកើតមានម្តងម្កាល ករណី ក្មេងទំនើងនៅមានតិចតួច ល្បែងស៊ីសងនៅមានលួចលេងជាច្រើន ចោរកម្ម លួចទ្រព្យសម្បត្តិ របស់ប្រជា ពលរដ្ឋពេលយប់ នៅតែកើតមានជារឿយៗ ដែលអំពើទាំងនេះជាបច្ច័យអាក្រក់ ធ្វើឲ្យរាំងស្ទះដល់ការអភិវឌ្ឍ និង សុវត្ថិភាពរបស់ប្រជាពលរដ្ឋ។ ទោះបីជាមានកិច្ចទប់ស្កាត់ពីកម្លាំងសមត្ថកិច្ច និងប្រជាការពារ ក៏សកម្មភាពទាំង នេះ មិនទាន់បានលុបបំបាត់ទាំងស្រុងនៅឡើយទេ ម្យ៉ាងទៀតកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលមានគ្នាតិច និងខ្វះ ការសហការណ៍ ពីសំណាក់ប្រជាពលរដ្ឋទៀតផង។

## ៣.២ ដំណោះស្រាយ

### ៣.២.១ ពង្រឹងផ្នែកសេដ្ឋកិច្ច

សង្កាត់កោះអន្លង់ចិន ស្ថិតនៅទីតាំងមួយដែលមានលក្ខណៈអំណោយផលល្អសម្រាប់ប្រជាជនក្នុង សង្កាត់ ដោយសារតែមានទន្លេព័ទ្ធជុំវិញបង្កឲ្យមានលក្ខណៈងាយស្រួលដល់ការបង្កបង្កើនផលដំណាំកសិកម្ម ផ្សេងៗ។ ក្រៅពីការធ្វើកសិកម្មបងប្អូនប្រជាពលរដ្ឋខ្លះទៀត ធ្វើអាជីវកម្ម រកស៊ីជួញដូរ ខ្លះទៀតបម្រើការងារនៅ ក្នុងវិស័យរដ្ឋ និងវិស័យឯកជន ដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពរស់ប្រចាំថ្ងៃធ្វើឲ្យសេដ្ឋកិច្ចក្នុងគ្រួសាររបស់ ពួកគាត់មានភាពល្អប្រសើរឡើងជាងមុន។ សង្កាត់កោះអន្លង់ចិនមានផ្លូវបេតុងជាច្រើនឆ្លងកាត់ស្ទើរតែទូទាំង សង្កាត់ និងផ្លូវលំជាច្រើន ដែលមានចម្ងាយជាច្រើនម៉ែត្រសម្រាប់តភ្ជាប់ពីភូមិមួយទៅភូមិមួយ សម្រាប់សម្រួល ដល់ការដឹកផលិតផលកសិកម្ម ពាណិជ្ជកម្ម និងការធ្វើដំណើរទូទៅ។ ប្រព័ន្ធគមនាគមន៍ ជាផ្នែកមួយដ៏សំខាន់ នៅក្នុងការនាំទំនិញចេញចូលពីទីរួមស្រុកទៅទីរួមខេត្តជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋទូទៅសម្រាប់ប្រកប របររកស៊ី និងជាមធ្យោបាយប្រើប្រាស់ធ្វើដំណើរទៅមកតាមតម្រូវការ។ នៅក្នុងសង្កាត់កោះអន្លង់ចិន ទទួលបាន

នូវសមិទ្ធផលផ្លូវបេតុងទូទាំងសង្កាត់សម្រេចបាន៧០% មានទទឹងប្រវែង ៤ម៉ែត្រ ខ្លះ ៥ម៉ែត្រ ហើយក៏កំពុងតែបន្តកសាងបន្ថែមទៀត ពិសេសនៅចុងឆ្នាំ២០២១នេះនឹងដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវស្ពានក្រវាត់ក្រុងទី៣ (ស្ពានឆ្លងទន្លេ) នៅភូមិស្វាយពុំត្រង់។ ទោះបីជាមានផ្លូវបេតុងខ្វាត់ខ្វែងសម្រាប់ប្រើប្រាស់ក៏ពិតមែន ប៉ុន្តែការធ្វើដំណើរចេញចូល ក៏ដូចជាការដឹកទំនិញចេញចូលក្នុងសង្កាត់នៅតែការលំបាកដោយសារតែសង្កាត់នេះជាកោះមួយដែលមានទន្លេព័ទ្ធជុំវិញ រាល់ការធ្វើដំណើរទៅមកគឺត្រូវឆ្លងតាមទូកដរ ឬសាឡាង ចំណែកឯផ្លូវក្នុងសង្កាត់មួយចំនួនក៏ខូចខាត ត្រូវការជួសជុល កែលម្អបន្ថែមទៀត។ ដូច្នេះអាជ្ញាធរសង្កាត់ត្រូវតែសហការជាមួយអង្គភាពដែលពាក់ព័ន្ធនានា ដើម្បីស្វែងរកប្រភពធនធាន ដើម្បីធ្វើការជួសជុលផ្លូវដែលមានលក្ខណៈចាស់ទ្រុឌទ្រោម កសាងផ្លូវនិងស្ពានបន្ថែមទៀត ដើម្បីបង្កភាពងាយស្រួលដល់បងប្អូនប្រជាពលរដ្ឋធ្វើចរាចរណ៍ទៅមកប្រកបដោយសុវត្ថិភាព។

### ៣.២.២ ពង្រឹងផ្នែកសង្គមកិច្ច

**វិស័យសុខាភិបាល** : ការថែទាំសេវាសុខាភិបាល និងការលើកកម្ពស់ផ្នែកសុខភាពពិតជាមានសារៈសំខាន់ណាស់ ចំពោះប្រជាពលរដ្ឋនៅក្នុងសង្កាត់ សម្រាប់សម្រាកព្យាបាលពេលមានជំងឺឈឺថ្កាត់ផ្សេងៗ។ ជាក់ស្តែង ក្រុមប្រឹក្សាសង្កាត់កោះអន្លង់ចិនបានខិតខំប្រឹងប្រែង និងស្វែងរកដំណោះស្រាយព្រមទាំងសហការគ្នាជាមួយមន្ទីរសុខាភិបាលខេត្តដែលចំណុះឲ្យក្រសួងសុខាភិបាលដើម្បីជំរុញ និងបង្កើតឲ្យមានមណ្ឌលសុខភាពមួយសម្រាប់សង្កាត់ងាយស្រួលដល់ប្រជាពលរដ្ឋពេលត្រូវការផ្នែកសេវាសុខភាព មិនចាំបាច់ទៅឃុំផ្សេងដែលធ្វើឲ្យខាតពេលវេលា និងពិបាកធ្វើដំណើរទៅមក។ ហេតុនេះអាជ្ញាធរសង្កាត់ត្រូវអនុវត្តសកម្មភាពដូចជា ជំរុញផ្សព្វផ្សាយអំពីសុខភាពបន្តពូជដល់ស្ត្រី និងកុមារចាក់វ៉ាក់សាំងការពារ ជំងឺតេតាណុស ស្ត្រីពិនិត្យផ្ទៃពោះ និងសម្រាលកូននៅមណ្ឌលសុខភាព។ លើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភរបស់ស្ត្រី និងកុមារតាមរយៈផ្តល់គ្រាប់ថ្នាំជីវជាតិអា ដល់កុមារអាយុ ៦-៩ខែ ឲ្យបានគ្រប់គ្នា និងផ្តល់គ្រាប់ថ្នាំជាតិដែកដល់ស្ត្រីដែលមានផ្ទៃពោះ។ ពង្រឹងប្រព័ន្ធសុខាភិបាលតាមរយៈបង្កើនការផ្តល់សេវា និងលទ្ធភាពទទួលបានសេវាសុខាភិបាលជូនប្រជាពលរដ្ឋក្រីក្រនៅក្នុងការប្រើប្រាស់មូលនិធិសមធម៌។ មួយវិញទៀត គឺត្រូវធ្វើការផ្សព្វផ្សាយពីផលប៉ះពាល់ជំងឺឆ្លងដូចជា របេងអេដស៍ ផ្តាសាយបក្សី គ្រោះថ្នាក់ផ្សេងៗទៀត និងមានការប្រុងប្រយ័ត្ន អំពីផលប៉ះពាល់ ការប្រែប្រួលអាកាសធាតុ និងឧស្ម័នពុលក្នុងបរិយាកាស។ ត្រូវផ្តល់សេវាព្យាបាលជំងឺជូនប្រជាពលរដ្ឋទូទៅនៅមណ្ឌលសុខភាពប្រកបដោយវិជ្ជាជីវៈពេទ្យ។ បង្កើតប៉ុស្តិ៍ចល័តនៅពេលជួបប្រទះដោយគ្រោះធម្មជាតិដូចជា ទឹកជំនន់ជាដើម។

**វិស័យអប់រំ** : ជាវិស័យមួយដែលជួយពង្រឹងការអប់រំនៅក្នុងមូលដ្ឋានឲ្យកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបបានទៅនឹងតម្រូវការ នៃការសិក្សារបស់សិស្សានុសិស្សដែលចង់ក្រេបយកចំណេះវិជ្ជាមកដាក់ខ្លួន និងដើម្បីអភិវឌ្ឍខ្លួនឲ្យក្លាយទៅជាមនុស្សដែលមានសមត្ថភាពដែលសង្គមគេត្រូវការ។ ដោយឡែក បើក្រលេកមើលមកក្នុងសង្កាត់កោះអន្លង់ចិនយើងសង្កេតឃើញថា អត្រានៃការអប់រំសម្រាប់កុមារ គឺនៅមិនទាន់មានភាពល្អប្រសើរនៅ

ឡើយទេ ដោយសារតែសាលារៀនមានចំនួនតិច ឯខ្លះទៀតក៏ចាស់ទ្រុឌទ្រោម គ្មានសោភ័ណភាពល្អ និងមិនធានាសុវត្ថិភាពដល់សិស្សក៏ដូចជាលោកគ្រូ អ្នកគ្រូដែលកំពុងរៀន។ ចំណែកឯកុមារមួយចំនួនទៀតបោះបង់ចោលការសិក្សា ព្រោះតែបញ្ហាជីវភាពខ្វះខាត ហើយឪពុកម្តាយមួយចំនួនតូចមិនផ្តល់ឱកាសឲ្យកូនបានរៀនសូត្រ និងមិនឲ្យតម្លៃលើការអប់រំ។ ដូច្នេះអាជ្ញាធរមូលដ្ឋានថ្នាក់សង្កាត់ត្រូវយកចិត្តទុកដាក់ទៅលើបញ្ហាទាំងអស់នេះ ហើយចូលរួមសហការគ្នា ជាមួយមន្ទីរអប់រំស្រុកចំណុះឲ្យមន្ទីរអប់រំខេត្ត ដែលខ្លួនកាន់កាប់ ត្រូវស្វែងរកដំណោះស្រាយរាល់បញ្ហាចំពោះមុខ ដើម្បីឆ្លើយតបទៅតាមតម្រូវការទីផ្សារពលកម្មការងារ ហើយបានគិតគូរទៅលើចំណុចសកម្មភាពសំខាន់ៗសម្រាប់អនុវត្តដូចជា ធ្វើយុទ្ធនាការគ្រប់រូបភាពប្រមូលកុមារឲ្យចូលរៀនបានតាមចំណុចដៅរបស់ក្រសួងអប់រំ តាមរយៈការផ្សព្វផ្សាយអំពីតម្លៃនៃការអប់រំ។ ទទួលចុះឈ្មោះចូលរៀនដោយឥតបង់ថ្លៃ ប្រមូលទិន្នន័យពីកុមារ និងការចុះប្រមូលកុមារនៅតាមផ្ទះ ព្រមទាំងបង្កើតឲ្យមានថ្នាក់មត្តេយ្យសិក្សាសហគមន៍បន្ថែមទៀតនៅតាមភូមិនីមួយៗ ជ្រើសរើសគ្រូមត្តេយ្យ ឧបត្ថម្ភគាំទ្រ និងលើកទឹកចិត្តគ្រូដែលមានស្នាដៃល្អ។ ជំរុញលើកទឹកចិត្តដល់កុមារអាយុ ៦-១៤ឆ្នាំ ឲ្យចូលរៀនបានគ្រប់ៗគ្នា តាមរយៈការបង្កើតសាលាទៅជាសាលាកុមារមេត្រី។ ពង្រឹងការអនុវត្តកម្មវិធីសិក្សា ម៉ោងសិក្សា ជួយសិស្សរៀនយឺតជួបការលំបាកឲ្យចំគោលដៅ តាមការពង្រឹងក្រមសីលធម៌វិជ្ជាជីវៈដល់គ្រូបង្រៀន ត្រូវធ្វើអធិការកិច្ចសិក្សាជាប្រចាំនៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យ។ មួយវិញទៀតត្រូវរៀបចំឲ្យមានការលើកទឹកចិត្តដល់កុមារក្រីក្រ ដូចជា ផ្តល់ជាអាហារូបករណ៍ដល់សិស្ស និងមានរង្វាន់លើកទឹកចិត្តដល់សិស្សដែលរៀនពូកែ ជាពិសេស បង្កើតឲ្យមានបណ្ណាល័យសម្រាប់សិស្សសិក្សានៅតាមសាលានីមួយៗ។

### ៣.២.៣ ពង្រឹងការថែទាំធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

កត្តាអវិជ្ជមានទាំងឡាយដែលកើតមានឡើង គឺបណ្តាលមកពីការខ្វះការយល់ដឹងពីច្បាប់បរិស្ថាន និងច្បាប់នានា ហើយការផ្សព្វផ្សាយច្បាប់នេះទៀត មិនទាន់បានទូលំទូលាយ និងស៊ីជម្រៅដល់ប្រជាពលរដ្ឋដោយផ្ទាល់នៅឡើយដែរ។ ចំពោះផលវិបាកដែលបានកើតមានឡើងទាំងអស់នេះ ក្រុមប្រឹក្សាសង្កាត់ ត្រូវតែស្វែងរកការគាំទ្រពីស្ថាប័នជំនាញពាក់ព័ន្ធ ដើម្បីមានវិធានការជួយអប់រំ ផ្សព្វផ្សាយ បណ្តុះបណ្តាលដល់ប្រជាពលរដ្ឋឲ្យមានការយល់ដឹង។ សង្កាត់ត្រូវពង្រឹងសហគមន៍ឡើងវិញ ធ្វើការរៀបចំផ្សព្វផ្សាយច្បាប់បរិស្ថាន រៀបចំឲ្យមានអនាម័យ មានសោភ័ណភាព ជាពិសេសមានការរស់នៅស្អាត ហូបស្អាត ខិតខំរិះរកគ្រប់មធ្យោបាយ ដើម្បីការពារថែរក្សាក្នុងគោលបំណងធានាបាននូវ និរន្តរភាពជីវភាព សុខភាព និងការរស់នៅ ប្រកបដោយបរិស្ថានល្អបរិសុទ្ធ។ មួយវិញទៀតក្រុមប្រឹក្សាសង្កាត់ ត្រូវពង្រឹងរក្សាការពារធនធានធម្មជាតិ ធ្វើការផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋបានយល់ដឹង និងចេះថែរក្សា ហើយត្រូវបង្កើតឲ្យមាននៅសហគមន៍ សម្រាប់ដឹកនាំប្រជាពលរដ្ឋ បង្កើនការដាំដើមឈើ ជៀសវាងការកាប់គាស់ដីព្រៃ លុបបំបាត់ការនេសាទខុសច្បាប់ក្នុងរដូវត្រីពង បញ្ឈប់ការប្រើប្រាស់ជីគីមី ដែលមិនមាន

បទដ្ឋានបច្ចេកទេស និងការចោលសំរាម ក៏ដូចជាការបង្ហូរទឹក និងកាកសំណល់ពីផ្ទះចូលទៅក្នុងទន្លេ ដោយគ្មានសណ្តាប់ធ្នាប់ ដើម្បីកុំឲ្យមានផលប៉ះពាល់ដល់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ម្យ៉ាងទៀត ដើម្បីបញ្ចៀសនូវបញ្ហាប្រឈមពីគ្រោះមហន្តរាយផ្សេងៗដែលកើតឡើងពីការប្រែប្រួលអាកាសធាតុ ក្រុមប្រឹក្សាសង្កាត់ ត្រូវរៀបចំនូវយន្តការសម្រាប់ជួយធ្វើអន្តរាគមន៍ជាបន្ទាន់ដូចជា ជួយឧបត្ថម្ភសម្ភារៈជាបឋម ជួយសង្គ្រោះជិត ព្រមទាំងណែនាំប្រជាពលរដ្ឋឲ្យមានការប្រុងប្រយ័ត្ននឹងគ្រោះថ្នាក់ផ្សេងៗ ជាពិសេស មានវិធានការបង្ការត្រៀម សម្រាប់ឆ្លើយតបនៅពេលកើតមានគ្រោះអាសន្ន។ លើសពីនេះទៅទៀត អាជ្ញាធរមូលដ្ឋាន សហការគ្នាជាមួយកាកបាទក្រហមកម្ពុជា ព្រមទាំងសប្បុរសជននានាដើម្បីជួយសម្រួលរាល់ការខ្វះខាតរបស់ប្រជាពលរដ្ឋ ដែលរងគ្រោះដោយសារខ្យល់ព្យុះខ្យល់កន្ត្រាក់ ទឹកជំនន់ ភ្លើងឆេះជាដើម។

### ៣.២.៤ បង្កើនប្រសិទ្ធភាពការងាររដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ដើម្បីបង្កើនការគ្រប់គ្រងរដ្ឋបាលថ្នាក់សង្កាត់ឲ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល នោះក្រុមប្រឹក្សាសង្កាត់ ត្រូវបង្កើតឲ្យមានវគ្គបណ្តុះបណ្តាលខ្លីៗជូនពួកគាត់ឲ្យបានរៀងរាល់មួយខែម្តងទាំងផ្នែកបច្ចេកទេស និងលិខិតបទដ្ឋាន។ ក្រុមប្រឹក្សាសង្កាត់ ត្រូវធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយ ទាក់ទងទៅនឹងការធ្វើសំបុត្រអត្រានុកូលដ្ឋាននៅតាមបណ្តាភូមិនីមួយៗជុំវិញ និងលើកទឹកចិត្តដល់ពួកគាត់មកធ្វើសំបុត្រអត្រានុកូលដ្ឋានឲ្យបានគ្រប់ៗគ្នា។ ជាងនេះទៅទៀតសង្កាត់ត្រូវមានវិធានការ និងការអនុវត្តយ៉ាងតឹងរឹងរាល់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឲ្យទទួលបាននូវសិទ្ធិស្មើគ្នាមានភាពស្មោះត្រង់ យុត្តិធម៌ មិនលំអៀង និង ឯករាជ្យភាព បង្កើនការយល់ដឹងពីការផ្តល់សេវារដ្ឋបាល និងតម្លៃសេវារដ្ឋបាលឲ្យបានទូលំទូលាយ។ ការអនុវត្តការងាររដ្ឋបាលទទួលបានជោគជ័យនេះ ដោយសារតែមានកំណែទម្រង់រដ្ឋបាល តាមយុទ្ធសាស្ត្រស៊ីជម្រៅរបស់រាជរដ្ឋាភិបាលធ្វើយ៉ាងណាបង្គិតជិតប្រជាពលរដ្ឋ និងងាយស្រួលក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ ដើម្បីពង្រឹងសមត្ថភាពរបៀបរបបការងារប្រចាំថ្ងៃ ប្រចាំខែ ជាពិសេស ជួយពង្រឹង និងគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់ផ្តល់សេវាជូនប្រជាពលរដ្ឋនៅមូលដ្ឋាន។

ដើម្បីរក្សាសន្តិសុខសណ្តាប់ធ្នាប់នៅក្នុងសង្កាត់កោះអន្លង់ចិន ឲ្យប្រកបទៅដោយសុខសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងសង្កាត់ ក្រុមប្រឹក្សាសង្កាត់បានអនុវត្តនូវគម្រោងទប់ស្កាត់រាល់បញ្ហាអសន្តិសុខមួយចំនួនដូចជា បង្កើតឲ្យមានបញ្ជាការពារតាមភូមិ លុបបំបាត់ល្បែងស៊ីសងគ្រប់ប្រភេទ ចុះធ្វើការផ្សព្វផ្សាយតាមបណ្តាភូមិពីការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ការជួញដូរផ្លូវភេទ ដោយសហការពីប្រជាពលរដ្ឋក្នុងការផ្តល់ជាដំណឹងចំពោះជនណាដែលចូលមកថ្មី ជាពិសេសអាជ្ញាធរមូលដ្ឋានបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់អនុវត្តយ៉ាងហ្មត់ចត់ទៅតាម « គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព » ដែលមានលក្ខណៈសម្បត្តិ ៩ចំណុចដូចខាងក្រោមនេះ៖

- គ្មានសកម្មភាព លួច ឆក់ ប្លន់គ្រប់ប្រភេទ
- គ្មានការផលិត ការចែកចាយ និង ប្រើប្រាស់គ្រឿងញៀនខុសច្បាប់

- គ្មានអំពើអាណាចារ្យ អំពើហឹង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ
- គ្មានក្មេងទំនើង
- គ្មានការលេងល្បែងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
- គ្មានគ្រោះថ្នាក់ចរាចរណ៍
- គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះ
- មានវិធានការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
- គ្មានការត្រួតពិនិត្យខុសច្បាប់

ការអនុវត្តបាននូវវិធានការគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពទាំង ៩ចំណុចនេះហើយ គឺជាហេតុដែលនាំឲ្យការគ្រប់គ្រងនៅក្នុងសង្កាត់ មានការអភិវឌ្ឍប្រកបទៅដោយសុខសន្តិភាព មានរបៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ និងមានអភិបាលកិច្ចល្អសម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋាន ទទួលបាននូវសេចក្តីសុខ និងសេចក្តីចម្រើនក្នុងក្រុមគ្រួសារ។

## ៣.៣. ទិសដៅទៅអនាគត

ការងារតាមវិស័យផ្សេងៗនៅក្នុងសង្កាត់កោះអន្លង់ចិន ផ្អែកទៅតាមផែនការអភិវឌ្ឍន៍ឃុំ សង្កាត់បានសម្រេចលទ្ធផលវិជ្ជមានមួយចំនួនសដូចជា ផ្លូវបេតុងទូទាំងសង្កាត់ ស្ពានឆ្លងទន្លេ ក្រៅពីនោះរួមមាន ការចុះសំបុត្រអត្រានុកូលដ្ឋាន ការរៀបចំចុះបញ្ជីដីធ្លី ចេញប័ណ្ណកម្មសិទ្ធិលក្ខណៈជាប្រព័ន្ធ ការទទួលបានមូលនិធិពីសប្បុរសជន និងអង្គការសង្គមស៊ីវិលកន្លងមក សម្រាប់បម្រើលើវិស័យកសិកម្ម សុខាភិបាល និងអនាម័យជាដើម។ ទោះបីជាយ៉ាងណាក្តី ក៏នៅមានការងារមួយចំនួនដែលពុំទាន់បានសម្រេចជាដុំកំភួននៅឡើយ ជាពិសេសបញ្ហាសុខាភិបាល បញ្ហាបរិស្ថាន បញ្ហាសន្តិសុខ និងបញ្ហាធនធានមនុស្ស។ ក្នុងទិសដៅជំរុញឲ្យការផ្តល់សេវាសាធារណៈរបស់សង្កាត់ រួមទាំងការអភិវឌ្ឍឲ្យមានភាពល្អប្រសើរទៅថ្ងៃអនាគតអាជ្ញាធរសង្កាត់ ព្រមទាំងអាជ្ញាធររដ្ឋបាលថ្នាក់ជាតិ និងស្ថាប័នពាក់ព័ន្ធគួរពិចារណាទៅលើចំណុច៣ ជាសំខាន់រួមមាន ទី១.ការបណ្តុះបណ្តាលធនធានមនុស្ស ទី២.ការបង្កើនថវិកាសង្កាត់ និងទី៣.ការបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាសង្កាត់។

### ៣.៣.១. ការបណ្តុះបណ្តាលធនធានមនុស្ស

បើទោះបីជាយើងបានដឹងហើយថាការគ្រប់គ្រងនៅក្នុងមូលដ្ឋានដោយតំណាង ដែលកើតឡើងពីសម្លេងគាំទ្ររបស់ប្រជាពលរដ្ឋ ដើម្បីសបញ្ជាក់ពីលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានពិតមែន ប៉ុន្តែបុគ្គលដែលបានជ្រើសរើសមួយចំនួន ពុំទាន់មានសមត្ថភាពពេញលេញក្នុងការគ្រប់គ្រងដែនដីរបស់ខ្លួនឲ្យមានលក្ខណៈល្អប្រសើរនៅឡើយទេ ជាក់ស្តែង អ្នកឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ច្បាប់ពុំចាំបាច់ទាមទារតម្រូវឲ្យជននោះមានចំណេះដឹងកម្រិតសញ្ញាបត្រខ្ពង់ខ្ពស់នោះទេ យ៉ាងហោចណាស់ត្រឹមអាចអាន និងសរសេរភាសាខ្មែរ

បានគ្រប់គ្រាន់ហើយ។ ដូច្នេះ ជាទិសដៅខ្លីទៅមុខរដ្ឋបាលថ្នាក់ជាតិដែលមានក្រសួងមហាផ្ទៃជាអ្នកដឹកនាំការងារនេះ គួរតែបើកវគ្គបណ្តុះបណ្តាលសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធលើការប្រមូលចំណូល ការរៀបចំនូវគម្រោងថវិកា គម្រោងអភិវឌ្ឍន៍គម្រោងវិនិយោគប្រចាំឆ្នាំជាដើម។ល។ រីឯទិសដៅនៅក្នុងរយៈពេលវែងវិញ គឺធ្វើការកែប្រែច្បាប់ដោយកំណត់លក្ខខណ្ឌតម្រូវ សម្រាប់បេក្ខជនឈរឈ្មោះជាក្រុមប្រឹក្សាឃុំសង្កាត់ត្រូវមានសញ្ញាបត្រអាចត្រឹមមធ្យមសិក្សាទុតិយភូមិ ឬអាចទៅដល់សញ្ញាបត្របរិញ្ញាបត្រដែលមានជំនាញពាក់ព័ន្ធនឹងរដ្ឋបាលសាធារណៈ សេដ្ឋកិច្ច ឬការទូត។

### ៣.៣.២. ការបង្កើនថវិកាសង្កាត់

យោងតាមអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ត្រង់មាត្រា២០ បានចែងថា ឃុំ សង្កាត់មានប្រភពធនធានមកពីភូមិទាំងអស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន ឃុំ សង្កាត់ផ្សេងៗ រាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធនានានៃរាជរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិនានា ផ្នែកឯកជន និងសប្បុរសជននានាជាដើម។ ថ្វីត្បិតមើលទៅប្រភពធនធានរបស់សង្កាត់ហាក់ដូចជាច្រើន ប៉ុន្តែបើតាមជាក់ស្តែងចំណូលថវិការបស់សង្កាត់ជាទូទៅបានមកពីការឧបត្ថម្ភធនធានពីរាជរដ្ឋាភិបាល និងកម្រៃសេវារដ្ឋបាលផ្សេងៗដូចជា ការងារអត្រានុកូលដ្ឋាន និងការចេញលិខិតអនុញ្ញាតនានាដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ។ បច្ចុប្បន្នថវិការបស់សង្កាត់អាចត្រឹមតែធានាបានពីប្រក្រតីភាពនៃដំណើរការរដ្ឋបាលរបស់ខ្លួនតែប៉ុណ្ណោះ។ ប៉ុន្តែ នៅពុំទាន់អាចឆ្លើយតបចំពោះការអភិវឌ្ឍនៅថ្នាក់មូលដ្ឋានឲ្យបានពេញលេញនៅឡើយទេ ព្រោះតម្រូវការអភិវឌ្ឍរបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការស្តារ និងរៀបចំប្រព័ន្ធធារាសាស្ត្រ ការកសាងនិងជួសជុលផ្លូវ ស្ពាន និងការរៀបចំឲ្យមានភ្នាក់ងារប្រមូលសំរាមជាដើម គឺត្រូវចំណាយថវិកាខ្ពស់ហួសពីសមត្ថភាពជាក់ស្តែងរបស់សង្កាត់ទៅទៀត។ ដូច្នេះ ដើម្បីអាចធានាបានពីការអភិវឌ្ឍឲ្យបានពេញលេញនៅមូលដ្ឋាន រាជរដ្ឋាភិបាលគួរពិនិត្យលទ្ធភាពនៅក្នុងការបង្កើនថវិកាបន្ថែមសម្រាប់សង្កាត់ទោះបីជាផ្តល់នៅក្នុងរូបភាពឧបត្ថម្ភធនាន និងការផ្តល់ជំនួយលើគម្រោងនានាក្តី។

### ៣.៣.៣. ការបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាសង្កាត់

ការគ្រប់គ្រងរដ្ឋបាលសង្កាត់ត្រូវបានអនុវត្តទៅតាមបែបវិមជ្ឈការ ដែលមានន័យថាសង្កាត់ទទួលបាននូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធានពីថ្នាក់ជាតិ។ ប៉ុន្តែ បើតាមភាពជាក់ស្តែងយើងសង្កេតឃើញថាភាពជាម្ចាស់ និងការទទួលខុសត្រូវទាំងនេះហាក់នៅមានកម្រិតនៅឡើយ ដោយហេតុថាសង្កាត់មិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលបន្ទុកលើការងាររបស់ខ្លួន បូករួមទាំងភាពស្ទាក់ស្ទើរនៃការធ្វើវិមជ្ឈការអំណាចពីថ្នាក់ជាតិផង។ ជាការពិតណាស់ ការបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាសង្កាត់នឹងធ្វើឲ្យការផ្តល់សេវាសាធារណៈនៅថ្នាក់សង្កាត់កាន់តែមានភាពល្អប្រសើរ។ ដូច្នេះ សម្រាប់ជាមធ្យោបាយ នា

ពេលអនាគតដ៏ប្រសើរក្រុមប្រឹក្សាសង្កាត់ត្រូវចេះពង្រឹងសមត្ថភាពរបស់ខ្លួនតាមរយៈការសិក្សាស្វែងយល់ឲ្យកាន់តែស៊ីជម្រៅពីច្បាប់ និងលិខិតបទដ្ឋាននានា ដើម្បីបង្ហាញពីសមត្ថភាពនៃការទទួលខុសត្រូវទាំងផ្នែករដ្ឋបាល និងផ្នែកព្រហ្មទណ្ឌលើការងាររបស់ខ្លួន។ ជាមួយគ្នានេះផងដែរ គណៈកម្មាធិការជាតិគាំទ្រសង្កាត់ត្រូវជំរុញយន្តការនៃការបែងចែកភារកិច្ចជាក់លាក់រវាងរដ្ឋបាលថ្នាក់កណ្តាល ថ្នាក់រាជធានី ខេត្តក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ដើម្បីកំណត់ឲ្យបានកាន់តែច្បាស់អំពីភាពជាម្ចាស់របស់ក្រុមប្រឹក្សាឃុំ សង្កាត់។ទន្ទឹមនឹងនេះផងដែរ ក្រសួងស្ថាប័ននៅថ្នាក់ជាតិ គួរធ្វើកិច្ចសហប្រតិបត្តិការជាមួយគណៈកម្មាធិការជាតិគាំទ្រសង្កាត់ក្នុងការផ្ទេរភារកិច្ចក្នុងកម្រិតណាមួយដល់ក្រុមប្រឹក្សាសង្កាត់ នៅវិស័យដែលមានភាពជាប់ពាក់ព័ន្ធផ្ទាល់ជាមួយនឹងប្រជាពលរដ្ឋដូចជា វិស័យកសិកម្ម វិស័យអប់រំ វិស័យសុខាភិបាល និងវិស័យសង្គមកិច្ចជាដើម ដើម្បីឲ្យសង្កាត់អាចផ្តល់នូវសេវាទាំងនោះប្រកបដោយការទទួលខុសត្រូវនៅក្នុងមូលដ្ឋានរបស់ខ្លួន។ និយាយជារួមមកវិញ ទន្ទឹមនឹងការរីកចម្រើនរបស់សង្កាត់កោះអន្លង់ចិន ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍសង្កាត់នៅមានបញ្ហាប្រឈមនៅលើផ្នែកសំខាន់ៗ រួមមានដូចជា៖ វិស័យអប់រំ វិស័យសុខាភិបាល ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ផ្លូវគមនាគមន៍ ប្រព័ន្ធទឹកស្អាត បញ្ហាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសកម្មភាពនានាក្នុងសង្កាត់ នៅមានកម្រិតនៅឡើយ ហើយទាំងអស់នេះ សុទ្ធសឹងតែជាបញ្ហាដែលទាមទារឲ្យមានដំណោះស្រាយឲ្យបានសមស្រប ឬការចាត់វិធានការដោះស្រាយជាបន្តបន្ទាប់ សំដៅធ្វើយ៉ាងណាដើម្បីកុំឲ្យបញ្ហាទាំងនោះរីករាលដាលក្លាយទៅជាឧបសគ្គរារាំងឃាំងឃាត់ទៅដល់ដំណើរការអភិវឌ្ឍន៍សង្កាត់។ នៅក្នុងការដោះស្រាយបញ្ហាចំពោះមុខពិតជាមានសារៈសំខាន់ណាស់ ប៉ុន្តែជាការចាំបាច់នោះ អាជ្ញាធរសង្កាត់គួរតែពិនិត្យមើលទៅលើលទ្ធភាពនៅក្នុងការរៀបចំផែនការការងារសម្រាប់អនុវត្តនៅក្នុងពេលខាងមុខ ដើម្បីធ្វើជាចក្ខុវិស័យចង្អុលទិសបង្ហាញផ្លូវឆ្ពោះទៅរកការរីកចម្រើនប្រកបដោយចិរភាព។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការបកស្រាយ និងសិក្សាស្រាវជ្រាវទៅលើប្រធានបទ **ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការក្នុងសង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្ដាល** រួចមក យើងខ្ញុំអាចសន្និដ្ឋានបានថា សកម្មភាពការងារនៅក្នុងការគ្រប់គ្រងរដ្ឋបាលរបស់សង្កាត់ពិតជាមានភាពល្អប្រសើរហើយ ដោយអនុវត្តទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានខិតខំរៀបចំដាក់ចេញដើម្បីធ្វើការបម្រើប្រជាពលរដ្ឋ ដែលទាំងនេះជាការបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមជនបទ ជាពិសេសគឺការអនុវត្តនូវគោលនយោបាយវិមជ្ឈការក្នុងការគ្រប់គ្រងឃុំ សង្កាត់នៅតាមមូលដ្ឋានដែលជារដ្ឋបាលថ្នាក់ក្រោមជាតិមួយដ៏សំខាន់ដើម្បីជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋបានចូលរួមសកម្មភាពយ៉ាងពេញលេញនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តណាមួយដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍសង្កាត់របស់ខ្លួន ដែលនេះជាដំណើរការជំរុញឲ្យមានលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សនៅមូលដ្ឋាន។ មួយវិញទៀត ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នេះជាមូលដ្ឋានគ្រឹះដើម្បីរួមចំណែកនៅក្នុងការអភិវឌ្ឍប្រទេសជាតិឲ្យមានការរីកចម្រើន និងមានស្ថិរភាពផងដែរ។ ជាងនេះទៅទៀតនោះនៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការនេះបានឈានទៅរកការកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងលើកកម្ពស់ការអភិវឌ្ឍនៅមូលដ្ឋាន ដើម្បីជំរុញការអភិវឌ្ឍខឿនសេដ្ឋកិច្ចជាតិឲ្យមានសន្ទុះខ្លាំងក្លារីកចម្រើនជឿនលឿនទៅមុខ។ ផ្អែកទៅតាមការសិក្សាស្រាវជ្រាវទៅលើទ្រឹស្តី និងការចុះទៅដល់ទីតាំងផ្ទាល់នៃសង្កាត់កោះអន្លង់ចិន (ខេត្តកណ្តាល) សង្កេតឃើញថា ការអភិវឌ្ឍមានភាពជឿនលឿនទៅមុខពីមួយអាណត្តិទៅមួយអាណត្តិគួរឲ្យកត់សម្គាល់ ដែលនេះសរបញ្ជាក់ឲ្យឃើញថា ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការនេះពិតជាទទួលបាននូវផ្លែផ្កាល្អប្រសើរស្របតាមការចង់បានរបស់រាជរដ្ឋាភិបាល។ ជាក់ស្តែង នៅក្នុងសង្កាត់កោះអន្លង់ចិនអាណត្តិនេះ បានប្រែក្លាយអភិវឌ្ឍស្ទើរគ្រប់វិស័យ ដែលសុទ្ធសឹងជាសរសៃឈាមនៃការអភិវឌ្ឍមូលដ្ឋានសង្កាត់។ មិនតែប៉ុណ្ណោះ ក្រោមការដឹកនាំ និងគ្រប់គ្រងរបស់ក្រុមប្រឹក្សាសង្កាត់នៅក្នុងអាណត្តិនេះយើងសង្កេតឃើញថាក្រុមប្រឹក្សាសង្កាត់ បានខិតខំប្រឹងប្រែងបំពេញការងារភារកិច្ចរបស់ខ្លួនយ៉ាងយកចិត្តទុកដាក់នៅក្នុងការបម្រើប្រជាពលរដ្ឋ តាមរយៈការផ្តល់សេវាសាធាណៈផ្សេងៗ ព្រមទាំងដោះស្រាយបញ្ហាប្រឈម និងការលំបាកនានាជូនប្រជាពលរដ្ឋឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ហើយនេះពិតជាបង្ហាញយ៉ាងច្បាស់ពីការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាសង្កាត់នៅក្នុងដំណើរការគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន ឲ្យប្រព្រឹត្តទៅបានរលូន។ លើសពីនេះទៅទៀត ប្រជាពលរដ្ឋដែលរស់នៅក្នុងសង្កាត់កោះអន្លង់ចិន ទទួលបាននូវសិទ្ធិយ៉ាងទូលំទូលាយនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា ដែលទាក់ទងទៅដល់ការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ខ្លួន ព្រមទាំងបានចូលរួមផ្តល់មតិយោបល់ទៅកិច្ចការជាច្រើន និងលើកសំណូមពរនានាដែលទាក់ទងទៅនឹងផលប្រយោជន៍របស់ពួកគាត់ផ្ទាល់។ ទោះបីជា

ក្រុមប្រឹក្សាសង្កាត់ បានខិតខំប្រឹងប្រែងដោះស្រាយបញ្ហាការលំបាកនានាជាច្រើនដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានយ៉ាងណាក៏ដោយ ក៏នៅតែមានចំណុចខ្លះ ផ្នែកខ្លះ អាជ្ញាធរមូលដ្ឋានមិនទាន់បានធ្វើការដោះស្រាយរួចរាល់ហើយដែរ។

សរុបសេចក្តីមក ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ តាមបែបវិមជ្ឈការក្នុងសង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល ដែលកំពុងតែដឹកនាំដោយក្រុមប្រឹក្សាសង្កាត់នៅអាណត្តិនេះ ពិតជាមានលក្ខណៈល្អប្រសើរដែលសម្រេចបាននូវសមិទ្ធផលនានាជាច្រើនសម្រាប់ការអភិវឌ្ឍនៅក្នុងសង្កាត់នេះទាំងមូល ព្រមទាំងបានដោះស្រាយបញ្ហាការលំបាកមួយចំនួនធំដល់ប្រជាពលរដ្ឋផងដែរ ក៏ប៉ុន្តែទន្ទឹមនឹងមានការរីកចម្រើនក៏នៅមានចំណុចខ្វះខាតមួយចំនួនដែលសង្កាត់ត្រូវធ្វើការដោះស្រាយ និងកែលម្អដើម្បីឲ្យមានភាពល្អប្រសើរឡើងថែមទៀតនាថ្ងៃអនាគត និងរហូតតទៅ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានចុះទៅស្រាវជ្រាវនៅសង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្ដាលនៃការសិក្សាស្រាវជ្រាវលើប្រធានបទ «ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការក្នុងសង្កាត់កោះអន្លង់ចិន» រួចមកហើយនេះ យើងខ្ញុំយល់ឃើញថា មិនទាន់មានលក្ខណៈល្អប្រសើរគ្រប់ជ្រុងជ្រោយនៅឡើយទេ ដោយសារនៅមានការខ្វះខាតបន្តិចបន្តួច ដែលរដ្ឋាភិបាលគួរតែយកចិត្តទុកដាក់បន្ថែមទៀត និងបំពេញនូវចំណុចខ្វះខាតទាំងនោះឲ្យបានគ្រប់ជ្រុងជ្រោយ ហើយយើងខ្ញុំសូមចូលរួមចំណែកជាគំនិតមតិយោបល់ខ្លះៗនៅក្នុងការផ្ដល់ជាអនុសាសន៍មួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលសង្កាត់កោះអន្លង់ចិនដូចខាងក្រោមៈ

- រាជរដ្ឋាភិបាល គួរតែបង្កើនខ្ទង់ថវិកានៅក្នុងការអភិវឌ្ឍឃុំ សង្កាត់ឲ្យបានសមស្របទៅតាមតម្រូវការ ជាពិសេសឃុំ សង្កាត់ណាដែលក្រីក្រ និងដាច់ស្រយាលដើម្បីជំរុញការអភិវឌ្ឍឲ្យបានឆាប់រហ័ស
- រាជរដ្ឋាភិបាល គួរតែធ្វើការកែប្រែច្បាប់ ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដោយកំណត់លក្ខខណ្ឌតម្រូវ សម្រាប់បេក្ខជនឈរឈ្មោះជាក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានសញ្ញាបត្រអាចត្រឹមមធ្យមសិក្សាទុតិយភូមិ ឬអាចទៅដល់សញ្ញាបត្របរិញ្ញាបត្រ
- រាជរដ្ឋាភិបាល គួរតែបើកវគ្គបណ្ដុះបណ្ដាលដល់ក្រុមប្រឹក្សា និងបុគ្គលិកឃុំ សង្កាត់ឲ្យបានច្រើនដងដើម្បីបង្កើនសមត្ថភាពការងារ ជាពិសេសផ្នែកបច្ចេកទេស
- ក្រុមប្រឹក្សាឃុំ សង្កាត់គួរតែយកចិត្តទុកដាក់នៅក្នុងការត្រួតពិនិត្យលើការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ ឃុំ សង្កាត់ ដើម្បីឲ្យមានគណនេយ្យភាព និងតម្លាភាព
- ក្រុមប្រឹក្សាឃុំ សង្កាត់គួរតែសិក្សាស្វែងយល់ពី ច្បាប់ លិខិតបទដ្ឋាននានាឲ្យកាន់តែស៊ីជម្រៅ ដើម្បីពង្រឹងបន្ថែមនូវសមត្ថភាព និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការបំពេញការងារ
- ក្រុមប្រឹក្សាឃុំ សង្កាត់គួរតែចុះជួបប្រជាពលរដ្ឋក្នុងមូលដ្ឋានឱ្យបានញឹកញាប់ ដើម្បីយល់ដឹងពីសុខទុក្ខ និងតម្រូវការផ្សេងរបស់ប្រជាពលរដ្ឋ
- ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន គួរតែបង្កើនការយល់ដឹងខ្លះៗបន្ថែមទៀតអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ជាពិសេសត្រូវចេះតាមដានការបំពេញការងាររបស់មន្ត្រីឃុំ សង្កាត់ និង ចូលរួមក្នុងសកម្មភាពផ្សេងៗក្នុងសង្កាត់របស់ខ្លួន។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

២.ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

៣.ព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

៤.ព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

៥.ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

៦.ព្រះរាជក្រមលេខ នស/រកម/១០១៧/១១២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

៧.ព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

៨.ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៩.អនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់ ។

១០.អនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់។

១១.អនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១០ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់។

១២.អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ ស្តីពីការកែប្រែ និងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០១៩។

១៣.អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែប្រែ និងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិក ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០២០។

១៤.អនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែប្រែ និងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល។

១៥.អនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់។

១៦.ប្រកាសលេខ១៣២៩ប្រក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ ស្តីពីតួនាទីភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់។

១៧.ប្រកាសលេខ ១៥០១ ប្រក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលរាជធានីខេត្ត ក្នុងការចាត់ចែងដំណើរការនៃកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិថ្មី។

១៨.ប្រកាសលេខ ១៨៨៤ ប្រក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុងក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់។

១៩.ប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

២០.ប្រកាសណែនាំ ២៣១ សហវប្រក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការងារលទ្ធកម្មរបស់ឃុំ សង្កាត់។

២១.ផែនការណែនាំរបស់ក្រសួងមហាផ្ទៃលេខ ០២០ ផ.ក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ ស្តីពីការចាត់តាំងអនុវត្ត«គោលនយោបាយភូមិឃុំ មានសុវត្ថិភាព»។

២២.សេចក្តីណែនាំស្តីពីបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

២៣.សេចក្តីណែនាំស្តីពី ការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។

២៤.សេចក្តីណែនាំស្តីពី ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

២៥.សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃលេខ ០០៤ស.ណ.ន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ ស្តីពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទីភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ។

**សៀវភៅ**

២៦.សម្តេច ជួន ណាត វចនានុក្រមខ្មែរ ភាគ១&២ បោះពុម្ពលើកទី៥ ឆ្នាំ១៩៦៧។

២៧.បណ្ឌិត សាយ បូរី. នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៤ ឆ្នាំ២០១២។

២៨.បណ្ឌិត ឈុន ណារ៉េត.សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ ឆ្នាំ២០០៦។

២៩. ហៀង សាង. នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៤ ឆ្នាំ២០១៧។

៣០. អ៊ុយ ធឿន. ប្រព័ន្ធរដ្ឋបាលកម្ពុជា ឆ្នាំ២០១៨ ។

៣១. ខាំ សុមករា. រដ្ឋបាលសាធារណៈ ឆ្នាំ២០១៣។

៣២. សៀវភៅណែនាំស្តីពី កិច្ចការរដ្ឋបាលឃុំ សង្កាត់, ខែវិច្ឆិកា ឆ្នាំ២០០៥។

៣៣. សៀវភៅណែនាំស្តីពី ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់, ខែមករា ឆ្នាំ២០០៩។

៣៤. សៀវភៅណែនាំបច្ចេកទេស មូលនិធិឃុំ សង្កាត់។

៣៥. សៀវភៅកម្រងទិន្នន័យឈ្មោះ និងចំនួនរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិនៃព្រះរាជាណាចក្រកម្ពុជា

**ឯកសារផ្សេងៗ**

៣៦. ក្រសួងមហាផ្ទៃ. .មេរៀនការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ. ខែឧសភា ឆ្នាំ២០០៧។

៣៧. ក្រសួងមហាផ្ទៃ..ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ. ខែកក្កដា ឆ្នាំ២០១៧។

៣៨. ក្រសួងមហាផ្ទៃអភិបាលកិច្ចល្អសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ខែវិច្ឆិកា ឆ្នាំ២០០៥។

៣៩. ក្រសួងមហាផ្ទៃ..អភិបាលកិច្ចល្អ បោះពុម្ពលើកទី៤ ខែកុម្ភៈ ឆ្នាំ២០១៣។

៤០. កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២១-២០២៣ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល។

៤១. ការរៀបចំគម្រោងថវិកាឆ្នាំ២០២១ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល។

៤២. ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០១៩-២០២៣ សង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

១.ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

២.អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែប្រែ និងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែ ចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៣.អនុស្សរណៈស្តីពីការរៀបចំគម្រោងថវិកាឆ្នាំ២០២១ របស់សង្កាត់កោះអន្លង់ចិន។

៤.សេចក្តីសម្រេចលេខ ០០១/២១ ស.ស.រ ស្តីពីការបង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកា សង្កាត់កោះអន្លង់ចិន។

៥.សេចក្តីសម្រេចលេខ ០០២/២១ ស.ស.រ ស្តីពីការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ។

៦.សេចក្តីសម្រេចលេខ ០០៣/២១ ស.ស.រ ស្តីពីការបង្កើតគណៈកម្មការលទ្ធកម្មសង្កាត់កោះអន្លង់ចិន។

៧.សេចក្តីសម្រេចលេខ ០០៤/២១ ស.ស.រ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងគម្រោងសង្កាត់កោះអន្លង់ចិន។

៨.កំណត់ហេតុស្តីពី ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលសង្កាត់កោះអន្លង់ចិន (២០២១-២០២៣) ថ្ងៃទី១២ ខែមករា ឆ្នាំ២០២១។

៩.លិខិតបញ្ជាក់លេខ ២៤៣ ល.ប ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការចុះស្រាវជ្រាវឯកសារនៅក្នុងសង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្តាល។

១០.ផែនទីសង្កាត់ កោះអន្លង់ចិន។

**១.ព្រះរាជក្រមលេខ នស/រកម/0៣0១/0៥ ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ២00១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។**

# ច្បាប់

## ស្តីពី

## ការគ្រប់គ្រងរដ្ឋបាល
## ឃុំ សង្កាត់

នស / រកម / ០៣០១ / ០៥

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ
## រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
## និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤នៃរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្ដីក្រាបបង្គំទូលស្នើសុំ ពីសម្ដេចនាយករដ្ឋមន្ត្រី និង ពីសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

## ប្រកាសអោយប្រើ

ច្បាប់ស្ដីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០១ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្ដីសម្រេចលេខ ០៤១/ ០០៣ / ២០០១ កបធ.ច ចុះថ្ងៃទី ២៨ ខែ កុម្ភះ ឆ្នាំ ២០០១ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅ ៖ ។ល។

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាតាមនយោបាយវិមជ្ឈការ ។

**មាត្រា ២.-**

ឃុំ សង្កាត់ជានីតិបុគ្គល ។

**មាត្រា ៣.-**

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ។

**មាត្រា ៤.-**

អំណាចដឹកនាំនិងគ្រប់គ្រងឃុំ សង្កាត់បានមកដោយការបោះឆ្នោតជាទូទៅជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ក្នុងក្របខ័ណ្ឌនៃឃុំ សង្កាត់នីមួយៗ ។

**មាត្រា ៥.-**

ឃុំ សង្កាត់គ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួនដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

អំណាចបញ្ញត្តិ អំណាចប្រតិបត្តិក្នុងការគ្រប់គ្រងមូលដ្ឋានត្រូវផ្តល់ឱ្យឃុំ សង្កាត់ ហើយអំណាចនេះត្រូវអនុវត្តស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ត្រូវសំរេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលមានការប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ត្រូវ៖ល៖

សំរេចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ផ្អែកលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

កាលបើមានផលវិបាកណាមួយកើតឡើង ក្រោយពេលដែលឃុំ សង្កាត់ ត្រូវបានបង្កើត លុបចោលឬកែសម្រួល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសដើម្បីដោះស្រាយផលវិបាកនោះស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៨.-**

ឃុំ សង្កាត់ណាដែលមិនអាចដំណើរការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានដោយករណីប្រធានសក្តិ រាជរដ្ឋាភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា។

បន្ទាប់ពីបានរាយការណ៍ជូនរដ្ឋសភារួចហើយ រាជរដ្ឋាភិបាលត្រូវចាត់ឱ្យក្រសួងមហាផ្ទៃរៀបចំគ្រប់គ្រងឃុំ សង្កាត់ទាំងនោះជាបណ្តោះអាសន្ន ហើយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះនឹងត្រូវដំណើរការ នៅពេលស្ថានការណ៍ឃុំ សង្កាត់ទាំងនេះមានប្រក្រតីភាពឡើងវិញ ។

## ជំពូកទី ២
## ក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៩.-**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបំរើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

មាត្រា ១១.-

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង ។

ក្នុងតំណាក់កាលអន្តរកាលនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលផុតអាណត្តិមានភារកិច្ចសំរួលកិច្ចការប្រចាំថ្ងៃតែប៉ុណ្ណោះ ។

មាត្រា ១២.-

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកចំនួនពី ៥ ទៅ ១១រូប ផ្អែកតាមប្រជា-សាស្ត្រនិងភូមិសាស្ត្ររបស់ខ្លួន ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាតាមឃុំ សង្កាត់នីមួយៗត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានកំណត់រួចហើយ អាចធ្វើការផ្លាស់ប្តូរបានដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាស្រ័យដោយការផ្លាស់ប្តូរនៃប្រជាសាស្ត្រនិងភូមិសាស្ត្រ ។

សមាជិកបន្ថែមនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសតាមនីតិវិធីដូចសមា-ជិកដទៃទៀតដែរ ។

មាត្រា ១៣.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានម្នាក់ហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ច :

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាននិងបទបញ្ជាដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់និងបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់នេះ
- រក្សារបៀបរៀបរយនិងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ ។ល។

**មាត្រា ១៤.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិនិងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញល័ក្ខខ័ណ្ឌសំខាន់ៗដូចខាងក្រោម:

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាននិងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ១៥.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ។

**មាត្រា ១៦.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម :

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៨៤នៃច្បាប់នេះ ៕

- ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ
- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាព ត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

**មាត្រា ១៧.-**

ត្រូវរៀបចំធ្វើការបោះឆ្នោតឡើងវិញក្នុងរយៈពេល ១២០ថ្ងៃយ៉ាងយូរ ដើម្បីធ្វើការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីណាមួយដូចខាងក្រោម :

- ឃុំ សង្កាត់ដែលបង្កើតថ្មីតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយចោលតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៥៧ និងមាត្រា ៥៨ នៃច្បាប់នេះ ។

ការបោះឆ្នោតឡើងវិញដូចមានចែងខាងលើនេះត្រូវចាត់ចែងធ្វើឡើង អនុលោមទៅតាមបែបបទនិងនីតិវិធីដែលបានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះមានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេលមិនលើសពី ១៨០ថ្ងៃ ។

ក្នុងរយៈពេលនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវតែងតាំងសមាសភាពនិងកំណត់អំពីសមត្ថកិច្ច របៀបរបបដឹកនាំគ្រប់គ្រងឃុំ សង្កាត់នោះ រហូតដល់មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

**មាត្រា ១៨.-**

ការកែប្រែព្រំប្រទល់របស់ឃុំ សង្កាត់ណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការកែប្រែនោះ ពុំបណ្តាលឱ្យផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ។/.

ការបង្កើតឃុំ សង្កាត់ថ្មីណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការបង្កើតនោះពុំបណ្ដាលឱ្យមានផ្លាស់ប្ដូរដល់ចំនួនសមាជិកក្រុមប្រឹក្សានៃឃុំ សង្កាត់ដែលពាក់ព័ន្ធ ។

ក្នុងករណីឃុំ សង្កាត់ដែលត្រូវបង្កើតថ្មី ដែលត្រូវលុបចោល ដែលត្រូវកែប្រែព្រំប្រទល់ ហើយបណ្ដាលឱ្យមានការផ្លាស់ប្ដូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ត្រូវចូលជាធរមានសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាអាណត្តិបន្ទាប់ ។

**មាត្រា ១៩.-**

ក្នុងអំឡុងពេល ១៤ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ត្រូវចាត់ឱ្យមានការប្រជុំជាលើកដំបូងនៃក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់និងប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់និងចៅសង្កាត់រង ។

**មាត្រា ២០.-**

មុនចាប់ផ្ដើមការងារ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំនិងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសំរាប់អង្គប្រជុំនិងរបៀបរបបធ្វើការងាររបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្ដីណែនាំអំពីគោលការណ៍នានាសំរាប់ជាមូលដ្ឋានដល់ការរៀបចំបទបញ្ជាផ្ទៃក្នុងខាងលើនេះ ។

**មាត្រា ២១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំក្នុងសាលាឃុំ ឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសយកទីកន្លែងណាមួយក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីប្រជុំ ។ល។

## មាត្រា ២២.-

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ នឹងយកជាការបាន លុះត្រាតែមានចំនួនលើសពីពាក់កណ្ដាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួម ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការបោះឆ្នោតអនុម័តដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ដើម្បីសំរេចបញ្ហាណាមួយដូចខាងក្រោម :

- អនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- អនុម័តលើគំរោងថវិកាឃុំ សង្កាត់
- កំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាននិងកំរៃសេវាផ្សេងៗ
- អនុម័តបទបញ្ញាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងពេលអនុម័ត ប្រសិនបើមានសំឡេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព ។

## មាត្រា ២៣.-

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើជាសាធារណៈនិងមានលក្ខណៈប្រជាធិបតេយ្យ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្ដីណែនាំអំពីរបៀបរបបប្រជុំខាងលើនេះ ។

## មាត្រា ២៤.-

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បានឡើយ ។ល។

## ជំពូកទី ៣
## រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

**មាត្រា ២៥.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ ។

**មាត្រា ២៦.-**

មេឃុំ ចៅសង្កាត់មានអ្នកជំនួយការដូចខាងក្រោម :

ចំពោះមេឃុំ អ្នកជំនួយការមានពីររូប :

-ជំទប់ទី ១ មួយរូប

-ជំទប់ទី ២ មួយរូប ។

ចំពោះចៅសង្កាត់ អ្នកជំនួយការមានពីររូប :

-ចៅសង្កាត់រងទី ១ មួយរូប

-ចៅសង្កាត់រងទី ២ មួយរូប ។

**មាត្រា ២៧.-**

មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន ។

**មាត្រា ២៨.-**

ឃុំ សង្កាត់ត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបធ្វើជាស្មៀនឃុំ សង្កាត់ ។

ស្មៀនឃុំ សង្កាត់តែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយកិច្ចការឃុំ សង្កាត់ និងធានានិរន្តភាពកិច្ចការរដ្ឋបាលក្នុងឃុំ សង្កាត់ ។ល។

ស្មៀនឃុំ សង្កាត់ត្រូវផ្លាស់ប្តូរក្នុងករណីមានសំណើរបស់មេឃុំ ចៅសង្កាត់ អនុលោមតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២៩.-**

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួន តាមសេចក្តីត្រូវការនិងការចាំបាច់នៃការងារនិងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់ ។

**មាត្រា ៣០.-**

ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សំរាប់ភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន ។

មេភូមិត្រូវរៀបចំចាត់តាំងឱ្យមានអនុប្រធានមួយរូបនិងសមាជិកមួយរូបជាជំនួយការ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិនិងការតែងតាំងជំនួយការមេភូមិ ។

**មាត្រា ៣១.-**

មេភូមិមានភារកិច្ច :

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ប្រគល់ឱ្យដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែងនិងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំបន្ថែមអំពីរបៀបរបបធ្វើការងារនិងភារកិច្ចរបស់ភូមិ ឱ្យបានសមស្រប ។៚

## មាត្រា ៣២.-

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសចេញពីបេក្ខ-ជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់មានអាណត្តិស្មើនឹងអាណត្តិរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

## មាត្រា ៣៣.-

ជំទប់ទី ១ ចៅសង្កាត់រងទី ១ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ២ ។

ជំទប់ទី ២ ចៅសង្កាត់រងទី ២ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ៣ ។

## មាត្រា ៣៤.-

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែមួយដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈទាំងអស់ក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាពីក្នុងបញ្ជីតែមួយនោះឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។

## មាត្រា ៣៥.-

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែពីរដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាជាបេក្ខជន ដែលមានឈ្មោះលេខរៀងបន្ទាប់ពីបេក្ខជនដែលមានឈ្មោះលេខរៀងលំដាប់លើគេបង្អស់នៃបញ្ជីដែលបានទទួលសម្លេងឆ្នោតគាំទ្រលំដាប់ទីមួយ ឱ្យទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ និងជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះលេខរៀងលើគេបង្អស់ នៃបញ្ជីដែលបានទទួលសម្លេងគាំទ្រលំដាប់ទី ២ ឱ្យទទួលតំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។ល។

មាត្រា ៣៦.-

តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវបាត់បង់ក្នុងករណីសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។

មាត្រា ៣៧.-

មុខតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មុខតំណែងមេឃុំ ចៅសង្កាត់និងមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ កាលបើមុខតំណែងណាមួយត្រូវបាត់បង់ មុខតំណែងទាំងអស់ខាងលើរបស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៅក្នុងបញ្ជីរួមជាមួយអតីតប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ ដែលបានបាត់បង់ពីមុខតំណែងនោះ ឱ្យទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់និងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មី ជំនួសកន្លែងដែលទំនេរតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីដែលបញ្ជីបេក្ខជនត្រូវកាន់កាប់តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់អស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចេញពីក្នុងបញ្ជីបេក្ខជនជាមួយ ផ្សេងៗតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦ នៃច្បាប់នេះនិងចាត់ឱ្យសមាជិកក្រុមប្រឹក្សារូបនេះទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ជំនួសប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ ការបាត់បង់ពីមុខតំណែងនិងការទទួលតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

មាត្រា ៣៨.-

តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបាត់បង់ពីមុខតំណែង ក្នុងករណីដែលសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សា ឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។/.

ក្នុងករណីតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបានបាត់បង់ មុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៃបញ្ជីបេក្ខជនរួមជាមួយជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ឱ្យទទួលតំណែងជំនួសជំទប់ ឬចៅសង្កាត់រងដែលបានបាត់បង់ពីមុខតំណែងនិងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មីជំនួសកន្លែងដែលទំនេរ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីបញ្ជីបេក្ខជនដែលត្រូវកាន់កាប់តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ អស់សមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសបេក្ខជនពីក្នុងបញ្ជីនោះបញ្ចូលជាសមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ នឹងប្រគល់ឱ្យសមាជិកក្រុមប្រឹក្សារូបនោះទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ជំនួសតំណែងជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះនិងល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ការបាត់បង់មុខតំណែងនិងការទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៩.-**

មេឃុំ ចៅសង្កាត់បំពេញតួនាទីភារកិច្ចដូចខាងក្រោម :

- អនុវត្តសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តនូវបទប្បញ្ញត្តិនិងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនយ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ផ្តល់យោបល់ផ្សេងៗនិងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំផែនការហិរញ្ញវត្ថុនិងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុម ./.

ប្រឹក្សាឃុំ សង្កាត់ ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនប្រគល់ឱ្យ ។

**មាត្រា ៤០.-**

ជំទប់ ឬចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ចដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យនិងជំនួសមេឃុំ ចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ ចៅសង្កាត់រង នៅពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន ។

ជំទប់ ឬចៅសង្កាត់រង ត្រូវធ្វើការបែងចែកភារកិច្ចដូចខាងក្រោម :

ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈនិងសណ្តាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែកខាងលើនេះដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន ។

## ជំពូកទី ៤
## តួនាទី មុខងារនិងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

**មាត្រា ៤១.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញនិងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាព សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

**មាត្រា ៤២.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ :

- តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ សង្កាត់និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ។
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។ល។

មាត្រា ៤៣.-

ក្នុងតួនាទីបំរើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច :

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ

- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ

- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ

- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ

- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក

- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជា-ពលរដ្ឋ ។

**មាត្រា ៤៤.-**

ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាពនិងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សំរាប់អនុវត្ត ។

ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ ។

**មាត្រា ៤៥.-**

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសំរេចលើវិស័យទាំងឡាយដូចខាងក្រោម :

- ព្រៃឈើ

- ប្រៃសណីយ៍និងទូរគមនាគមន៍

- ការពារប្រទេស ល។

- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

**មាត្រា ៤៦.-**

តួនាទី មុខងារនិងអំណាចរបស់ឃុំ សង្កាត់ ដូចមានចែងក្នុងមាត្រា ៤២, ៤៣ និងមាត្រា ៤៤នៃច្បាប់នេះ អនុវត្តបានតែក្នុងរង្វង់ដែនដីឃុំ សង្កាត់របស់ខ្លួនតែប៉ុណ្ណោះ ។

ក្នុងករណីមានបញ្ហាកើតឡើងទាក់ទងសមត្ថកិច្ចរវាងឃុំ សង្កាត់ពីរឬច្រើន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់ការឱ្យមានការសំរុះសំរួលគ្នារវាងរដ្ឋបាលដែលពាក់ព័ន្ធទាំងនោះ ។

**មាត្រា ៤៧.-**

តួនាទី មុខងារនិងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ដូចមានចែងក្នុងមាត្រា ៤២, ៤៣, ៤៤ និងមាត្រា ៤៥នៃច្បាប់នេះ អាចកំណត់លំអិតជាក់ស្តែងបន្ថែមទៀតដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ឃុំ សង្កាត់មានអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ។

អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់សំរាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារនិងអំណាចរបស់ខ្លួន ។

ដីកាឃុំ សង្កាត់ត្រូវធ្វើឡើងតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ។

រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនិងជាបន្ទាន់ក្នុងឃុំ សង្កាត់របស់ខ្លួននូវដីកាដែលបានសំរេចរួចហើយ ។៚

មាត្រា ៤៩.-

ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ ។

ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធបានឡើយ ។

ដីកាដែលដាក់ចេញដោយរដ្ឋបាលឃុំ សង្កាត់ ហើយផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធត្រូវចាត់ទុកជាមោឃៈដាច់ខាត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងអំពីមោឃភាពនេះជាលាយលក្ខណ៍អក្សរដល់ឃុំ សង្កាត់សាមីនិងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

មាត្រា ៥០.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំអំពីទំរង់និងបែបបទ ដើម្បីឱ្យឃុំ សង្កាត់រៀបចំដីកាស្របទៅតាមសភាពការណ៍ក្នុងឃុំ សង្កាត់របស់ខ្លួន ។

មាត្រា ៥១.-

ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់តាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែបញ្ហាទាំងឡាយដូចខាងក្រោម :

- ការអនុម័តលើគំរោងថវិកាឃុំ សង្កាត់
- ការកំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកំរៃសេវាផ្សេងៗ
- ការបោះឆ្នោតអនុម័តបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- ការអនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- បញ្ហាដទៃទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មេឃុំ ចៅសង្កាត់ដែលត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើប្រតិភូកម្មអំណាចឱ្យពុំអាចផ្ទេរអំណាចនេះបន្តទៅឱ្យបុគ្គលដទៃទៀតបានឡើយ ។ ៚

មាត្រា ៥២.-

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់ នៅតែទទួលខុសត្រូវលើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ ។

ការដកហូតនូវអំណាចដែលបានធ្វើប្រតិភូកម្ម មិនធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចការដែលបានធ្វើរួចហើយនោះទេ ។

## ជំពូកទី ៥
## ការតាមដាន ការត្រួតពិនិត្យនិងការធ្វើអន្តរាគមន៍

មាត្រា ៥៣.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់ពីនីតិវិធីផ្សេងៗសំរាប់ធ្វើការតាមដាននិងត្រួតពិនិត្យអំពីសកម្មភាពទូទៅរបស់ឃុំ សង្កាត់ដើម្បី :

- ពិនិត្យមើលអំពីនីត្យានុកូលភាពនៃការគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទី ភារកិច្ច របស់ឃុំ សង្កាត់នីមួយៗ
- ពិនិត្យមើលការវិវត្តន៍អំពីសមត្ថភាពរបស់ឃុំ សង្កាត់នានា
- វាយតំលៃប្រមាណអំពីការធ្វើអន្តរាគមន៍និងការជួយឧបត្ថម្ភគាំទ្រចំពោះឃុំ សង្កាត់ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទីភារកិច្ច ។

ក្នុងការតាមដាន ការត្រួតពិនិត្យនិងការធ្វើការអន្តរាគមន៍ចំពោះឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចបំរែបំរួលអំណាចដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឱ្យជួយកិច្ចការនេះទៅតាមសំណូមពរការងារ ។

មាត្រា ៥៤.-

ឃុំ សង្កាត់ណាដែលមិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ដើម្បីឱ្យមានការបំពេញភារកិច្ចដែលច្បាប់បានតម្រូវនោះជាបន្ទាន់ ។ល។

ភារកិច្ចដែលច្បាប់បានតម្រូវ គឺជាភារកិច្ចមួយដែលក្រុមប្រឹក្សាឃុំ សង្កាត់ មានកាតព្វកិច្ចបំពេញតាមល័ក្ខខ័ណ្ឌទាំងឡាយនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានពាក់ព័ន្ធ ឬបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់ ។

**មាត្រា ៥៥.-**

ការតាមដាន ត្រួតពិនិត្យនិងធ្វើអន្តរាគមន៍រួមមានការងារ :

- ស៊ើបអង្កេតនិងវាយតំលៃ
- ធ្វើសេចក្តីណែនាំជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញភារកិច្ចដែលច្បាប់បានតម្រូវ
- ធ្វើជំនួសក្នុងការបន្តបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ។

**មាត្រា ៥៦.-**

ការធ្វើអន្តរាគមន៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥៤ នៃច្បាប់នេះត្រូវមានលក្ខណៈសមហេតុផលនិងស្របទៅតាមទំហំនៃកិច្ចការដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ដោយភ្ជាប់ជាមួយនូវការណែនាំនិងការគាំទ្រសំខាន់ចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចបំពេញភារកិច្ចដែលច្បាប់បានតម្រូវជាធម្មតា ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសិទ្ធិចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គល ឬអង្គការណាមួយ ឬធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌឱ្យបំពេញការងារចាំបាច់ដើម្បីធ្វើអន្តរាគមន៍ក្នុងនាមខ្លួនចំពោះកិច្ចការណាមួយ ។

**មាត្រា ៥៧.-**

កាលបើការធ្វើអន្តរាគមន៍មិនទទួលបានលទ្ធផលចំពោះភារកិច្ចដែលច្បាប់បានតម្រូវណាមួយ ឬមួយចំនួនក្នុងអំឡុងពេល ៦ខែ ហើយភារកិច្ចដែលច្បាប់បានតម្រូវជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់ក៏មិនអាចបំពេញបាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំលាយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយធ្វើការបោះឆ្នោតឡើងវិញទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល.ស.

មាត្រា ៥៨.-

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ណាធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ផ្ទុយនឹងនយោបាយរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ នោះជាបន្ទាន់ ហើយត្រូវធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះឡើងវិញ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

មាត្រា ៥៩.-

ត្រូវបង្កើតឱ្យមានអង្គភាពមួយចំណុះក្រសួងមហាផ្ទៃដើម្បីធ្វើជាសេនាធិការអំពីការងាររដ្ឋបាលមូលដ្ឋាន ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៦
## ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

មាត្រា ៦០.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័តនិងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំសង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធីនិងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

មាត្រា ៦១.-

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់ជាតិ ។

មាត្រា ៦២.-

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំទី ១ នៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវពិនិត្យឡើងវិញដើម្បីផ្តល់ទិន្នន័យថ្មីៗជារៀងរាល់ឆ្នាំ ដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។ ...

## មាត្រា ៦៣.-

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធានការដូចតទៅ :

- វាយតំលៃអំពីកំរិតអត្ថិភាពនៃការអភិវឌ្ឍន៍និងសកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន
- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះ ដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់មាននិងធនធានដែលបានទទួល
- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានា តាមរយៈការផ្តល់សេវានិងការអភិវឌ្ឍន៍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់
- ផ្តល់សេវានិងការអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន
- ពិនិត្យ តាមដាននិងវាយតំលៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍
- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតំលៃអំពីកំរិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងឃុំ សង្កាត់របស់ខ្លួន
- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ជូនប្រជាពលរដ្ឋរបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

## មាត្រា ៦៤.-

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិនិងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង ។

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រនិងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល ។ ៕

**មាត្រា ៦៤.-**

ក្នុងករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ណាមួយធ្វើឡើងមិនស្របតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់នេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់កែតំរូវផែនការរបស់ខ្លួនឱ្យបានសមស្របក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលច្បាប់ចម្លងនៃផែនការនោះ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសំរួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនឱ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦៦.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដាន ត្រួតពិនិត្យនិងវាយតំលៃរាល់ការអនុវត្តផែនការ កម្មវិធី គំរោងនិងការផ្តល់សេវានានាប្រកបដោយតម្លាភាពនិងមានការទទួលខុសត្រូវខ្ពស់ ។

**មាត្រា ៦៧.-**

ក្រុមប្រឹក្សាឃុំ សង្កាត់នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យនិងការវាយតំលៃចំពោះផែនការ កម្មវិធីនិងគំរោងនានា ទោះជាការងារនោះត្រូវបានអនុវត្តដោយសមាសភាពណាក៏ដោយដែលខ្លួនបានជ្រើសយក ។

**មាត្រា ៦៨.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំក្រុមប្រឹក្សាឃុំ សង្កាត់អំពីវិធីផ្សេងៗក្នុងការអនុវត្តផែនការនិងក្នុងការត្រួតពិនិត្យ វាយតំលៃចំពោះការប្រើប្រាស់មូលនិធិសំរាប់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៦៩.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំអំពី :

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់នាឆ្នាំសារពើពន្ធកន្លងមក
- លទ្ធផលនៃការអនុវត្តចំពោះកិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍ទាំងនោះរបស់ឃុំ សង្កាត់ ។ល។

- វិធានការធ្វើឱ្យបានល្អប្រសើរចំពោះវិស័យនានាដែលមានការខ្វះចន្លោះក្នុងការអនុវត្តកន្លងមក

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តសេចក្តីរាយការណ៍នេះក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីបំណាច់ឆ្នាំសារពើពន្ធនីមួយៗ ។

**មាត្រា ៧០.-**

សេចក្តីរាយការណ៍ប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា ៦៩នៃច្បាប់នេះ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

- ចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តម្កល់ទុកជាសាធារណៈ
- ចម្លងចែកជូនអង្គការ សមាគមនិងសាធារណជនសំខាន់ៗដោយគិតត្រឹមថ្ងៃដើម ។

**មាត្រា ៧១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យពិចារណាទៅលើមតិយោបល់ផ្សេងៗដែលបានផ្តល់ចំពោះសេចក្តីរាយការណ៍ដូចមានចែងក្នុងមាត្រា ៦៩ និងមាត្រា ៧០នៃច្បាប់នេះ ហើយត្រូវទទួលយកនូវមតិយោបល់ល្អៗ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៧២.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវពិគ្រោះពិភាក្សាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងនូវបទប្បញ្ញត្តិនានា ដែលបានចែងក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

## ជំពូកទី ៧
## ហិរញ្ញវត្ថុឃុំ សង្កាត់

**មាត្រា ៧៣.-**

ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកានិងទ្រព្យសម្បត្តិផ្ទាល់ ។

មាត្រា ៧៤.-

ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ។

ពន្ធខាងលើនេះរាប់បញ្ចូលនូវពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យនិងពន្ធនៃការជួល ។

ក្នុងករណីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់របស់ឃុំ សង្កាត់ ការប្រមូលចំណូលនេះត្រូវធ្វើក្នុងនាមឃុំ សង្កាត់ ។

ប្រភេទ កំរិតនិងរបៀបរបបនៃការប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ខាងលើនេះត្រូវកំណត់ដោយច្បាប់ ។

មាត្រា ៧៥.-

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវធនធានវិភាជន៍ពីចំណូលរដ្ឋ សំរាប់ថវិការបស់ខ្លួន ។

ធនធានវិភាជន៍នេះរួមមានៈ

- ការផ្ទេរទាំងមូលឬមួយផ្នែកនូវប្រាក់ចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធដ៏ជាក់លាក់របស់រដ្ឋ
- ទាយជ្ជទាននិងធនធានវិភាជន៍ ឧបត្ថម្ភធន ឬអនុប្បទានដែលបានមកពីប្រាក់ចំណូលរដ្ឋ ។

ធនធានវិភាជន៍ខាងលើនេះត្រូវផ្តល់ទៅឱ្យឃុំ សង្កាត់តាមរតនាគារខេត្ត ក្រុង ។

ការរៀបចំនិងនីតិវិធីនៃការផ្ទេរប្រាក់វិភាជន៍ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៧៦.-

ឃុំ សង្កាត់នីមួយៗ មានសិទ្ធិទទួលបាននូវប្រាក់កំរៃ ចំពោះការអនុវត្តនូវតួនាទីជាភ្នាក់ងារតំណាងរដ្ឋដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលបានប្រគល់ឱ្យអនុវត្ត ។

ប្រាក់កំរៃខាងលើនេះគឺជាប្រាក់បន្ថែមពីលើប្រាក់ចំណូលរបស់ឃុំ សង្កាត់ ឬប្រាក់វិភាជន៍ផ្សេងៗដែលឃុំ សង្កាត់ទទួលបានពីប្រាក់ចំណូលរដ្ឋ ។ល។

រាជរដ្ឋាភិបាលឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលត្រូវផ្តល់កំរៃសមស្របដល់ឃុំ សង្កាត់ ដែលបានអនុវត្តតួនាទីជាភ្នាក់ងារតំណាងរដ្ឋដូចបានចែងខាងលើ ។

ក្នុងករណីដែលការប្រគល់អំណាច មុខងាររបស់រដ្ឋមានលក្ខណៈជាអចិន្ត្រៃយ៍ទៅឱ្យឃុំ សង្កាត់រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមានធនធានហិរញ្ញវត្ថុរយៈពេលយូរអង្វែងសំរាប់ផ្តល់ឱ្យឃុំ សង្កាត់ ។

ការរៀបចំប្រាក់កំរៃខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៧.-**

រដ្ឋបង្កើតឱ្យមានមូលនិធិឃុំ សង្កាត់ ។

មូលនិធិឃុំ សង្កាត់បង្កើតឡើងក្នុងគោលដៅដើម្បីធ្វើការផ្ទេរនូវប្រាក់ចំណូលពីជាតិនិងប្រាក់ចំណូលផ្សេងៗទៀតទៅឱ្យថវិកាឃុំ សង្កាត់ ។

ការផ្ទេរប្រាក់ចំណូលពីជាតិទៅមូលនិធិខាងលើនេះត្រូវធ្វើឡើងទៅតាមរូបមន្តឬតាមអត្រាជាក់លាក់មួយសំរាប់ថេរៈវេលាយ៉ាងតិច ៣ឆ្នាំ និងមិនលើសពី ៥ឆ្នាំដែលកំណត់ដោយអនុក្រឹត្យ ។

នីតិវិធីអនុវត្តជាក់ស្តែងនៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៨.-**

មូលនិធិឃុំ សង្កាត់បានមកពី :

- ការធ្វើវិភាជន៍នូវចំណែកដ៏ជាក់លាក់នៃប្រាក់ចំណូលរដ្ឋ ពីថវិការដ្ឋប្រចាំឆ្នាំដែលកំណត់ដោយអនុក្រឹត្យ
- អនុប្បទាននិងការឧបត្ថម្ភពីប្រភពក្នុងប្រទេសនិងក្រៅប្រទេស ។

ការធ្វើវិភាជន៍នូវធនធានប្រចាំឆ្នាំទៅឱ្យឃុំ សង្កាត់តាមមូលនិធិឃុំ សង្កាត់ត្រូវធ្វើឡើងទៅតាមរូបមន្តដែលកំណត់ដោយអនុក្រឹត្យ ។

របៀបរបបចាត់ចែង វិធាននៃការប្រើប្រាស់និងនីតិវិធីនៃការបើកប្រាក់ចំណាយពីមូលនិធិឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៩.-**

ឃុំ សង្កាត់ត្រូវរៀបចំនិងអនុម័តថវិការបស់ខ្លួនជារៀងរាល់ឆ្នាំ ។ ៸.

ថវិកាឃុំ សង្កាត់ត្រូវរៀបចំទៅតាមទំរង់មួយនិងអនុម័តនៅក្នុងកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទមួយអនុលោមទៅតាមប្រពន្ធ័ថវិកាជាតិ ។

ថវិកាឃុំ សង្កាត់ត្រូវមានតុល្យភាពរវាងចំណូលសរុបនិងចំណាយសរុប ។

ឃុំ សង្កាត់អាចបង្កើនចំណាយបាន តែត្រូវឱ្យស្របទៅតាមចំណូលរបស់ខ្លួន ។

ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងអំពីអាទិភាពនិងសេចក្តីត្រូវការនៃផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ ។

នីតិវិធីនៃការរៀបចំនិងការអនុម័តថវិកាខាងលើត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨០.-**

ឃុំ សង្កាត់គ្មានសិទ្ធិខ្ចីប្រាក់បានឡើយ ។

ឃុំ សង្កាត់មិនអាចធានារ៉ាប់រងចំពោះការខ្ចី ឬកាតព្វកិច្ចហិរញ្ញវត្ថុណាមួយបានឡើយ ។

**មាត្រា ៨១.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវការផ្ទេរទ្រព្យសម្បត្តិមួយផ្នែករបស់រដ្ឋមកជាទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ ។

ឃុំ សង្កាត់ត្រូវគ្រប់គ្រងឱ្យបានល្អនូវទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង និងទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យ ។

ឃុំ សង្កាត់អាចប្រើប្រាស់និងទាញយកផលចំណូលពីទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យខ្លួនគ្រប់គ្រង ។

ឃុំ សង្កាត់ត្រូវថែរក្សាការពារទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យ។បានគង់វង្ស ហើយទ្រព្យសម្បត្តិទាំងនោះ ឃុំ សង្កាត់គ្មានសិទ្ធិលក់ដូរឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

នីតិវិធីចាត់ចែងនិងប្រើប្រាស់ទ្រព្យសម្បត្តិខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨២.-**

ឃុំ សង្កាត់ត្រូវបង្កើតឱ្យមាននូវប្រព័ន្ធគ្រប់គ្រង តាមដាននិងត្រួតពិនិត្យហិរញ្ញ-វត្ថុរបស់ខ្លួនដែលរួមមាន : ៧.T.

- បទដ្ឋានហិរញ្ញវត្ថុនិងការអនុវត្តជាក់ស្តែងផ្នែកគណនេយ្យ
- ការចាត់ចែង គ្រប់គ្រងទ្រព្យសម្បត្តិ
- តំរូវការផ្សេងៗ ក្នុងការធ្វើសវនកម្ម
- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព ប្រសិទ្ធិភាពនិងការទទួលខុសត្រូវ ។

ប្រព័ន្ធនៃការគ្រប់គ្រង ការតាមដាននិងការត្រួតពិនិត្យហិរញ្ញវត្ថុឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨៣.-**

របបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានពិភាក្សាឯកភាពលើគោលការណ៍ជាមួយក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៨៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលវិន័យដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

វិន័យរួមមាន :

- ស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានកំណត់ហេតុច្បាស់លាស់
- ករណីនៅតែបន្តប្រព្រឹត្តកំហុស ត្រូវកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភ ។

វិន័យដែលតម្រូវឱ្យកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភដូចចែងខាងលើអាចអនុវត្តបាន លុះត្រាតែមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសេចក្តីស្នើសុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រាក់ឧបត្ថម្ភដែលកាត់នេះត្រូវបានមកជាប្រយោជន៍នៃថវិកាឃុំ សង្កាត់ ។៸.

ក្នុងករណីបានអនុវត្តបភាពវិន័យទាំងពីរខាងលើរួចហើយ តែសាមីខ្លួននៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំ សង្កាត់អាចបញ្ឈប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដោយការបោះឆ្នោតអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ហើយត្រូវធ្វើការជ្រើសរើសសមាជិកថ្មីមកជំនួសតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ទទួលវិន័យ ត្រូវជ្រើសយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឬមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុវត្តបភាពវិន័យខាងលើនេះ ។

មន្ត្រីដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំខាងលើនេះពុំមានសិទ្ធិអនុម័តឡើយ ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា ៨៥.-**

ដើម្បីមានមូលដ្ឋានសំរាប់រៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់និងគ្រប់គ្រងឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសអំពីចំនួន ឈ្មោះនិងព្រំប្រទល់របស់ឃុំ សង្កាត់ ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ ។

**មាត្រា ៨៦.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ១ នេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំឡើងវិញនូវមេភូមិនានាចំណុះឃុំ សង្កាត់របស់ខ្លួនទៅតាមបែបបទនីតិវិធីដូចមានចែងក្នុងមាត្រា ៣០នៃច្បាប់នេះ ។

**មាត្រា ៨៧.-**

ដើម្បីបង្កលក្ខណៈសម្បត្តិដល់ការគ្រប់គ្រងឃុំ សង្កាត់តាមប្រព័ន្ធវិមជ្ឈការត្រូវបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយឈ្មោះថា "គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់" ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន ។ល។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតបន្ទាប់ពីច្បាប់នេះបានចូលជាធរមាន ហើយត្រូវបញ្ចប់អាណត្តិរបស់ខ្លួនឱ្យបាន ៦ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចចែកចេញជាអនុគណៈកម្មការតាមការចាំបាច់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវយកអង្គភាពដែលបានបង្កើតឡើងស្របតាមមាត្រា ៥៩នៃច្បាប់នេះធ្វើជាលេខាធិការដ្ឋាន ។

**មាត្រា ៨៨.-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសមត្ថកិច្ចធ្វើសេចក្ដីស្នើយោបល់ទៅក្រសួងមហាផ្ទៃនិងរាជរដ្ឋាភិបាលអំពីបញ្ហានានាដូចខាងក្រោម :

- សិក្សាស្រាវជ្រាវកំណត់ឡើងវិញនូវព្រំប្រទល់ឃុំ សង្កាត់ទាំងអស់ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- បែងចែកមុខងារ សិទ្ធិអំណាចនិងភារកិច្ចផ្សេងៗ រវាងរាជរដ្ឋាភិបាលនិងឃុំ សង្កាត់ព្រមទាំងរៀបចំឱ្យមានកិច្ចសហការសំរបសំរួលរវាងឃុំ សង្កាត់ ពីរឬច្រើន ។
- បណ្ដុះបណ្ដាល បង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់
- រៀបចំប្រាក់ចំណូលនិងសារពើពន្ធសំរាប់ឃុំ សង្កាត់
- គាំទ្រផ្នែកបច្ចេកទេសដល់ឃុំ សង្កាត់
- វិះរកមធ្យោបាយសំរាប់ផ្ដល់ព័ត៌មាននិងគំរង់ទិសរដ្ឋបាលសាធារណៈអំពីកិច្ចដំណើរការនៃប្រព័ន្ធគ្រប់គ្រងឃុំ សង្កាត់តាមបែបប្រជាធិបតេយ្យនិងវិមជ្ឈការ
- ផ្ដល់យោបល់ដល់រាជរដ្ឋាភិបាលអំពីការអនុវត្តនយោបាយវិមជ្ឈការក្រោមអំណាចនៃច្បាប់នេះនិងផ្ដល់យោបល់លើការកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំព្រាងលិខិតបទដ្ឋានសំរាប់អនុវត្តច្បាប់នេះ
- រួមយោបល់ទៅលើអនុក្រឹត្យដែលមានការពាក់ព័ន្ធដល់ការងារនៅថ្នាក់ឃុំ សង្កាត់ ។ល។

- កំណត់របបគ្រប់គ្រងរដ្ឋបាលអន្តរកាលចំពោះឃុំ សង្កាត់ដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តនយោបាយវិមជ្ឈការ ។

**មាត្រា ៨៩.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយផ្អែកតាមសេចក្ដីស្នើយោបល់របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចស្នើបង្កើតឃុំ សង្កាត់ លុបចោលឃុំ សង្កាត់ កែប្រែព្រំប្រទល់ឃុំ សង្កាត់ ផ្លាស់ប្ដូរឈ្មោះឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦ និងមាត្រា ១៨នៃច្បាប់នេះ សំរាប់ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ២ ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៩០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។/.

រាជធានីភ្នំពេញថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១

ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាប់

ប្រមុខរដ្ឋស្ដីទី

**ហត្ថលេខា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ហត្ថលេខា**

ស ខេង យូ ហុកគ្រី

លេខ : ៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ ០៣ ឆ្នាំ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាន់ តាន់

# ២.អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០២០ ស្ដីពីការកែប្រែ និងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែ ចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែប្រែនិងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិក ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងការិយាល័យ ប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០
- បានឃើញអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងប្រធានការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា១ ..**

ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីភូមិ ត្រូវបានដំឡើងនិងកំណត់ដូចខាងក្រោម៖

| ល.រ | បរិយាយ | ប្រាក់ឧបត្ថម្ភ(រៀល) |
|---|---|---|
| ១ | ប្រធានក្រុមប្រឹក្សារាជធានី<br>ប្រធានក្រុមប្រឹក្សាខេត្ត | ១ ៤៤០ ០០០ |
| ២ | សមាជិកក្រុមប្រឹក្សារាជធានី<br>សមាជិកក្រុមប្រឹក្សាខេត្ត | ១ ១៣៥ ០០០ |
| ៣ | ប្រធានក្រុមប្រឹក្សាក្រុង<br>ប្រធានក្រុមប្រឹក្សាស្រុក<br>ប្រធានក្រុមប្រឹក្សាខណ្ឌ | ១ ១៥៥ ០០០ |
| ៤ | សមាជិកក្រុមប្រឹក្សាក្រុង<br>សមាជិកក្រុមប្រឹក្សាស្រុក<br>សមាជិកក្រុមប្រឹក្សាខណ្ឌ | ៩១០ ០០០ |
| ៥ | មេឃុំ ចៅសង្កាត់ | ១ ១១០ ០០០ |
| ៦ | ជំទប់ទី១<br>ចៅសង្កាត់រងទី១<br>ជំទប់ទី២<br>ចៅសង្កាត់រងទី២ | ៨៧០ ០០០ |
| ៧ | សមាជិកក្រុមប្រឹក្សាឃុំ<br>សមាជិកក្រុមប្រឹក្សាសង្កាត់ | ៧៦០ ០០០ |
| ៨ | មេភូមិ | ៤៣០ ០០០ |
| ៩ | អនុប្រធានភូមិ | ៣១០ ០០០ |
| ១០ | សមាជិកភូមិ | ២៨០ ០០០ |

**មាត្រា២ ..**

ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត និងប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ត្រូវបានដំឡើងនិងកំណត់ដូចខាងក្រោម៖

| ល.រ | បរិយាយ | ប្រាក់ឧបត្ថម្ភ(រៀល) |
|---|---|---|
| ១ | ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី<br>ប្រធានការិយាល័យប្រជាពលរដ្ឋខេត្ត | ១ ៤៤០ ០០០ |
| ២ | អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី<br>អនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្ត | ១ ១៣៥ ០០០ |
| ៣ | ប្រធានការិយាល័យប្រជាពលរដ្ឋក្រុង<br>ប្រធានការិយាល័យប្រជាពលរដ្ឋស្រុក<br>ប្រធានការិយាល័យប្រជាពលរដ្ឋខណ្ឌ | ១ ១៥៥ ០០០ |

**មាត្រា៣ ..**

ប្រាក់ឧបត្ថម្ភដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ តទៅ។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងមេឃុំ ចៅសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៨ រោច ខែ មិគសិរ ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

| **ឧបនាយករដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **ឧបនាយករដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រី<br>ក្រសួងមុខងារសាធារណៈ** |
|---|---|---|
| **សម្តេចក្រឡាហោម ស ខេង** | **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** | **ពេជ្រ ប៊ុនធិន** |

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ៣.អនុស្សរណៈស្តីពីការរៀបចំគម្រោងថវិកា ឆ្នាំ២០២១ របស់សង្កាត់កោះអន្លង់ចិន។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកណ្ដាល**
**ក្រុងតាខ្មៅ**
**សង្កាត់ កោះអន្លង់ចិន**
លេខ: ០០១/២១

ថ្ងៃចន្ទ ៦រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
កោះអន្លង់ចិន,ថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១

# អនុស្សរណៈ
## ស្ដីពី
## ការរៀបចំគម្រោងថវិកាឆ្នាំ ២០២១

### I. អំពីចំណូលថវិកាចរន្ត

| | | | |
|---|---|---|---|
| **ក- សរុបចំណូលចរន្ត (ក+ខ)** | សរុបចំនួន | **524,294,200** | រៀលក្នុងនោះមាន៖ |
| **ក្រុមទី ១: ចំណូលពិត (ប្រ.១ + ប្រ.២)** | | 524,294,200 | រៀល |
| **ប្រភេទទី ១: ចំណូលសារពើពន្ធ** | | | រៀល |
| **ប្រភេទទី ២: ចំណូលមិនមែនសារពើពន្ធ** | | 524,294,200 | រៀល |
| **២: ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិ និងសេវា(73)** | សរុបចំនួន | **2,000,000** | រៀល |
| - ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ: (7301) | : | - | រៀល |
| + ការលក់សម្ភារៈបរិក្ខារ សម្ភារៈខូចខាត សម្ភារៈសិក្សា (73011) | : | | រៀល |
| + ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈផ្សេងៗទៀត (73018) | : | | រៀល |
| - ផលពីការគ្រប់គ្រងរដ្ឋបាល (7302) | : | 2,000,000 | រៀល |
| + ចំណូលពីការអនុញ្ញាតិរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ (73028) | : | 2,000,000 | រៀល |
| ចំណូលពីការអនុញ្ញាតិរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ ឆ្នាំ២០២០ (73028) | : | - | រៀល |
| ចំណូលពីការអនុញ្ញាតិរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ ឆ្នាំ២០២១ (73028) | : | 2,000,000 | រៀល |
| - ការជួលទ្រព្យសម្បត្តិអចលត៍ (7303) | : | - | រៀល |
| + ការជួលគ្រឹះស្ថានសាធារណៈនៅថ្នាក់ក្រោមជាតិ (73036) | : | | រៀល |
| - ការផ្ដល់សេវាកម្ម (7304) | : | - | រៀល |
| + សេវាសុរិយោដី (73043) | : | | រៀល |
| + សេវាសំណង់ (73044) | : | | រៀល |
| + ផលពីសេវាផ្សេងៗទៀត (73048) | : | | រៀល |
| - ការជួលទ្រព្យសម្បត្តិអចល័តផ្សេងៗទៀត (7502) | : | - | រៀល |
| + ការជួលទ្រព្យសម្បត្តិអចល័តផ្សេងៗ (73058) | : | | រៀល |
| **៣: ការឧបត្ថម្ភ អំណោយ (75)** | សរុបចំនួន | **522,294,200** | រៀល |

- ឧបត្ថម្ភធនពីថ្នាក់ជាតិ (75011)

យោងតាមលិខិតលេខ ៥៧៤៩ សហវ.អហក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ របស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការបែងចែកជធនជានមូលនិធិឃុំ សង្កាត់ទូទាំងប្រទេសសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ដែលក្នុងនោះសង្កាត់ កោះអន្លង់ចិន បានទទួលថវិកាសំរាប់ចំណាយរដ្ឋបាលចំនួន ៖ 155,000,000 រៀល

| | | | |
|---|---|---|---|
| - ឧបត្ថម្ភធន រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ (7502) | : | - | រៀល |
| + ឧបត្ថម្ភធនពីរាជធានី ខេត្ត (75021) | : | | រៀល |
| + ឧបត្ថម្ភធនពីក្រុង ស្រុក ខណ្ឌ (75022) | : | | រៀល |
| + ការជួលទ្រព្យសម្បត្តិអចល័តផ្សេងៗ (75023) | : | | រៀល |
| - ការចូលរួមធនធានពីសមាសភាគអភិវឌ្ឍមូលដ្ឋាន (75031) | : | 19,200,000 | រៀល |
| - ឧបត្ថម្ភធនចរន្តពីក្រៅប្រទេសទ្វេភាគី (7504) | : | | រៀល |
| - ឧបត្ថម្ភធនចរន្តពីក្រៅប្រទេសពហុភាគី (7505) | : | | រៀល |
| - ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារតិ (7506) | : | - | រៀល |
| + ពីក្រសួង ស្ថាប័ន (75061) | : | | រៀល |

+ ពីមន្ទីរជំនាញ (75062) : រៀល

+ ពីរាជធានី ខេត្ត (75063) : រៀល

+ ពីក្រុង ស្រុក ខណ្ឌ (75064) : រៀល

+ ផ្សេងៗ (75068) : រៀល

- ចំណូលបដិភាគពីប្រជាពលរដ្ឋ សប្បុរសជនក្នុងនិងក្រៅប្រទេស (7507) : រៀល

- ចំណូលចរន្តពីប្រភពផ្សេងៗ (7508) : រៀល

- មូលនិធិបម្រុង (75101) : 178,994,200 រៀល

- ឧបត្ថម្ភកធនពីថ្នាក់ជាតិសម្រាប់ចំណាយវិនិយោគ (75111) : 168,800,000 រៀល

យោងតាមលិខិតលេខ ៥៧៤៩ សហវ.អហក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការវិភាជមូនិធិឃុំ សង្កាត់ ទូទាំងប្រទេសសម្រាប់ឆ្នាំ ២០២១។ សង្កាត់៖ កោះអន្លង់ចិន បានទទួលថវិកាសម្រាប់ ចំណាយវិនិយោគអភិវឌ្ឍន៍ មូលដ្ឋានចំនួន 96,000,000 រៀល យោងតាមការចាំបាច់របស់រដ្ឋបាលសង្កាត់ និង គណៈកម្មាធិកាកសាងផែនការ និងថវិកាសង្កាត់ បានឯកភាពរំលែកថវិកា 20% នេះចំនួន 19,200,000 រៀលត្រូវជា ថវិកានេះនៅសល់ចំនួន 76,800,000 រៀលនឹងត្រូវប្រើប្រាស់សម្រាប់ចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន ។

-យោងតាមលិខិតលេខ ៦៣៩៦ សហវ.អហក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការវិភាជធនធានបន្ថែម សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋានជូនរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០២១ សង្កាត់កោះអន្លង់ចិន បានទទួលចំនួន : 92,000,000 រៀល

- ឧបត្ថម្ភកធនរវាងថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ចំណាយវិនិយោគ (7512) : - រៀល

+ ឧបត្ថម្ភកធនពីរាជធានី ខេត្តសម្រាប់ចំណាយវិនិយោគ (75121) : រៀល

+ ឧបត្ថម្ភកធនពីក្រុង ស្រុក ខណ្ឌសម្រាប់ចំណាយវិនិយោគ (75122) : រៀល

+ ឧបត្ថម្ភកធនពីឃុំ សង្កាត់សម្រាប់ចំណាយវិនិយោគ (75123) : រៀល

- ចំណូលពីការរួមចំណែករបស់ប្រជាជនមូលដ្ឋានក្នុងការអនុវត្តគម្រោង (75131) : 300,000 រៀល

- ឧបត្ថម្ភកធនពីក្រៅប្រទេសទ្វេភាគី សម្រាប់ចំណាយវិនិយោគ (7514) : រៀល

- ឧបត្ថម្ភកធនពីក្រៅប្រទេសពហុភាគីសម្រាប់ចំណាយវិនិយោគ (7515) : រៀល

- ចំណូលពីប្រជាពលរដ្ឋសប្បុរសជនក្នុងនិងក្រៅប្រទេសសម្រាប់ចំណាយវិនិយោគ (7517) : រៀល

- ចំណូលពីប្រភពផ្សេងៗសម្រាប់ចំណាយវិនិយោគ (7518) : រៀល

សរុបចំនួន - រៀល

**៤: ផលហិរញ្ញវត្ថុ(76)** : រៀល

- ផលហិរញ្ញវត្ថុផ្សេងទៀត (7698)

សរុបចំនួន - រៀល

**៥: ផលផ្សេងៗ និងផលពិសេស(77)** : រៀល

- ចំណូលពីការលក់អាគារ (7704) : រៀល

- ចំណូលពីការលក់បបនកម្ម បច្ចេកទេស សម្ភារ: និងហត្ថូបករណ៍ (7705) : រៀល

- ចំណូលពីការលក់រថយន្តដឹកជញ្ជូន (7706) : រៀល

- ចំណូលពីការលក់ឧបករណ៍ធុនធ្ងន់ (7707) : រៀល

- ចំណូលពីការលក់ឧបករណ៍ការិយាល័យនិងគ្រឿងសង្ហារឹម (7708) : រៀល

- ផលផ្សេងៗទៀត (7798) : រៀល

**ខ- ក្រុមទី២ ចំណូលតាមដីកា (ប្រ.៣)** : រៀល

**ប្រភេទទី ៣: ចំណូលតាមដីកា (មិនឆ្លងកាត់សាច់ប្រាក់)** : រៀល

**ខ - សរុបចំណូលជាមូលធន (ក + ខ)** : រៀល

**ក្រុមទី ១: ចំណូលពិត (ប្រ.១ + ប្រ.២)** : រៀល

**ប្រភេទទី ១: ចំណូលពីប្រភពផ្ទាល់** : រៀល

**ប្រភេទទី ២: ចំណូលពីប្រភពខាងក្រៅ** : រៀល

**ប្រភេទទី ៣: ចំណូលតាមដីកា (មិនឆ្លងកាត់សាច់ប្រាក់)**

## II. អំពីចំណាយថវិកាចរន្ត

សរុបចំនួន 524,294,200 រៀលក្នុងនោះមាន៖

**គ- សរុបចំណាយចរន្ត (ក្រុមទី១ +ក្រុមទី២)** សរុបចំនួន 522,744,200 រៀល

**ក្រុមទី ១: ចំណូលពិត (ប្រ.១ + ប្រ.២+ ប្រ.៣ + ប្រ.៤)** សរុបចំនួន 518,674,820 រៀល

**ប្រភេទទី ១: មធ្យោបាយសេវា** សរុបចំនួន 11,020,620 រៀល

១: ការទិញ (60)

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| - សម្ភារៈផ្គត់ផ្គង់ថែទាំ (6001) | : | | | | | | 7,740,000 | រៀល |
| + សម្ភារៈផ្គត់ផ្គង់សំអាត និងអនាម័យ-(60011) | : | 45,000 | រៀល/ខែ x | 12 | ខែ | = | 540,000 | រៀល |
| + សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេង-(60012) | : | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| + សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំ ផ្លូវថ្នល់ ស្ពាន និងលូ-(60013) | : | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| + សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍-(60014) | : | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| + ប្រេងឥន្ធនៈ និងប្រេងរំអិល-(60015) | : | 600,000 | រៀល/ខែ x | 12 | ខែ | = | 7,200,000 | រៀល |
| មធ្យោបាយធ្វើដំណើររបស់ អ.ក.ន.ក និងក្រុមប្រឹក្សាឃុំប្រជុំ | | 40,000 | រៀល/ខែ x | 12 | ខែ | = | 480,000 | រៀល |
| + សម្ភារៈផ្គត់ផ្គង់ថែទាំផ្សេងៗ-(60018) | : | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| - សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល (6002) | : | | | | | | 1,720,620 | រៀល |
| + សម្ភារៈការិយាល័យ និងការបោះពុម្ព-(60021) | : | 95,000 | រៀល/ខែ x | 12 | ខែ | = | 1,140,000 | រៀល |
| *ថវិកាពីអភិវឌ្ឍន៍(7503)សម្ភារៈការិយាល័យបម្រើឲ្យគម្រោង* | | 50,000 | រៀល/ខែ x | 12 | ខែ | = | 600,000 | រៀល |
| + សៀវភៅមើល និងឯកសារ-(60022) | : | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| + ការបោះពុម្ព (60023) | : | | រៀល/ខែ x | 12 | ខែ | = | 580,620 | រៀល |
| + សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ-(60028) | : | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| - ស្បៀងអាហារនិងផលិតផលកសិកម្ម (6003) | : | | | | | | - | រៀល |
| + ស្បៀង-(60031) | : | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| + ស្បៀងអាហារនិងផលិតផលកសិកម្មផ្សេងៗ-(60038) | : | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| - សំលៀកបំពាក់ និងការតុបតែង(6004) | : | | | | | | - | រៀល |
| + ឯកសណ្ឋាន-(60041) | : | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| - សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ (6005) | : | | | | | | - | រៀល |
| + សម្ភារៈ និងបរិក្ខារបច្ចេកទេស-(60051) | : | | | | | | - | រៀល |
| + សង្ហារិម-(60052) | : | | | | | | - | រៀល |
| + សម្ភារៈប្រើប្រាស់-(60053) | : | | | | | | - | រៀល |
| + សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារផ្សេងៗ-(60058) | : | | | | | | - | រៀល |
| *ថវិកាពីអភិវឌ្ឍន៍(7503)សម្រាប់បម្រើឱ្យសេវាសង្គម* | | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| - ថាមពល និងទឹក (6006) | : | | | | | | 1,560,000 | រៀល |
| + អគ្គិសនី-(60061) | | 50,000 | រៀល/ខែ x | 12 | ខែ | = | 600,000 | រៀល |
| + ទឹក-(60062) | | 80,000 | រៀល/ខែ x | 12 | ខែ | = | 960,000 | រៀល |
| + ផ្សេងៗ-(60068) | | - | រៀល/ខែ x | 12 | ខែ | = | | រៀល |
| - សម្ភារៈផ្គត់ផ្គង់ផ្សេងៗ (6098) | | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| *ថវិកាពីអភិវឌ្ឍន៍(7503)សម្រាប់បម្រើឱ្យសេវាសង្គម* | | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| | | សរុបចំនួន | | | | | 384,614,200 | រៀល |
| **២: សេវាកម្ម (61)** | | | | | | | | |
| - កិច្ចសន្យានៃការផ្តល់សេវា-សហគ្រាស(6101) | | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| *ថវិកាពីអភិវឌ្ឍន៍(7503)សម្រាប់បម្រើឲ្យការផ្គត់ផ្គង់សេវា* | | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| - ការជួលមធ្យោបាយដឹកជញ្ជូន (6102) | : | 240,000 | រៀល/ខែ x | 12 | ខែ | = | 2,880,000 | រៀល |
| *ថវិកាពីអភិវឌ្ឍន៍(7503)សម្រាប់ជួលរថយន្ត ម៉ូតូបម្រើឲ្យគម្រោង* | | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| + *សោហ៊ុយដឹកជញ្ជូន ឬធ្វើដំណើររបស់ជនងាយរងគ្រោះនិងជនពិការ(61021)* | | 240,000 | រៀល/ខែ x | 12 | ខែ | = | 2,880,000 | រៀល |
| - ថ្លៃឈ្នួល និងបន្ទុក ( អសង្ហារឹម)(6103) | : | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| - ការថែទាំ និងជួសជុល (6105) | : | | | | | | 348,494,200 | រៀល |
| + ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេរ និងដែនទេសាទ- (61051) | : | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| + ការថែទាំ និងជួសជុលអគារផ្សេងៗ និងប្រាសាទ- (61052) | : | - | រៀល/ខែ x | 12 | ខែ | = | - | រៀល |
| + ការថែទាំ និងជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ- (61053) | : | - | រៀល/ខែ x | 1 | ឆ្នាំ | = | 348,494,200 | រៀល |
| *ថវិកាពីអភិវឌ្ឍន៍(7503)សម្រាប់បម្រើឱ្យការថែទាំ* | | | រៀល/ខែ x | 1 | ឆ្នាំ | = | - | រៀល |
| 081108/20/01/01ផ្លូវបេតុងអាមេភូមិចុងកោះ:310m x5m | | 104,422,800 | រៀល/ខែ x | 1 | ឆ្នាំ | = | 104,422,800 | រៀល |
| 081108/21/01/01ផ្លូវបេតុងអាមេភូមិចុងកោះ: 500mx5m | | 244,071,400 | រៀល/ខែ x | 1 | ឆ្នាំ | = | 244,071,400 | រៀល |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| + ការថែទាំបណ្ដាញផ្សេងៗ- (61054) | : | - | រៀល/ខែ | | x 12 ខែ | = | - | រៀល |
| *ថវិកាពីអភិវឌ្ឍន៍(7503)សម្រាប់បម្រើឲ្យការថែទាំ* | | - | រៀល/ខែ | | x 12 ខែ | = | - | រៀល |
| + ការថែទាំប្រព័ន្ធធារាសាស្ត្រ- (61055) | : | - | រៀល/ខែ | | x 12 ខែ | = | - | រៀល |
| 80813/14/01-01 ...................... | | | រៀល/ខែ | | x 1 ឆ្នាំ | = | - | រៀល |
| + ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន- (61056) | : | - | រៀល/ខែ | | x 12 ខែ | = | - | រៀល |
| + ការថែទាំ និងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស- (61057) | : | - | រៀល/ខែ | | x 12 ខែ | = | - | រៀល |
| + ការថែទាំ និងជួសជុលផ្សេងៗ- (61058) | : | - | រៀល/ខែ | | x 12 ខែ | = | - | រៀល |
| - សោហ៊ុយសិក្សាពិសោធន៍ ការប្រើប្រាស់សេវា និងការប្រើប្រាស់សិទ្ធិ (6107) | | | | | | : | - | រៀល |
| + សំណងផ្នែកស៊ីវិល-(61074) | | - | | | | : | - | រៀល |
| *ថវិកាពីអភិវឌ្ឍន៍(7503)ចំណាយលើផលប៉ះពាល់គម្រោង* | | - | រៀល/ខែ | | x 12 ខែ | = | - | រៀល |
| + សោហ៊ុយផ្សេងៗទៀត-(61078) | | - | រៀល/ខែ | | x 12 ខែ | = | - | រៀល |
| - សោហ៊ុយដឹកជញ្ជូន (6108) | | | | | | : | - | រៀល |
| + សម្ភារៈ និងទំនិញ -(61081) | | - | រៀល/ខែ | | x 12 ខែ | = | - | រៀល |
| + សោហ៊ុយដឹកជញ្ជូនផ្សេងៗ -(61088) | | - | រៀល/ខែ | | x 12 ខែ | = | - | រៀល |
| - បុគ្គលិកខាងក្រៅ (6109) | | | | | | : | 28,080,000 | រៀល |
| + ភ្នាក់ងារជាតិជាប់កិច្ចសន្យាទទួលបន្ទុករដ្ឋបាល -(61091) | 670,000 | រៀល/ខែ | x 2 នាក់ | | x 12 ខែ | = | 16,080,000 | រៀល |
| + ភ្នាក់ងារជាតិជាប់កិច្ចសន្យាទទួលបន្ទុកហិរញ្ញវត្ថុ -(61091) | 1,000,000 | រៀល/ខែ | x 1 នាក់ | | x 12 ខែ | = | 12,000,000 | រៀល |
| + បុគ្គលិកសមូហភាពសាធារណៈផ្សេងៗ -(61093) | | រៀល/ខែ | x 2 នាក់ | | x 12 ខែ | = | - | រៀល |
| -ការជួលអ្នកជំនួយការរដ្ឋបាល | - | រៀល/ខែ | x 1 នាក់ | | x 9 ខែ | = | - | រៀល |
| *ថវិកាពីអភិវឌ្ឍន៍(7503)សម្រាប់ជំនួយការរដ្ឋបាលអគ្រានុគោលដ្ឋាន* | | | | រៀល/ខែ | x 12 ខែ | = | - | រៀល |
| -ការជួលគ្រូមត្តេយ្យសហគមន៍ | | រៀល/ខែ | x 2 នាក់ | | x 12 ខែ | = | - | រៀល |
| *ថវិកាពីអភិវឌ្ឍន៍(7503)សម្រាប់គ្រូមត្តេយ្យសហគមន៍* | | | | រៀល/ខែ | x 12 ខែ | = | - | រៀល |
| + បុគ្គលិកខាងក្រៅផ្សេងៗ -(61098) | - | រៀល/ខែ | x នាក់ | | x 12 ខែ | = | - | រៀល |
| - ទំនាក់ទំនងសាធារណៈ និងការផ្សព្វផ្សាយ -(6110) | | | | | | : | 960,000 | រៀល |
| + សោហ៊ុយទទួលភ្ញៀវជាតិ-(61101) | : | - | រៀល/ដង | | x 1 ឆ្នាំ | = | - | រៀល |
| + សោហ៊ុយទទួលភ្ញៀវបរទេស -(61102) | : | - | រៀល/ដង | | x 1 ឆ្នាំ | = | - | រៀល |
| + ប្រជុំ-សិក្ខាសាលា និងសន្និសីទ -(61103) | : | 80,000 | រៀល/ខែ | | x 12 ខែ | = | 960,000 | រៀល |
| *ថវិកាពីអភិវឌ្ឍន៍(7503)សម្រាប់កិច្ចប្រជុំពិនិត្យ គ្រប់គ្រងគម្រោង និងសេវាសង្គម* | | 50,000 | រៀល/ខែ | | x 12 ខែ | = | 600,000 | រៀល |
| + សោហ៊ុយពិធីបុណ្យ-(61104) | : | | រៀល/ដង | | x 1 ឆ្នាំ | = | - | រៀល |
| + ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ-(61107) | | | រៀល/ដង | | x 1 ឆ្នាំ | = | - | រៀល |
| + សោហ៊ុយទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយផ្សេងៗ-(61108) | | | រៀល/ដង | | x 1 ឆ្នាំ | = | - | រៀល |
| - ចំណាយលើការជាវសារព័ត៌មាន និងឯកសារ -(6111) | | | | | | : | 600,000 | រៀល |
| + ចំណាយលើការជាវសារព័ត៌មាន -(61111) | : | | រៀល/ខែ | | x 12 ខែ | = | - | រៀល |
| + ចំណាយលើការជាវទស្សនាវដ្ដី -(61112) | : | | រៀល/ខែ | | x 12 ខែ | = | - | រៀល |
| + ចំណាយលើការជាវសៀវភៅរាជកិច្ច -(61113) | : | | រៀល/ខែ | | x 12 ខែ | = | - | រៀល |
| + ចំណាយលើការជាវសារព័ត៌មាន និងឯកសារផ្សេងៗ -(61118) | : | 50,000 | រៀល/ខែ | | x 12 ខែ | = | 600,000 | រៀល |
| - ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស -(6112) | | | | | | : | - | រៀល |
| + សោហ៊ុយបេសកកម្ម -(61122) | | - | រៀល/ខែ | | x 12 ខែ | = | - | រៀល |
| *ថវិកាពីអភិវឌ្ឍន៍(7503)សម្រាប់សោហ៊ុយបេសកកម្មពិនិត្យគម្រោង* | | - | រៀល/ខែ | | x 12 ខែ | = | - | រៀល |
| - សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍ -(6114) | | | | | | : | 3,600,000 | រៀល |
| + សោហ៊ុយប្រៃសណីយ៍ -(61141) | | - | រៀល/ខែ | | x 12 ខែ | = | - | រៀល |
| + សោហ៊ុយទូរគមនាគមន៍ -(61142) | | 300,000 | រៀល/ខែ | | x 12 ខែ | = | 3,600,000 | រៀល |
| - សោហ៊ុយ និងសេវាកម្មផ្សេងៗ -(6198) | | | | | | : | | រៀល |
| ៣: បន្ទុកបុគ្គលិក (64) | | សរុបចំនួន | 123,040,000 | រៀល | | | | |
| - រង្វាន់ និងប្រាក់បំណាច់ផ្សេងៗ -(6403) | | | | | | : | 1,600,000 | រៀល |

\+ ងៀន់ -(64033) - រៀល/ខែ x 12 ខែ = 1,600,000 រៀល

ងៀន់សម្រាប់ឆ្នាំ២០២០ -(64033) - រៀល/ខែ x 12 ខែ = - រៀល

ងៀន់សម្រាប់ឆ្នាំ២០២១ -(64033) - រៀល/ខែ x 12 ខែ = 1,600,000 រៀល

\- លាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈរដ្ឋបាលថ្នាក់ក្រោមជាតិ-(6407) : **119,640,000** រៀល

\+ ប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សានិងមេឃុំចៅសង្កាត់ - (64073) : **70,680,000** រៀល ក្នុងនោះ៖

\- មេឃុំ : រៀល/នាក់/ខែ x 1 នាក់ x 12 ខែ = 13,320,000 រៀល

\- ជំទប់ : រៀល/នាក់/ខែ x 2 នាក់ x 12 ខែ = 20,880,000 រៀល

\- សមាជិកក្រុមប្រឹក្សា : រៀល/នាក់/ខែ x 4 នាក់ x 12 ខែ = 36,480,000 រៀល

\+ ប្រាក់ឧបត្ថម្ភមន្ត្រីភូមិ -(64074) : **48,960,000** រៀល ក្នុងនោះ៖

\- មេភូមិ : រៀល/នាក់/ខែ x 4 នាក់ x 12 ខែ = 20,640,000 រៀល

\- អនុប្រធានភូមិ : រៀល/នាក់/ខែ x 4 នាក់ x 12 ខែ = 14,880,000 រៀល

\- សមាជិកភូមិ : រៀល/នាក់/ខែ x 4 នាក់ x 12 ខែ = 13,440,000 រៀល

\- បន្ទុកផ្សេងៗទៀត -(64981) : 1,800,000 រៀល/ឆ្នាំ x 1 ឆ្នាំ = **1,800,000** រៀល

**ប្រភេទទី ២: បន្ទុកហិរញ្ញវត្ថុ** : - រៀល

៤: បន្ទុកហិរញ្ញវត្ថុ -(66) សរុបចំនួន - រៀល

**ប្រភេទទី ៣: អន្តរាគមន៍សាធារណៈ** : 4,069,380 រៀល

៥: អត្ថប្រយោជន៍សង្គម -(62) សរុបចំនួន **4,069,380** រៀល

\- អត្ថប្រយោជន៍សន្តិសុខសង្គម -(6201) : - រៀល/ខែ x 12 ខែ = រៀល

\- ជំនួយសង្គមដល់ប្រជាពលរដ្ឋ -(6202) : = **3,600,000** រៀល

\+ ជំនួយដល់ប្រជាជនសំរាកពេទ្យ និងចំណាយធ្វើដំណើរការ របស់មណ្ឌលថែទាំសុខភាព -(62021) : រៀល x 1 ឆ្នាំ = - រៀល

\+ ជួយជនរងគ្រោះដោយគ្រោះធម្មជាតិ -(62024) : រៀល x 1 ឆ្នាំ = - រៀល

\+ ជំនួយសង្គមផ្សេងៗទៀត -(62028) : រៀល x 1 ឆ្នាំ = 3,600,000 រៀល

*ថវិកាពីអភិវឌ្ឍន៍(7503)សម្រាប់គាំទ្រសេវាសង្គម* 3,600,000 រៀល

១.ឧបត្ថម្ភការធ្វើដំណើរសម្រាប់ស្ត្រីមានផ្ទៃពោះក្រីក្រទៅមន្ទីរពេទ្យ - x 12 ខែ : # - រៀល

២.ឧ.បការធ្វើដំណើរដល់ជនរងគ្រោះ កុមាររងគ្រោះ និងងាយរងគ្រោះ:

គ្រួសារងាយរងគ្រោះ និងក្រីក្រ ១១ នាក់ x 8200ស្មើ x 12 ខែ : # - រៀល

៣.ការបើកផ្តល់ប្រាក់ឧ.ដល់ជន និងគ្រួសារក្រីក្រងាយរងគ្រោះ:

កុមារក្រីក្រងាយរងគ្រោះ និងអ្នកពាក់ព័ន្ធផ្សេងទៀត x 12 ខែ : # - រៀល

៤.សោហ៊ុយធ្វើដំណើររបស់សមាជិកគ.ក.ន.ក - x 12 ខែ : # - រៀល

៥.ចំណាយឧបត្ថម្ភថាសចានបង្ខន់ ៣៦ គ្រួសារ 300,000 x 12 ខែ : # 3,600,000 រៀល

\- ឧបត្ថម្ភដល់អង្គការមូលដ្ឋាននិងគាំទ្រកម្មវិធីផ្សេងៗ -(62041) 469,380 x 1 ឆ្នាំ : **469,380** រៀល

*ថវិកាពីអភិវឌ្ឍន៍(7503)ឧបត្ថម្ភធនធានដល់អង្គការមូលដ្ឋាន* 469,380 x 1 ឆ្នាំ : 469,380 រៀល

\- ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច -(6205) x 1 ឆ្នាំ : រៀល

\- អត្ថប្រយោជន៍សង្គមផ្សេងៗទៀត -(6298) x 1 ឆ្នាំ : រៀល

៦: ឧបត្ថម្ភធន -(65) សរុបចំនួន - រៀល

\- ឧបត្ថម្ភធនរវាងរដ្ឋបាលសាធារណៈ -(6501) : - រៀល

\+ ឧបត្ថម្ភធនដល់រាជធានី ខេត្ត -(65011) រៀល x 1 ឆ្នាំ = - រៀល

\+ ឧបត្ថម្ភធនដល់ក្រុង ស្រុក ខណ្ឌ -(65012) រៀល x 1 ឆ្នាំ = - រៀល

\+ ឧបត្ថម្ភធនដល់ឃុំ សង្កាត់ -(65013) រៀល x 1 ឆ្នាំ = - រៀល

\+ ផ្សេងៗ -(65018) រៀល x 1 ឆ្នាំ = - រៀល

\- ការចូលរួមក្នុងការអនុវត្តគម្រោង -(6507) : រៀល

\- ឧបត្ថម្ភធនផ្សេងៗ -(6598) : រៀល

**ប្រភេទទី ៤: ចំណាយផ្សេងៗ** : - រៀល

ខ- **ក្រុមទី២ ចំណាយតាមជំពូកនិងចំណាយមិនបានគ្រោងទុក (ប្រ.៥+ប្រ.៦)** សរុបចំនួន **1,550,000** រៀល

**ប្រភេទទី ៥: ចំណាយតាមជំពូក (មិនទូទាត់សាច់ប្រាក់)** : - រៀល

៧: បន្ទុកពិសេស -(67) សរុបចំនួន - រៀល

- តម្លៃគណនេយ្យនៃចំណែកសកម្មបានលក់(តម្លៃនៅសល់ -(6705) : រៀល

៨: ទាយជ្ជទានឱ្យដល់រំលស់អចលកម្ម -(68) សរុបចំនួន - រៀល

- ទាយជ្ជទានឱ្យដល់រំលស់អចលកម្មអរូបី -(6801) : រៀល
- ទាយជ្ជទានឱ្យដល់រំលស់អចលកម្មរូបី -(6802) : រៀល

**ប្រភេទទី ៦: ចំណាយមិនបានគ្រោងទុក** : 1,550,000 រៀល

៩: ចំណាយមិនបានគ្រោងទុក -(69) សរុបចំនួន 1,550,000 រៀល

- ចំណាយផ្សេងៗ -(69021) 1,550,000 **1,550,000** រៀល

**ខ - សរុបចំណាយជាមូលធន ( ក្រុមទី ១ + ក្រុមទី ២ )** សរុបចំនួន - រៀល

**ក្រុមទី ១: ចំណាយពិត (ប្រ. ១ + ប្រ. ២ )** - រៀល

ប្រភេទទី ១ ការទូទាត់ប្រាក់ខ្ចី និងបំណុលរយៈពេលវែង : - រៀល

ប្រភេទទី ២: អចលកម្ម : - រៀល

១០: អចលកម្មរូបី -(21) : - រៀល

- ការរៀបចំកែលម្អ ដីធ្លី ដីវែននិងសម្បត្តិធម្មជាតិផ្សេងៗ (2102) : - រៀល
  + ការរៀបចំកែលម្អដីធ្លី -(21021) : : - រៀល
  + ការរៀបចំកែលម្អសម្បត្តិធម្មជាតិផ្សេងៗ -(21028) : - រៀល
- សំណង់អគាររដ្ឋបាល និងការកែលម្អ (2103) : - រៀល រៀល
  + សំណង់អគាររដ្ឋបាល -(21031) : - រៀល
  + ការកែលម្អអគាររដ្ឋបាល -(21032) : - រៀល
  + សំណង់ផ្សេងៗ -(21038) : - រៀល
- ហេដ្ឋារចនាសម្ព័ន្ធ (2104) : - រៀល
  + ផ្លូវថ្នល់ -(21041) - រៀល #
    - កិច្ចសន្យាទី១ : 81109 : - រៀល
    - កិច្ចសន្យាទី២ : 81109 : - រៀល
    - កិច្ចសន្យាទី៣ : : - រៀល
  + ធារាសាស្ត្រ -(21042) : - រៀល
    - កិច្ចសន្យាទី.. : 81109 : - រៀល
    - កិច្ចសន្យាទី.. : 81109 : - រៀល
  + បណ្តាញបង្ហូរទឹក និងអនាម័យ -(21047) : - រៀល
    - កិច្ចសន្យាទី.. : 81109 : - រៀល
  + ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ -(21048) : - រៀល
    - កិច្ចសន្យាទី.. : 81109 : - រៀល
- អចលកម្មរូបីផ្សេងៗទៀត -(2108) : - រៀល
  + សម្ភារ:ឧបករណ៍ការិយាល័យ -(21082) : - រៀល
  + សម្ភារ:ព័ត៌មានវិទ្យា និងទូរគមនាគមន៍ -(21083) : - រៀល
  + សង្ហារឹម -(21084) : - រៀល
  + អចលកម្មរូបីផ្សេងៗ -(21088) : - រៀល

១១: អចលកម្មកំពុងដំណើរការ -(23) : - រៀល

- ការកែលម្អ ដីធ្លី ដីវែននិងសម្បត្តិធម្មជាតិផ្សេងៗ (កំពុងដំណើរការ) -(2302) : - រៀល
  + ការកែលម្អដីធ្លី (កំពុងដំណើរការ) -(23021) : - រៀល
  + ការកែលម្អសម្បត្តិធម្មជាតិផ្សេងៗ (កំពុងដំណើរការ ) -(23028) : - រៀល
- សំណង់អគាររដ្ឋបាល និងការកែលម្អ (កំពុងដំណើរការ) -(2303) : - រៀល
  + សំណង់អគាររដ្ឋបាល (កំពុងដំណើរការ ) -(23031) : - រៀល
  + ការកែលម្អអគាររដ្ឋបាល (កំពុងដំណើរការ) -(23032) : - រៀល
  + សំណង់ផ្សេងៗ (កំពុងដំណើរការ) -(23038) : - រៀល

| | | | |
|---|---|---|---|
| - ហេដ្ឋារចនាសម្ព័ន្ធ (កំពុងដំណើរការ) -(2304) | : | - | រៀល |
| + ផ្លូវថ្នល់ (កំពុងដំណើរការ) -(23041) | : | - | រៀល |
| + ធារាសាស្ត្រ (កំពុងដំណើរការ) -(23042) | : | - | រៀល |
| + បណ្តាញបង្ហូរទឹក និងអនាម័យ (កំពុងដំណើរការ) -(23047) | : | - | រៀល |
| + ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ (កំពុងដំណើរការ) -(23048) | : | - | រៀល |
| **ក្រុមទី ២: ចំណាយតាមដីកា** | | | |
| ជំពូកទី ៣: ចំណាយតាមដីកា | : | - | រៀល |
| **សរុបចំណូលទូទៅ** | : | 524,294,200 | រៀល |
| **សរុបចំណាយទូទៅ** | : | 524,294,200 | រៀល |
| | | - | |

គម្រោងខាងលើនេះ បានរៀបចំឡើងដោយគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ ព្រមទាំងមានការចូលរួមពីសាធារណៈជនក្នុងឃុំ សង្កាត់ចំនួន .......... នាក់ កាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១។ រីឯការចំណាយអភិវឌ្ឍន៍មូលដ្ឋានគឺបានរៀបចំឡើង ផ្អែកតាមផែនការអភិវឌ្ឍ/កម្មវិធីវិនិយោគឃុំ សង្កាត់ឆ្នាំ ២០២១ និងផ្អែកតាមតំរូវការជាក់ស្តែងជាអាទិភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ចៅសង្កាត់កោះអន្លង់ចិន

ជ្រឹង-ជ្រឿង

# ៤.សេចក្តីសម្រេចលេខ ០០១/២១ ស.ស.រ ស្តីពីការបង្កើត គណ:កម្មាធិការកសាងផែនការ និងថវិកា សង្កាត់កោះអន្លង់ចិន។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកណ្តាល**
**ក្រុងតាខ្មៅ**
**រដ្ឋបាលសង្កាត់កោះអន្លង់ចិន**
លេខ៖....០០១....../២១ ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកាសង្កាត់កោះអន្លង់ចិន

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- យោងអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមុខងារ អំណាច តួនាទី ភារកិច្ចទៅអោយក្រុមប្រឹក្សាឃុំ-សង្កាត់
- យោងអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រង ហិរញ្ញវត្ថុ ឃុំ-សង្កាត់
- យោងប្រកាសលេខ៣៣១ សហវ.ប្រ.ក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការអនុវត្តថវិកាឃុំ-សង្កាត់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងប្រកាសអន្តរក្រសួងលេខ២៤៣២ ប្រ.ក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកសាងផែនការ អភិវឌ្ឍន៍ឃុំ-សង្កាត់ និងកម្មវិធីវិនិយោគឃុំ-សង្កាត់ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ
- បានឃើញប្រកាសលេខ៣០៩២ ប្រ.ក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការទទួលស្គាល់ សមាសភាពសមាជិកក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំកោះអន្លង់ចិន
- យោងប្រកាសអន្តរក្រសួងលេខ៣៨៤០ ប្រ.ក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការកែប្រែ ប្រការ៦ នៃប្រកាសអន្តរក្រសួង លេខ២៤២៣ ប្រ.កចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកសាងផែនការ អភិវឌ្ឍន៍ឃុំ-សង្កាត់ និងកម្មវិធីវិនិយោគឃុំ-សង្កាត់ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ
- យោងតាមកំណត់ហេតុប្រជុំក្រុមប្រឹក្សាសង្កាត់កោះអន្លង់ចិន នាថ្ងៃទី១២ ខែមករា ឆ្នាំ២០២១

## សម្រេច

**ប្រការ១-**

បង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកាសង្កាត់ កោះអន្លង់ចិន ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១. | លោក | **ជ្រឹង ជឿង** | ប្រធានក្រុមប្រឹក្សាសង្កាត់ | ប្រធាន |
| ២. | លោក | **ជា គីមហួន** | ចៅសង្កាត់រងទី១ | សមាជិកអចិន្ត្រៃយ៍ |
| ៣. | លោក | **ប៉ូ ឆាង** | ចៅសង្កាត់រងទី២ | សមាជិក |
| ៤. | លោកស្រី | **អាត សាម៉ុនី** | សមាជិកក្រុមប្រឹក្សាសង្កាត់ | សមាជិក |

| | | | |
|---|---|---|---|
| ៥. លោក | ឯម សុខា | មេភូមិក្បាលកោះ | សមាជិក |
| ៦. លោកស្រី | កេ ផាត | អនុប្រធានភូមិក្បាលកោះ | សមាជិក |
| ៧. លោក | ជី សំអូន | សមាជិកភូមិក្បាលកោះ | សមាជិក |
| ៨. លោក | សយ ណាន | មេភូមិកណ្ដាលកោះ | សមាជិក |
| ៩. លោក | លឹម គង់ | អនុប្រធានភូមិកណ្ដាលកោះ | សមាជិក |
| ១០. កញ្ញា | ចាយ ផល្លា | សមាជិកភូមិកណ្ដាលកោះ | សមាជិក |
| ១១. លោក | ផេង គីម | មេភូមិស្វាយពុំត្រង់ | សមាជិក |
| ១២. លោកស្រី | ប៉ោក គៀង | អនុប្រធានភូមិស្វាយពុំត្រង់ | សមាជិក |
| ១៣. លោក | ខុច ព្រហ្ម | តំណាងប្រជាពលរដ្ឋភូមិកណ្ដាលកោះ | សមាជិក |
| ១៤. លោក | ម៉ម ភីនី | មេភូមិចុងកោះ | សមាជិក |
| ១៥. លោក | អ៊ុំ អេម | អនុភូមិចុងកោះ | សមាជិក |
| ១៦. លោកស្រី | សុខ ផារី | សមាជិកភូមិចុងកោះ | សមាជិក |
| ១៧. លោក | គាំ ចាន់កុសល | ស្មៀនសង្កាត់ | លេខាធិការ |

**ប្រការ២-**

គណៈកម្មាធិការខាងលើមានភារកិច្ច៖

ទទួលខុសត្រូវ ជួយចៅសង្កាត់ ក្នុងការរៀបចំកសាងផែនការអភិវឌ្ឍន៍សង្កាត់ និងរៀបចំថវិកា ប្រចាំឆ្នាំរបស់សង្កាត់។ គណៈកម្មាធិការកសាងផែនការ និងថវិកាសង្កាត់ អនុវត្តនីតិវិធីកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគសង្កាត់ និងរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់សង្កាត់តាមអភិក្រម ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ។

**ប្រការ៣-**

គណៈកម្មាធិការកសាងផែនការ និងថវិកានេះ ត្រូវអនុវត្តនូវរបៀបរបបធ្វើការងារទៅតាម បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាសង្កាត់។

**ប្រការ៤-**

ខ្លឹមសារនៃសេចក្ដីសម្រេចទាំងឡាយណា ដែលផ្ទុយពីខ្លឹមសារនៃសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥-**

សមាសភាពដូចមានចែងក្នុងប្រការ ១ និងនាក់ពាក់ព័ន្ធ ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១៤រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
កោះអន្លង់ចិន, ថ្ងៃទី១២ ខែមករា ឆ្នាំ២០២១
**ចៅសង្កាត់**

ជ្រឹង_ភឿង

<u>ចម្លងជូន៖</u>
-សាលាខេត្តកណ្ដាល
-មន្ទីរផែនការខេត្ត
-សាលាក្រុងតាខ្មៅ
"ដើម្បីជូនជ្រាប"
-ដូចប្រការ៥"ដើម្បីអនុវត្ត"
-ឯកសារ កាលប្បវត្តិ

# ៥.សេចក្តីសម្រេចលេខ ០០២/២១ ស.ស.រ ស្តីពីការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកណ្ដាល**
**ក្រុងតាខ្មៅ**
**រដ្ឋបាលសង្កាត់កោះអន្លង់ចិន**
លេខ៖...០០២...... /២១ ស.ស.រ

## សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០១ ស្ដីពីការផ្ទេរ វិមជ្ឈការអំណាច តួនាទី និង ភារកិច្ច ទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់
- យោងអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- យោងសេចក្ដីណែនាំលេខ០៨២ ស.ណ.ន/គ.ជ.វ.វ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៧ស្ដីពីការរៀបចំ និងការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ ទូទាំង ប្រទេស
- ប្រកាសលេខ៣០៨២ ប្រក ចុះថ្ងៃទី២៧៦ ខែមិថុនា ឆ្នាំ២០១៧ ស្ដីពីការទទួលស្គាល់សមាសភាពសមាជិក សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ជំទប់ទី១ និងជំទប់ទី២ នៃ ឃុំកោះអន្លង់ចិន ស្រុកស្អាង ខេត្តកណ្ដាល របស់ក្រសួងមហាផ្ទៃ
- យោងស្មារតីប្រជុំក្រុមប្រឹក្សាសង្កាត់កោះអន្លង់ចិន នាថ្ងៃទី១៦ ខែមករា ឆ្នាំ ២០២០

## សម្រេច

**ប្រការ១-**

បង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារសង្កាត់កោះអន្លង់ចិន ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. លោក | **ព្រីង ស្រៀង** | ចៅសង្កាត់ | ប្រធាន |
| ២. លោក | **ប៉ុ ឆាង** | ចៅសង្កាត់រងទី២ | អនុប្រធាន |
| ៣. លោកស្រី | **អាត សាម៉ុនី** | សមាជិកក្រុមប្រឹក្សា | សមាជិកអចិន្ត្រៃយ៍ |
| ៤. លោក | **គាំ ចាន់កុសល** | ស្មៀនសង្កាត់ | សមាជិក |
| ៥. លោក | **នុល ចំណាន** | នាយរងប៉ុស្តិ៍រដ្ឋបាល | សមាជិក |
| ៦. លោកស្រី | **ម៉ក់ សុខន** | នាយកសាលាបឋមសិក្សា | សមាជិក |
| ៧. លោកស្រី | **អ៊ុច វណ្ណនី** | ប្រធានមណ្ឌលសុខភាព | សមាជិក |
| ៨. លោកស្រី | **កេ ផាត** | អនុប្រធានភូមិក្បាលកោះ | សមាជិក |
| ៩. កញ្ញា | **ចាយ ផល្លា** | សមាជិកភូមិកណ្ដាលកោះ | សមាជិក |
| ១០.លោកស្រី | **ម៉ោក សៀង** | អនុប្រធានភូមិស្វាយពុំក្រាង | សមាជិក |
| ១១.លោកស្រី | **សុខ ស្រី** | សមាជិកភូមិចុងកោះ | សមាជិក |

**ប្រការ២-**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារសង្កាត់មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គណៈកម្មការជូនក្រុមប្រឹក្សាសង្កាត់អនុម័ត
- ផ្តល់ប្រឹក្សាយោបល់ និងជួយក្រុមប្រឹក្សាសង្កាត់ ចំពោះការងារពាក់ព័ន្ធកិច្ចការនារី និងកុមារនៅសង្កាត់
- អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យយល់ដឹងអំពីច្បាប់ គោលនយោបាយនានារបស់រដ្ឋពាកព័ន្ធសិទ្ធិនារី និងកុមារ និងបំផុសចលនាសហគមន៍លើវិស័យសុខភាពអប់រំ កិច្ចការពារ និងការអភិវឌ្ឍកុមារ ព្រមទាំងការចុះបញ្ជីអត្រានុកូលដ្ឋានជូនទារក និងកុមារ
- ទាក់ទាញការគាំទ្រដើម្បីអោយនារីបានចូលរួមធ្វើសេចក្តីសម្រេច លើការអភិវឌ្ឍនៅមូលដ្ឋានសង្កាត់
- បង្កើននិងពង្រឹងនូវការប្រាស្រ័យទាក់ទងកិច្ចសហការ និងការសម្រមស្រួលរវាងក្រុមប្រឹក្សាសង្កាត់ និងអ្នកផ្តល់សេវាកម្ម និងអ្នកភូមិ ដែលធ្វើសកម្មភាពជួយនារី និងកុមារនៅក្នុងសង្កាត់របស់ខ្លួន
- ជួយក្រុមប្រឹក្សាសង្កាត់ក្នុងការប្រមូល វិភាគព័ត៌មានទិន្នន័យ ពាក់ព័ន្ធបញ្ហា និងតម្រូវការរបស់នារីនិង កុមារ ដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍សង្កាត់ និងកម្មវិធីវិនិយោគសង្កាត់
- ចូលរួមអនុវត្តពិនិត្យតាមដាន និងវាយតម្លៃផែនការសកម្មភាពពាក់ព័ន្ធ ស្ថានភាពនារី និងកុមារ
- តាមដានស្ថានភាពនារី និងកុមារក្នុងសង្កាត់ និងធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សាសង្កាត់ ព្រមទាំងដាក់បញ្ចូលក្នុងរបាយការណ៍សង្កាត់

ចៅសង្កាត់ ដែលជាប្រធានគណៈកម្មាធិការត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាសង្កាត់របស់ខ្លួន។

គណៈកម្មាធិការត្រូវសម្របសម្រួល និងសហការជិតស្និតជាមួយអ្នកផ្តល់សេវាកម្មនានា ផ្នែកសង្គមកិច្ច និងអ្នកស្ម័គ្រចិត្តភូមិ និងសហគមន៍នៅក្នុងសង្កាត់ ដើម្បីបំពេញតួនាទី ភារកិច្ចខាងលើឲ្យមានប្រសិទ្ធិភាព។

**ប្រការ៣-**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារនេះត្រូវអនុវត្តនូវរបៀបរបប ធ្វើការទៅតាម បទបញ្ជា ផ្ទៃក្នុងរបស់ក្រុមប្រឹក្សាសង្កាត់ សង្កាត់ ។

**ប្រការ៤-**

ខ្លឹមសារនៃសេចក្តីសម្រេចទាំងឡាយណា ដែលផ្ទុយពីខ្លឹមសារនៃសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥-**

សមាសភាពដែលមានចែងក្នុងប្រការ១ និងអ្នកពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធិ ភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១៤រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

កោះអន្លង់ចិន, ថ្ងៃទី១២ ខែមករា ឆ្នាំ២០២១

**ចៅសង្កាត់**

ជ្រឹម ព្រឿម

ចម្លងជូន៖

-សាលាខេត្តកណ្ដាល

-សាលាក្រុងតាខ្មៅ

"ដើម្បីជូនជ្រាប"

-ដូចប្រការ៤"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

# ៦.សេចក្ដីសម្រេចលេខ ០០៣/២១ ស.ស.រ ស្ដីពីការបង្កើត គណៈកម្មការលទ្ធកម្មសង្កាត់កោះអន្លង់ចិន។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកណ្តាល**
**ក្រុងតាខ្មៅ**
**រដ្ឋបាលសង្កាត់កោះអន្លង់ចិន**
លេខ៖....០០៣....../២១ ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការលទ្ធកម្មសង្កាត់កោះអន្លង់ចិន

- បានឃើញអនុក្រឹត្យលេខ៦០ អ.ន.ក្រ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ២៦ អ.ន.ក្រ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឃុំ-សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ប្រកាសលេខ៣០៨២ ប្រក ចុះថ្ងៃទី២៧៦ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការទទួលស្គាល់សមាសភាពសមាជិក សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំកោះអន្លង់ចិន ស្រុកស្អាង ខេត្តកណ្តាល របស់ក្រសួងមហាផ្ទៃ
- បានឃើញប្រកាសអន្តរក្រសួងលេខ ០៨៨ ប្រ.ក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- យោងស្មារតីប្រជុំក្រុមប្រឹក្សាសង្កាត់កោះអន្លង់ចិន នាថ្ងៃទី១២ ខែមករា ឆ្នាំ២០២១
- **យោងតាមការចាំបាច់របស់សង្កាត់**

## សម្រេច

**ប្រការ១-**

បង្កើតគណៈកម្មការលទ្ធកម្មរបស់សង្កាត់កោះអន្លង់ចិន ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១.លោក | **ជ្រឹង ជ្រឿង** | ចៅសង្កាត់ | ប្រធាន |
| ២.លោក | **ជា គឹមហួន** | ចៅសង្កាត់រងទី១ | អនុប្រធាន |
| ៣.លោកស្រី | **អាត សាម៉ុនី** | សមាជិកក្រុមប្រឹក្សា | សមាជិក |
| ៤.លោក | **តាំ ចាន់កុសល** | ស្មៀនសង្កាត់ | លេខាធិការ |

**ប្រការ២-**

គណៈកម្មការក្នុងប្រការ១ មានភារកិច្ចទទួលបន្ទុកការងារទាំងឡាយមាន៖

- ធ្វើការវាយតំលៃលើការងារជេញថ្លៃ របស់អ្នកម៉ៅការ និងអ្នកផ្គត់ផ្គង់
- ផ្តល់អនុសាសន៍ លើការសម្រេចចុះកិច្ចសន្យា ។

**ប្រការ៣-**

គណៈកម្មការលទ្ធកម្មត្រូវធានា៖

- លទ្ធកម្មការងារសាងសង់ ការផ្គត់ផ្គង់សម្ភារៈ និងការផ្ដល់សេវា ប្រព្រឹត្តទៅប្រកបដោយតម្លាភាព និងសន្សំសំចៃ
- អ្នកម៉ៅការ និងអ្នកផ្គត់ផ្គង់ ត្រូវបានឱកាសស្មើៗគ្នា ក្នុងការចូលរួមប្រគួតប្រជែង ផ្គត់ផ្គង់ សម្ភារៈ និងផ្គត់ផ្គង់សេវាក្រោមលក្ខខណ្ឌតែមួយ
- លទ្ធផលនៃការងារលទ្ធកម្មត្រូវប្រកាសជាសាធារណៈ។

**ប្រការ៤-**

ស្នាក់ការអចិន្ត្រៃយ៍ របស់គណៈកម្មការលទ្ធកម្ម ស្ថិតនៅសាលាសង្កាត់។

**ប្រការ៥-**

គណៈកម្មការក្នុងប្រការ១នេះ មានសិទ្ធិប្រើប្រាស់ត្រារបស់សង្កាត់។

**ប្រការ៦-**

ខ្លឹមសារនៃសេចក្ដីសម្រេចទាំងឡាយណា ដែលផ្ទុយពីខ្លឹមសារនៃសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧-**

គណៈកម្មការក្នុងប្រការ១ និងស្មៀន ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១៤រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

កោះអន្លង់ចិន, ថ្ងៃទី១២ ខែមករា ឆ្នាំ២០២១

**ចៅសង្កាត់**

ជ្រឹម_ជ្រឿម

__ចម្លងជូន៖__

-សាលាខេត្តកណ្ដាល

-មន្ទីរផែនការខេត្ត

-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត

-មន្ទីរនានាជុំវិញខេត្ត

-សាលាក្រុងតាខ្មៅ

"ដើម្បីជូនជ្រាប"

-ដូចប្រការ៧ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

# ៧.សេចក្តីសម្រេចលេខ ០០៤/២១ ស.ស.រ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងគម្រោងសង្កាត់កោះអន្លង់ចិន។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកណ្ដាល**
**ក្រុងតាខ្មៅ**
**រដ្ឋបាលសង្កាត់កោះអន្លង់ចិន**
លេខ៖...០០៤...../២១ ស.ស.

**សេចក្ដីសម្រេច**
**ស្ដីពី**
**ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងគម្រោងសង្កាត់កោះអន្លង់ចិន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមុខងារអំណាច តួនាទីភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់
- យោងសេចក្តីសម្រេចលេខ០៩៧ សសរ/គ.ជ.អ.ប ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីការដាក់ឲ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់
- យោងតាមស្មារតីអង្គប្រជុំក្រុមប្រឹក្សាសង្កាត់នាថ្ងៃទី១២ ខែមករា ឆ្នាំ២០២១
- យោងតាមការចាំបាច់របស់សង្កាត់

**សម្រេច**

**ប្រការ១-**

បង្កើតគណៈកម្មការគ្រប់គ្រងគម្រោងរបស់សង្កាត់កោះអន្លង់ចិន ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១.លោក | **ជ្រឹង ជឿង** | ចៅសង្កាត់ | ប្រធាន |
| ២.លោក | **ប៉ុ ឆាង** | ចៅសង្កាត់រងទី២ | អនុប្រធាន |
| ៣.លោកស្រី | **អាត សាម៉ុនី** | សមាជិកក្រុមប្រឹក្សា | សមាជិក |
| ៤.លោកស្រី | **ថៃ សុភាវី** | សមាជិកក្រុមប្រឹក្សា | សមាជិក |
| ៥.លោក | **សយ ណាន** | មេភូមិកណ្ដាលកោះ | សមាជិក |
| ៦.លោក | **គាំ ចាន់កុសល** | ស្មៀនសង្កាត់ | លេខាធិការ |

**ប្រការ២-**

គណៈកម្មការគ្រប់គ្រងគម្រោងមានតួនាទី ភារកិច្ចដូចខាងក្រោម៖

**ក. ការរៀបចំគម្រោង**

- ពិនិត្យ និងអនុម័តផែនការសិក្សាគម្រោង
- រៀបចំសំណើគេម្រោង ដោយមានជំនួសពីអ្នកជំនួយការបច្ចេកទេស
- ពិនិត្យ និងអនុម័តលើសំណើគេម្រោង។

ខ. ការអនុវត្តគម្រោង

- គ្រប់គ្រងតាត់ចែងសំណើការអនុវត្តគម្រោង
- រៀបចំប្រជុំចាប់ផ្តើម និងបញ្ចប់នៃការអនុវត្តការងារ ឬការផ្គត់ផ្គង់ទំនិញ និងរៀបចំប្រជុំពិនិត្យ និងអនុម័តការទូទាត់គម្រោង
- រៀបចំកិច្ចប្រជុំនានានៅក្នុងអំឡុងពេលអនុវត្តគម្រោង ដើម្បីពិនិត្យ និងវាយតម្លៃការអនុត្តន៍គម្រោង ដើម្បីពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង។

**ប្រការ៣-**

គណៈកម្មការគ្រប់គ្រងគម្រោងមានរបៀបរបបការងារដូចខាងក្រោម៖

- ប្រធានគណៈកម្មាការគ្រប់គ្រងគម្រោង ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់ គណៈកម្មការគ្រប់គ្រងគម្រោង។ ក្នុងករណីប្រធានអវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយលក្ខអក្សរទៅឲ្យអនុប្រធាន ជាប្រធានស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ
- កិច្ចប្រជុំរបស់គណៈកម្មាការគ្រប់គ្រងគម្រោងអាចប្រព្រឹត្តទៅបាន លុះត្រាតែមាន សមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាការទាំងមូល
- សេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងអាចយកជាការបាន លុះត្រាតែមានសម្លេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការទាំងមូល។ ប្រសិនបើសំឡេងអនុម័តមានចំនួនស្មើគ្នា សំឡេងរបស់គណៈអធិបតីនៃអង្គប្រជុំមានឧត្តមានុភាព
- ប្រធានគណៈកម្មការគម្រោងគ្រប់គ្រងគម្រោង អាចអញ្ជើញបុគ្គលិកមកពីភ្នាក់ងារនានា ឬតំណាងអង្គការសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធនឹងគម្រោង ដើម្បីចូលរួមកិច្ចប្រជុំ គណៈកម្មការនាមជាអ្នកសង្កេត
- គ្រប់កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោង ត្រូវមានកំណត់ហេតុដែលរៀបចំដោយលេខាធិការរបស់គណៈកម្មការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

**ប្រការ៤-**

ខ្លឹមសារនៃសេចក្តីសម្រេចទាំងឡាយណា ដែលផ្ទុយពីខ្លឹមសារនៃសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥-**

សមាសភាពដែលមានចែងក្នុងប្រការ១ និងអ្នកពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធិ ភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១៤រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

កោះអន្លង់ចិន, ថ្ងៃទី១២ ខែមករា ឆ្នាំ២០២១

**ចៅសង្កាត់**

ជ្រឹង-ជ្រឿង

ចម្លងជូន ៖
- រដ្ឋបាលខេត្តកណ្តាល
- រដ្ឋបាលក្រុងតាខ្មៅ
"ដើម្បីជូនជ្រាប"
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ៨.កំណត់ហេតុស្តីពី ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលសង្កាត់កោះអន្លង់ចិន (២០២១-២០២៣) ថ្ងៃទី១២ ខែមករា ឆ្នាំ២០២១។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកណ្តាល**

**ក្រុងតាខ្មៅ**

**រដ្ឋបាលសង្កាត់កោះអន្លង់ចិន**

## កំណត់ហេតុ

ឆ្នាំពីរពាន់ម្ភៃមួយ ខែមករា ថ្ងៃទីដប់ពីរ វេលាម៉ោងប្រាំបីព្រឹក នៅសាលាសង្កាត់កោះអន្លង់ចិនបានបើកកិច្ចប្រជុំសាមញ្ញ ដើម្បីពិនិត្យ និងពិភាក្សាអនុម័តសៀវភៅកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់សង្កាត់ក្រោមអធិបតីភាព លោក **ជ្រឹង ជឿង** ប្រធានក្រុមប្រឹក្សាសង្កាត់ និងជាចៅសង្កាត់កោះអន្លង់ចិន។

### សមាសភាពចូលរួម

| | | | |
|---|---|---|---|
| ១. លោក | **ជ្រឹង ជឿង** | ចៅសង្កាត់ | ប្រធាន |
| ២. លោក | **ជា គឹមហួន** | ចៅសង្កាត់រងទី១ | អនុប្រធាន |
| ៣. លោក | **ប៉ុំ ឆាង** | ចៅសង្កាត់រងទី២ | សមាជិក |
| ៤. លោកស្រី | **អាត សាម៉ីនី** | សមាជិកក្រុមប្រឹក្សា | សមាជិក |
| ៥. លោកស្រី | **ផៃ សុភាវី** | សមាជិកក្រុមប្រឹក្សា | សមាជិក |
| ៦. លោក | **សួង ថន** | សមាជិកក្រុមប្រឹក្សា | សមាជិក |
| ៧. លោក | **យឿន យ៉ុង** | សមាជិកក្រុមប្រឹក្សា | សមាជិក |
| ៨. លោក | **តាំ ចាន់កុសល** | ស្មៀនសង្កាត់ | លេខាធិការ |
| ៩. លោក លោកស្រី ជាមេភូមិ អនុភូមិគ្រប់ភូមិ | | | សមាជិក |

បន្ទាប់ពីសមាជិក សមាជិកា នៃអង្គប្រជុំបានមកជួបជុំគ្រប់គ្នាគ្រប់កូរ៉ុម អាចដំណើរការបានរួចមក លោកប្រធានអង្គប្រជុំ បានថ្លែងអំណរគុណចំពោះវត្តមាន សមាជិក សមាជិកា នៃអង្គប្រជុំហើយបានប្រកាសបើកអង្គប្រជុំ។ ជាបន្តលោកបានអនុញ្ញាតឲ្យ លោក **តាំ ចាន់កុសល** ស្មៀនសង្កាត់ អាននូវខ្លឹមសារកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់សង្កាត់ជូនដល់អង្គប្រជុំឲ្យបានជ្រាប។

បន្ទាប់ពីអានចប់រួចរាល់ជាស្ថាពរ ហើយលោកប្រធានបានដាក់ខ្លឹមសារទាំងនេះឲ្យសមាជិកសមាជិកា នៃអង្គប្រជុំទាំងមូល ធ្វើការពិនិត្យ និងពិភាក្សាគ្នាទៅតាមទំព័រ ផ្នែក និងជំពូកនីមួយៗ។

ក្រោយពីបានពិនិត្យ និងពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក អង្គប្រជុំបានសម្រេចអនុម័តយល់ព្រមដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២១-២០២៣ ចំនួន ០៧ លើ០៧ សម្លេង។

អង្គប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង ដប់និងសែសិបនាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

**លេខាកត់ត្រា**

តាំ ចាន់កុសល

បានឃើញ និងឯកភាព

**ប្រធានអង្គប្រជុំ**

ជ្រឹង ជឿង

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកណ្ដាល
ក្រុងតាខ្មៅ
រដ្ឋបាលសង្កាត់កោះអន្លង់ចិន

## បញ្ជីវត្តមានចូលរួមប្រជុំ

**ខ្លឹមសារ:** ពិភាក្សា និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល (2021-2023)

**កាលបរិច្ឆេទ** 12.01.2021

| ល.រ | គោត្តនាម-នាម | ភេទ | តួនាទី | អង្គភាព | លេខទូរស័ព្ទ | ហត្ថលេខា |
|---|---|---|---|---|---|---|
| ១ | [illegible] | ប | [illegible] | [illegible] | 07[illegible]35187 | |
| ២ | [illegible] | ប | [illegible] | -"- | 095262088 | |
| ៣ | [illegible] | ប. | [illegible] | -"- | 012710033 | |
| ៤ | [illegible] | ប | [illegible] | -"- | 070896588 | |
| ៥ | [illegible] | ប | [illegible] | [illegible] | 092928012 | |
| ៦ | [illegible] | ស | ក្រុមប្រឹក្សា | ក្រុងតាខ្មៅ | 099617285 | |
| ៧ | [illegible] | ស | [illegible] | [illegible] | 012592636 | |
| ៨ | [illegible] | ប | [illegible] | កោះអន្លង់ចិន | 098256623 | |
| ៩ | [illegible] | ស | [illegible] | [illegible] | 012434545 | |
| ១០ | [illegible] | ប | [illegible] | [illegible] | 012801304 | |
| ១១ | [illegible] | ប | [illegible] | [illegible] | 092819696 | |
| ១២ | [illegible] | ប | [illegible] | -"- | 012432346 | |
| ១៣ | [illegible] | ប | [illegible] | [illegible] | 092155664 | |
| ១៤ | [illegible] | ប. | [illegible] | [illegible] | 010575893 | |
| ១៥ | [illegible] | ប | [illegible] | [illegible] | 011863887 | |
| ១៦ | [illegible] | ប | [illegible] | [illegible] | | |
| ១៧ | [illegible] | ប | [illegible] | -"- | 076502O213 | |
| ១៨ | គាំ ចាន់កុសល | ប | ស្មៀន | កោះអន្លង់ចិន | 069 209 206 | |
| ១៩ | | | | | | |
| ២០ | | | | | | |

ថ្ងៃអង្គារ ១៣កើតខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
កោះអន្លង់ចិន,ថ្ងៃទី ១២ ខែមករា ឆ្នាំ២០២១

បានឃើញ និងឯកភាព
**ចៅសង្កាត់**

[illegible]

**អ្នកធ្វើតារាង**

គាំ ចាន់កុសល

៩.លិខិតបញ្ជាក់លេខ ២៤៣ ល.ប ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១ ស្ដីពីការចុះស្រាវជ្រាវឯកសារនៅក្នុងសង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្ដាល។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកណ្ដាល**
**ក្រុងតាខ្មៅ**
**រដ្ឋបាលសង្កាត់កោះអន្លង់ចិន**

លេខ៖......២៤៣....... /២១ ល.ប

ថ្ងៃអង្គារ ៣រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
កោះអន្លង់ចិន,ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១

**លិខិតបញ្ជាក់**
**ចៅសង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្ដាល**

**សូមបញ្ជាក់ថា**

និស្សិតឈ្មោះ **អ៊ុង ផាណ្ណា** ភេទស្រី និង **ទិត សុផានី** ភេទស្រី ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាញរដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពិតជាបានចុះស្រាវជ្រាវឯកសារពាក់ព័ន្ធជុំវិញប្រធានបទ **«ការគ្រប់គ្រងរដ្ឋបាលតាមបែបគោលការណ៍វិមជ្ឈការក្នុងសង្កាត់កោះអន្លង់ចិន (កណ្ដាល)»** ពិតប្រាកដមែន។

និស្សិតស្រាវជ្រាវលើប្រធានបទខាងលើនេះ បានសុំការអនុញ្ញាតត្រឹមត្រូវ និងមានកិច្ចសហប្រតិបត្តិការជាមួយរដ្ឋបាលសង្កាត់ ក្រោមការដឹកនាំរបស់យើងខ្ញុំ ក្នុងក្របខណ្ឌដើម្បីស្រាវជ្រាវ ស្វែងរកចំណេះដឹងនៅក្នុងវិស័យសាធារណៈប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ ទំនាក់ទំនងល្អ និងការខិតខំព្យាយាមស្រាវជ្រាវអស់ពីកម្លាំងកាយចិត្ត។

ក្នុងនាមរដ្ឋបាលសង្កាត់កោះអន្លង់ចិន សូមសម្ដែងនូវក្ដីសោមនស្សរីករាយ ចំពោះនិស្សិតដែលបានមកធ្វើការស្រាវជ្រាវ ដើម្បីសិក្សាស្វែងយល់ និងបង្កើនពុទ្ធិរបស់ខ្លួន។

លិខិតបញ្ជាក់នេះ ផ្ដល់ជូនសាមីខ្លួន ដើម្បីយកទៅប្រើប្រាស់តាមផ្លូវការដែលអាចប្រើបាន។

**ចៅសង្កាត់កោះអន្លង់ចិន**

សង្កាត់
ជ្រឹង ព្រឿន

# ១០.ផែនទីសង្ខាត់ កោះអន្លង់ចិន។

# ផែនទីប្រើប្រាស់ដីបច្ចុប្បន្នក្នុងសង្កាត់កោះអន្លង់ចិន ក្រុងតាខ្មៅ ខេត្តកណ្ដាល

